Formation, Dialogue, Cooperation

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែកុម្ភៈ ឆ្នាំ២០១៧ លក់តម្លៃ ១០០០រៀល

លេខ ៩៩



## សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ លើកទឹកចិត្តព្រះសហាគមន៍កាតូលិក នៅកម្ពុជានិងនៅប្រទេសឡាវ

## សេចក្ដីជូនដំណឹង

"គ្មាននរណាមានសេចក្ដីស្រឡាញ់ ខ្លាំងជាងអ្នកដែលស៊ូប្ដូរជីវិត ដើម្បីមិត្តសម្លាញ់របស់ខ្លួននោះឡើយ ៗ" (យហ. ១៥,១៣) គំរូរបស់មរណសាក្សី ជួយជំរុញជំនឿរបស់យើងៗ សូមអរគុណបងប្អូន ដែលផ្ដល់ព័ត៌មានមួយចំនួនហើយទាក់ទងនឹងមរណសាក្សីរបស់យើងៗ យើងនៅតែត្រូវការរូបថត លិខិតឬស្នាដៃរបស់អ្នកបម្រើរបស់ព្រះជាម្ចាស់ទាំងនោះៗ សូមបងប្អូនផ្ដល់ព័ត៌មានឲ្យយើងទាំងនោះ តាមរយៈអាសយដ្ឋាននៅខាងក្រោម៖

Tel : 077 800 211 / 096 34 22 144

Email: martyrscambodia@gmail.com

ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ

# ដូនជីឧបការគុណសញ្ជាតិខ្មែរ២រូបប្រកាសពាក្យសច្ចានិរន្តរ៍នៅភ្នំពេញ



ថតដោយ សុធារិទ្ធ

ក្រុមគ្រួសារដូនជីឧបការគុណនៅព័រស៊ី ដែលមាន វត្តមាន ក្នុងប្រទេសកម្ពុជា បាន រៀបចំពិធីអរព្រះគុណព្រះជាម្ចាស់ ដោយ មានប្រកាសពាក្យសច្ចានិរន្តរ៍សម្រាប់ដូនជីម៉ារីម៉ាដាឡា ឌិន ចន្ថា និងដូនជីអាន ម៉ារី ខាយ ដានី។ ពិធីនេះឡើងនៅព្រះវិហារព្រះកុមារយេស៊ូ (បឹងទំពុន) ក្រោម អធិបតីភាព លោកអភិបាលអូលីវីយេ ឆ្មីតអីស្លែរ និងមានក្រុមបុព្វជិត បព្វជីតា ព្រមទាំងគ្រីស្តបរិស័ទចូលរួមអបអរសាទរយ៉ាងច្រើនកុះករ កាលពីថ្ងៃទី១៤ មករា ២០១៧នេះ។

ពិធីប្រកាសពាក្យសច្ចាជានិរន្តរ៍ ត្រូវបាន ធ្វើឡើងបន្ទាប់ពីអត្ថបទព្រះគម្ពីរដំណឹង ល្អ ដោយដូនជីប្រធានក្រុមគ្រួសារឧបការគុណនៅកម្ពុជា ប្រកាសហៅឈ្មោះបេក្ខនារីទាំងពីរដើម្បីបង្ហាញខ្លួនដល់ លោក អភិបាលព្រះសហគមន៍ ដូនជីប្រធាន សហធម្មចារីក្រុមឧបការគុណ នៅមុខ អសនៈ និងចំពោះមុខគ្រីស្តបរិស័ទទាំង អស់។

ជាមួយនឹងពាក្យឆ្លើយតប ដោយបង្ហាញ ថាព្រះជាម្ចាស់បានត្រាស់ហៅ "ចាស! ព្រះអង្គបានត្រាស់ហៅខ្ញុំ គឺខ្ញុំនេះហើយ!" ដូនជីទាំងពីរ បានប្រកាសពាក្យស្នើសុំទៅ ប្រធានក្នុងការប្រកាសពាក្យសច្ចារបស់ ខ្លួនជានិរន្តរ៍ ដោយសុខចិត្តថ្វាយខ្លួនទាំង ស្រុង ដើម្បីបម្រើព្រះសហគមន៍ និងបង ប្អូនតាមស្មារតីរបស់លោកបូជាចារ្យ យ៉ូហាន ម៉ាតាំងម៉ូយ ដែលជាឧបការីនៃក្រុមនេះ។

លោកអភិបាលព្រះសហគមន៍ បាន សួរបញ្ជាក់អំពីគោលបំណងរបស់បេក្ខនារីទាំងពីរ ក្នុងការសម្រេចចិត្តសច្ចាជា និរន្តរ៍ ហើយបងស្រីទាំងពីរក៏បានឆ្លើយ តបថា ចង់ដើរតាមព្រះគ្រីស្ត ដោយប្រកាន់ ភ្ជាប់នូវពាក្យសច្ចាស្តប់បង្គាប់ សច្ចាក្រីក្រ និងសច្ចាព្រហ្មចារីតាមធម្មនុញ្ញរបស់ក្រុម គ្រួសារដូនជីឧបការគុណនៅព័រស៊ី។

ជាមួយគ្នានេះដែរ ព្រះសហគមន៍ទាំង មូល រួមជាមួយដូនជីដែលហៀបនឹងប្រកាស ពាក្យសច្ចានិរន្តរ៍ បានលុតជង្គង់ ដើម្បីទូល អង្វរព្រះវិញ្ញាណដ៏វិសុទ្ធ តាមរយៈធម៌អង្វរ របស់សន្តបុគ្គលទាំងឡាយ ដើម្បីអធិដ្ឋាន ឲ្យបងស្រីទាំងពីរ។ និងបន្ទាប់មកមាន ពិធីបំពាក់ចិញ្ចៀន និងចុះហត្ថលេខាដោយ មានលោកអភិបាលជាតំណាងព្រះសហគមន៍ និងមានសាក្សីផងដែរ។

បន្ទាប់មកដូនជី ម៉ារីម៉ាដាឡា និង ដូនជីអានម៉ារី បានប្រកាសពាក្យសច្ចា របស់ខ្លួនដោយដាក់ដៃទាំងពីរទៅក្នុងដៃ ប្រធានសហធម្មចារី ដោយប្រកាសលើក តម្កើងព្រះជាម្ចាស់ និងផ្ញើរជីវិតទាំងស្រុង ដើម្បីធ្វើជាឧករណ៍របស់ព្រះជាម្ចាស់ក្នុង ការប្រកាសដណឹងល្អ។

នៅក្នុងធម្មទេសនា លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ថា អត្ថន័យ នៃជីវិតជាបងស្រី គឺធ្វើជាសាក្សីរបស់ ព្រះយេស៊ូ និងព្រះអង្គបានលើកបងស្រី ឡើងឲ្យមានឋានៈជាភរិយារបស់ព្រះអង្គ។ លោកបានបន្តថា នេះជាជីវិតថ្មីដែលមាន ប្ដីថ្មីមួយគឺព្រះយេស៊ូផ្ទាល់ ដោយបងស្រី ទាំងពីរបានលះបង់សម្រាប់ព្រះយេស៊ូ សម្រាប់បងប្អូនឯទៀតៗគ្រប់កាលៈទេសៈ។ លោកបន្ថែមថា បងស្រីទាំងពីរ នឹងទៅជាសញ្ញាមួយយ៉ាងពិសេស ស្រាប់យុវជន យុវនារី ដើម្បីរិះគិត និង មើលឃើញអំពីការត្រាស់ហៅ។

លោកអូលីវីយេ ក៏បានស្នើសុំឲ្យបង ស្រីចងចាំនូវពាក្យសច្ចាខាងលើ និងទុក ចិត្តទៅលើឧបការគុណរបស់ព្រះជាម្ចាស់។ លោកថាពាក្យសច្ចាស្តាប់បង្គាប់សំខាន់ ណាស់ ព្រោះថាសម្លេងរបស់ព្រះសហគមន៍ និងបងស្រីប្រធាន គឺជាសម្លេងរបស់ ព្រះជាម្ចាស់។

លើសពីនេះទៅទៀត លោកអភិបាល បានសំណូមពរ សុមឲ្យបងស្រីឧបការ គុណទាំងអស់ដែលមានវត្តមាននៅប្រទេស កម្ពុជា រិះគិតអំពីវិធីថ្មីៗ ដើម្បីបន្តប្រកាស ដំណឹងល្អដល់អស់អ្នកដែលកំពុងស្រេក ឃ្លាន និងគ្មានក្ដីសង្ឃឹម និងជាពិសេស សូមឲ្យចូលរួមសកម្មភាពមេត្តាករុណា ទាំងប្រាំពីរវិស័យរបស់ព្រះសហគមន៍។ លោកអូលីវីយេ បញ្ជាក់ថា ដើម្បីឲ្យការ ប្រកាស ដំណឹងល្អនេះទទួលបានជោគជ័យ និងមានអំណរសប្បាយនៅក្នុងជីវិត ជាបុព្វជិត បុព្វជីតា គឺត្រូវចេះលើកទឹក ចិត្ត និងផ្ដល់កម្លាំងឲ្យគ្នាទៅវិញទៅមក ទាំងនៅក្នុងក្រុម និងក្រុមដទៃទៀត។

យោងតាមខ្លឹមសារនៃឯកសារ ព្រះ សហគមន៍ជាពន្លឺពិភពលោក លេខ ៤៤-៤៥ បានសរសេរថា៖ ដោយអគ្គសញ្ញាជ្រមុជទឹក គ្រីស្តបរិស័ទលែងជំពាក់ បាបដូចមនុស្សស្លាប់ទៀតហើយ ព្រោះ គេបានថ្វាយខ្លួនទៅព្រះជាម្ចាស់រួចជា ស្រេច។ ប៉ុន្តែការប្រកាសពាក្យសច្ចានិរន្តរ៍ក្នុងព្រះសហគមន៍ ដោយកាន់តាម ដំបូន្មានដែលចែងទុកក្នុងព្រះគម្ពីរដំណឹង ល្អ គេចង់រួចផុតពីអ្វីៗ ដែលសង្កត់ខ្លួន និងរារាំងខ្លួន តាមផ្លូវទៅរកសេចក្ដីស្រឡាញ់ដ៏ខ្លាំងក្លា ក្នុងការគោរពបម្រើព្រះ ជាម្ចាស់យ៉ាងពេញលក្ខណៈ។ តាម អំណាចដែលព្រះជាម្ចាស់បានផ្ញើរទុកមក ព្រះសហគមន៍ផ្ទាល់ក៏ទទួលពាក្យសច្ចា និរន្តរ៍របស់អស់អ្នកដែលថ្វាយខ្លួន។ ព្រះ សហគមន៍អង្វរព្រះជាម្ចាស់ជាសាធារណៈ ព្រះសហគមន៍ក៏អង្វរព្រះអង្គ សូមទ្រង់ ប្រណីសន្តោសអ្នកទាំងនោះ និងផ្ញើរអ្នក ទាំងនោះទៅព្រះអង្គ សូមព្រះអង្គប្រទាន ព្រះវិញ្ញាណដល់ការថ្វាយខ្លួននេះទុកជា តង្វាយរួមជាមួយព្រះគ្រីស្តក្នុងសក្ការបូជាអរព្រះគុណ។

បច្ចុប្បន្នក្រុមគ្រួសារដូនជីឧបការគុណ នៅក្នុងប្រទេសកម្ពុជា មានចំនួន១៨ នាក់ ដោយមានមុខងារបម្រើព្រះសហគមន៍កាតូលិកទាំងបីភូមិភាគ គឺភ្នំពេញ បាត់ដំបង និងកំពុងចាម តាមរយៈការ ចូលរួមសកម្មភាពមេត្តាករុណានៅក្នុង សង្គម និងការងារព្រះសហគមន៍។

ក្រោយពិធីសច្ចានិរន្តរ៍ ក៏មានពិធីជប់ លៀងអបអរសាទរ ដល់ភរិយាថ្មីរបស់ ព្រះជាម្ចាស់ទាំងពីររូប ដោយអំណរ សប្បាយ។

*ដោយដាលីស*


Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org

Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org

https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

ចាងហ្វាង : លោក លី សុវណ្ណា

សេចក្ដីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# សេចក្តីស្រឡាញ់ តាមគំនិតរបស់សង្គមនិងគ្រីស្តសាសនា

ពេលដល់ខែកុម្ភៈ អ្នកខ្លះអាចនឹកដល់ថ្ងៃនៃសេចក្តីស្រឡាញ់ (Valentine Day) ដែលត្រូវនឹង ថ្ងៃទី១៤ ខែកុម្ភៈ តើថ្ងៃនេះយើងឃើញយុវជនយុវនារី ឬក៏មនុស្សមួយចំនួនព្យាយាមបង្ហាញ សញ្ញានៃ សេចក្តីស្រឡាញ់របស់ពួកគេ ដែលជាសេចក្តីស្រឡាញ់ ដែលមនុស្សយើងមានក្នុងចិត្តតាំងពីកំណើតមក។

សេចក្តីស្រឡាញ់តាមគំនិតរបស់ទស្សនវិទូជនជាតិក្រិក មានចែកជា ៣ ប្រភេទ គឺ

១.សេចក្តីស្រឡាញ់តាមរបៀបទំនាក់ទំនងខាងភេទ(Eros) គឺសេចក្តីត្រូវការចង់គ្រប់គ្រងលើអ្វីមួយ។ ជាសេចក្តីស្រឡាញ់ដែលមានប្រយោជន៍សម្រាប់មនុស្សជាតិគឺជួយឲ្យយើងអាចបន្តពូជបាន។ សេចក្តីស្រឡាញ់របៀបនេះ យើងអាចឃើញទូទៅក្នុងទិវានៃសេចក្តីស្រឡាញ់។

២.សេចក្តីស្រឡាញ់បែបមិត្តភក្តិ(Philia) គឺសេចក្តីស្រឡាញ់ ដែលកើតឡើងរវាងមនុស្សដែលរស់នៅជាមួយគ្នាក្នុងសង្គម។ សេចក្តីស្រឡាញ់នេះ ជួយឲ្យសង្គមមនុស្សមានទំនាក់ទនង និងមានការអភិវឌ្ឍក្នុងសង្គម។

៣.សេចក្តីស្រឡាញ់បែបមិននឹកដល់ខ្លួន (Agape) សេចក្តីស្រឡាញ់បែបនេះ មិនគិតពីសេចក្តី ត្រូវការឬផលប្រយោជន៍របស់ខ្លួនជាមុនទេ ប៉ុន្តែនឹកដល់សេចក្តីល្អរបស់អ្នកដទៃវិញ។ សេចក្តីស្រឡាញ់បែប agape នេះ យើងឃើញក្នុងជីវិតរបស់ព្រះយេស៊ូ ដែលសុខចិត្តលះបង់ ជួយមនុស្សបាប មនុស្សដែលគ្មានអ្នកណារាប់រក សូម្បីតែជីវិតក៏ហ៊ានលះបង់ដែរ ដើម្បីទទួល កំហុសរបស់មនុស្ស ទោះបីព្រះអង្គមិនបានប្រព្រឹត្តក៏ដោយ។

ក្នុងសៀវភៅ Compendium of the Social Doctrine of the Church បានផ្តល់អត្ថន័យ នៃសេចក្តីស្រឡាញ់បែបគ្រីស្តបរិស័ទក្នុងចំណងជើងថា "សេចក្តីស្រឡាញ់បែបព្រះត្រៃឯក គឺជាប្រភពនិង គោលដៅរបស់មនុស្ស។" ក្នុងលេខ ៣៤ ចាប់ផ្តើមថា "ការបង្ហាញអាថ៌កំបាំងរបស់ព្រះជាម្ចាស់ក្នុងអង្គព្រះគ្រីស្តតាមរបៀបសេចក្តីស្រឡាញ់បែបត្រៃឯក គឺការបង្ហាញការត្រាស់ហៅរបស់មនុស្សទៅកាន់សេចក្តីស្រឡាញ់។" ដូច្នេះអាចនិយាយបានថា ព្រះត្រៃឯក ជាប្រភពនៃសេចក្តីស្រឡាញ់បែបកាតូលិក។

ព្រះយេស៊ូមានព្រះបន្ទូលថា "ខ្ញុំឲ្យវិន័យថ្មីដល់អ្នករាល់គ្នា គឺ ត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។" (យហ.១៣,៣៤) បានជាគ្រីស្តបរិស័ទស្រឡាញ់គេ មិនមែនដោយសារខ្លួនឯងជាប្រភពនៃសេចក្តីស្រឡាញ់ទេ ប៉ុន្តែមានព្រះជាម្ចាស់ជាប្រភពវិញ ហើយការអនុវត្តសេចក្តី ស្រឡាញ់នោះ គឺដូចព្រះយេស៊ូនៅលើឈើឆ្កាង។ ព្រះអង្គអនុវត្តតាមព្រះអង្គបង្រៀនគឺថា "គ្មាននរណា មានសេចក្តីស្រឡាញ់ ខ្លាំងជាងអ្នកដែលស៊ូរប្តូរជីវិត ដើម្បីមិត្តសម្លាញ់របស់ខ្លួននោះឡើយ។" (យហ. ១៥,១៣)

ដូច្នេះ ទិវានៃសេចក្តីស្រឡាញ់ អាចផ្តល់អត្ថន័យ សម្រាប់គ្រីស្តបរិស័ទបាន លុះត្រាតែយើង បានបញ្ចូលអត្ថន័យនៃសេចក្តីស្រឡាញ់តាមបែបព្រះយេស៊ូគ្រីស្ត(agape) និងតាមគំរូដែលព្រះអង្គបានធ្វើ សម្រាប់យើង៕

*រៀបរៀងដោយ លោកពុក រឿង ឆ័ត្រសិរី*



# អង្គការសាមគ្គីធម៌ម៉ារីស្តជាក្តីសង្ឃឹមរបស់ជនពិការកាយសម្បទាន

នៅរសៀលថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧នេះ លោកអភិបាលអូលីវីយេ បានចុះទៅសួរសុខទុក្ខ ដល់ថ្នាក់ដឹកនាំលោកគ្រូអ្នកគ្រូនិងបងប្អូនជនពិការដែលជាសិស្សនិស្សិតរបស់អង្គការសាមគ្គីធម៌ម៉ារីស្តកម្ពុជាប្រមាណជាង២០០នាក់ ស្ថិតនៅក្នុងភូមិព្រែករាំង សង្កាត់កំពង់-សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល។

ថ្លែងនៅក្នុងពិធីសំណេះសំណាលនាឱកាសនោះ លោក អូលីវីយេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ មានប្រសាសថា អង្គការសាមគ្គីធម៌ម៉ារីស្តជាក្តីសង្ឃឹមរបស់ជនពិការកាយសម្បទាន ដូច្នេះនៅក្នុងសាលាឡាវ៉ាឡនេះ កុំឲ្យយើងធ្វើជាមនុស្សដែលមានចិត្តលោភលន់ ប៉ុន្តែឲ្យយើងគិតអំពីជីវិតរបស់យើង ដោយដឹងថាជីវិតរបស់យើងមានសមត្ថភាពខ្ពស់ណាស់ មានកម្លាំងខ្លាំងណាស់ តែសមត្ថភាព និងកម្លាំងនេះ គឺមកពីយើង និងមកពីបងប្អូនឯទៀតៗ ដោយយើងដឹងថាយើងអាចទីពឹងលើគ្នាទៅវិញទៅមក។ លោកអភិបាលក៏បានបន្ថែមទៀតថា យើងជាមនុស្សដែលមានសិទ្ធិសេរីភាព ឲ្យយើងធ្វើយ៉ាងណា ឲ្យជីវិតរបស់យើងទៅជាជីវិតដែលណែនាំឲ្យអ្នកដទៃមានសុភមង្គល និងសេចក្តីសុខសាន្ត។ យើងរួមកម្លាំងគ្នា ដើម្បីឲ្យពិភពលោករបស់យើង ទៅជាពិភពមួយប្រកបដោយសេចក្តីស្រឡាញ់ និងដោយចិត្តមេត្តាករុណា។ លោកក៏បានជូនពរដល់បងប្អូនជនពិការទាំងអស់ថា សូមឲ្យសុបិន្តដែលមាន ទៅជាសេចក្តីពិតនៅថ្ងៃអនាគត ដោយយកចិត្តទុកដាក់រៀនសូត្រ យកចិត្តទុកដាក់បង្កើតទំនាក់ទំនងល្អរវាងគ្នានឹងគ្នាពីពេលនេះតទៅ។

លោកស្រី អ៊ុំ ស្រីណាន ជានាយកសាលាឡាវ៉ាឡា បានឲ្យដឹងថា អង្គការសាមគ្គីធម៌ម៉ារីស្តកម្ពុជាផ្តោតសំខាន់គឺជួយដល់ជនពិការកាយសម្បទានមកទូទាំងប្រទេសកម្ពុជា សព្វថ្ងៃមានកម្មវិធីពីរសំខាន់ៗ គឺទីមួយសាលាបឋមសិក្សាឡាវ៉ាឡា ដែលមានសិស្សកំពុងសិក្សាមានចំនួន១០៣នាក់(ស្រី៣៨នាក់) និងមានបុគ្គលិកសិក្សាចំនួន៤៨នាក់ ទីពីរ ភូមិគ្រឹះនាងម៉ារី ជាមណ្ឌលស្នាក់នៅរបស់សិស្សនិស្សិត ពីថ្នាក់មធ្យមសិក្សារហូតដល់ឧត្តមសិក្សា ដែលមានសិស្ស-និស្សិតកំពុងស្នាក់នៅចំនួន ៩១នាក់។ លោកស្រីបន្ថែមថា វត្តមានរបស់លោកអភិបាលអូលីវីយេ នៅថ្ងៃនេះ ពិតជាបានធ្វើឲ្យអង្គការសាមគ្គីធម៌ម៉ារីស្តទាំងមូលមានភាពកក់ក្តៅ ពីព្រោះលោកបានលើកទឹកចិត្ត និងផ្តល់នូវអនុសាសន៍ល្អៗជាច្រើនដល់បងប្អូនជនពិការយើងខ្ញុំ ឲ្យខិតខំ-តស៊ូទៅមុខទៀត ដើម្បីឲ្យក្តីសង្ឃឹមរបស់ពួកយើងបានសម្រេចនាពេលអនាគត។

គួបញ្ជាក់ផងដែរថា អង្គការសាមគ្គីធម៌ម៉ារី បង្កើត ឡើងដោយក្រុមគ្រួសារបងប្រុស ម៉ារីស្ត តាំងពីឆ្នាំ១៩៩៨ ដែលមានបងប្រុសជនជាតិអូស្ត្រាលីម្នាក់ឈ្មោះ ហៀនរីច ធារី ជាអ្នកដឹកនាំ។ រហូតមកដល់បច្ចុប្បន្នអង្គការនេះ បានជួយជនពិការកាយសម្បទាន បានជាង ៥០០០នាក់ មកហើយ ឲ្យទទួលបានការសិក្សាចំណេះជំនាញផ្សេងៗ ដើម្បីកសាងអនាគតរបស់ពួកគេ។



*ថតដោយ សុធារិទ្ធ*

# ចប់រដូវប្រមូលផលពលរដ្ឋនៅជនបទភាគច្រើនកំពុងតែសម្រុកមកទីក្រុងដើម្បីរកការងារធ្វើ

ចាប់ពីពេលនេះរហូតដល់ខែ ៦ ឬ ៧ ពលរដ្ឋភាគច្រើនធ្វើចំណាកស្រុកពីជនបទមកទីក្រុងដើម្បី ស្វែងរកការងារធ្វើ ដោយការងារនោះមានទាំងពីសំណង់ រត់ម៉ូតូឌុប រត់ម៉ូតូកង់បី ខ្លះជាក់ស៊ីក្លូ ខ្លះ លក់នេះលក់នោះ រួមទាំងនំ នេកផងដែរ ទៅតាមកម្លាំងតាមជំនាញរៀងៗខ្លួន។

លោក ពេញ សាន ជាអ្នកលក់នំមួយរូបនៅរមណីដ្ឋានភ្នំតាម៉ៅ បានឲ្យដឹងថា កូន និងចៅៗរបស់លោកបានចេញមកភ្នំពេញអស់ហើយ ដើម្បីរកការងារធ្វើ។

លោកសាន បានបញ្ជាក់ថា "ពួកគេនាំគ្នីនាំគ្នាមករកការងារធ្វើនៅភ្នំពេញតាំងពីច្រូតហើយ(ខែវិច្ឆិកា)ម្ល៉េះ។ នៅឯផ្ទះឯភូមិ គឺមានតែខ្ញុំ និងចៅតូចៗនៅរៀន"។

បើតាមការអះអាងរបស់លោក នេះមិនមែនជារឿងថ្មីទេ សម្រាប់គ្រួសារលោកសាន និងអ្នកភូមិមួយចំនួន។ ជាទូទៅម្នាក់ៗ ដែលឧស្សាហ៍គឺ ចេះតែខំរកនេះរកនោះទុក បន្ទាប់ពីច្រូតស្រូវហើយ នៅក្នុងខែតុលា ឬវិច្ឆិកានេះ ហើយដល់ពេលរដូវធ្វើស្រែខែឧសភា ឬខែមិថុនា ពួកគេមកវិញហើយ។ លោក បានបន្តថា ពួកគេទៅនោះ មិនមែនទៅមិនមកទេ គឺជួនមួយអាទិត្យអី គេមកអើតផ្ទះម្តងជួនទៅកន្លះខែ។

បងស្រី ជា សាអ៊ីម ជាអ្នកលក់នំ គម នំអន្សមមួយរូបនៅភ្នំពេញបានអះអាងថា បងស្រីមកពី ឃុំ ពពែល ស្រុកត្រាំកក់ខេត្តតាកែវ។ នៅក្នុងមួយឆ្នាំ បងស្រីមកធ្វើនំលក់នៅភ្នំពេញ៥ ទៅ៦ខែដែរ ដើម្បីសន្សំប្រាក់ ទុកឲ្យកូនរៀន និងចាយវាយពេលរដូវធ្វើស្រែយកអង្ករហូប។ បងស្រីបានបន្តថា "នេះហើយរបរអ្នកស្រែដើម្បីរកប្រាក់ចិញ្ចឹមគ្រួសារ"។

បងស្រីបានបន្តថា សម្រាប់អ្នកស្រុកឯទៀតនៅក្នុងភូមិរបស់បងស្រី គឺដូចតែគ្នាទេ គឺម្នាក់ៗខំរៀង ៗខ្លួន ដូចជាស្វាមីរបស់បងស្រី ខែនេះ គឺកំពុងតែរវល់ដើរធ្វើផ្ទះ ធ្វើវិហារឲ្យ គេហើយខ្លះទៅគេជួញមាន់ ខ្លះទៅគេជួញដូង ចេះតែចែកគ្នារកស៊ី ចែកគ្នារស់ទៅ ធ្វើម៉េច បើវាមានដីតិចហើយអត់ទឹកខែប្រាំង ។

លោក ជ័យ យុទ្ធស៊ីម ជាប្រជាពលរដ្ឋនៅស្រុក ស្វាយអន្ទរខេត្ត ស្វាយរៀង ជាអ្នកមករត់រ៉ឺម៉កកង់បីនៅទីក្រុងភ្នំពេញមួយរូបបានបន្តថា "ឥឡូវនេះធ្វើតែស្រែមួយមុខមិនរស់ទេ មានតែឆ្លៀតបានមានស៊ី "។

លោកបានឲ្យដឹងថា ទាល់តែខំ បើមិនតចឹងទេជីវភាពមិនអាចរស់នៅសមរម្យដូចជាគេបានទេ ហើយគ្រួសារក៏យ៉ាប់ដែរ។ លោកបានបន្តថា ពីពេលនេះរហូតដល់ខែភ្លៀង លោករត់រហូត រីឯ ភរិយារបស់លោកគឺគេមកជួយលក់គ្រឿងហូបបងស្រីនៅផ្សារថ្មី ។

លោកបានបញ្ជាក់ថា "ដល់ពេលធ្វើស្រែ ក៏នាំគ្នាជិះទុកៗ (រ៉ឺម៉កម៉ូតូកង់បី) ត្រឡប់ទៅវិញទៅ។ ជីវិតចេះតែខំទៅ ទាន់កូនៗវានៅស្ទើរ មិនទាន់ចេះទារនេះទារនោះច្រើន ហើយវាមិនទាន់ត្រូវការលុយរៀនច្រើន"។

លោកបានបន្តថា អ្នកភូមិរបស់លោកគេក៏នាំគ្នាមករកការងារធ្វើនៅភ្នំពេញដែរ លើកលែងតែអ្នកដែលគេមានរបរនៅស្រុកស្រាប់ និងអ្នកដែលខ្វះលទ្ធភាព ឬខ្ជិល។ មកភ្នំពេញខ្លះធ្វើសន្តិសុខខ្លះ ធ្វើសំណង់ខ្លះតាមលទ្ធភាពរៀងៗខ្លួន។

នេះគឺជាជីវភាពរស់នៅជាទូទៅរបស់ប្រជាពលរដ្ឋកម្ពុជាមួយចំនួននៅតំបន់ជនបទដ៏សមញ្ញ មិនមែនជាអ្នកដែលធ្វើចំការ ឬធ្វើស្រែធំ ដូចជា ចំការកៅស៊ូស្វាយចន្ទី ស្រែ ខណៈដែលពួកគេអាច នឹងជួបព្យុះភ្លៀងខ្លះៗ ពីវិបត្តិនៃការធ្លាក់ថ្លៃ និងគ្មានទីផ្សារកន្លងមកនោះ។

នៅដើមឆ្នាំនេះ ស្ថានភាពអ្នកដែលមានរបរធ្វើកសិកម្ម ជាពិសេសគឺកៅស៊ូអាចនឹងជួបភាពប្រសើរ ឡើងបន្តិចដោយសារតែតម្លៃជ័រ អាចនឹងកើនឡើង ខណៈដែលចំការកៅស៊ូនៅថៃមានវិបត្តិទឹកជំនន់ប្រេងឡើងថ្លៃ ហើយផលិតកម្មដែលត្រូវការជ័រកៅស៊ូធ្វើជាវត្ថុធាតុដើម មានសកម្មភាពឡើងវិញបន្តិច។

លោក វេង សុខុន រដ្ឋមន្ត្រីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទថ្មីៗនេះបានប្រាប់កសិករថា តម្លៃជ័រកៅស៊ូងើបឡើងវិញជាង ២ពាន់ដុល្លារក្នុងមួយតោននេះ ជាសញ្ញាណល្អដែលកសិករត្រូវពង្រឹងដំណាំកៅស៊ូបន្ត។

ដោយឡែកតំឡូងមី ហាក់នៅមានបញ្ហា ហើយតម្លៃក៏កំពុងតែស្រុតចុះ ហើយកសិករ ដែលកំពុងតែ ប្រមូលផល កំពុងតែត្អូញត្អែរ។ តម្លៃដំឡូងមីស្រស់នៅដើមរដូវប្រមូលផលឆ្នាំ២០១៧ នេះ មានតម្លៃត្រឹមពី ១៩០រៀល ដល់២១០រៀលក្នុងមួយគីឡូក្រាមប៉ុណ្ណោះ ដែលនេះជាតម្លៃទាបធ្វើឲ្យកសិករបារម្ភថា ប្រសិនកសិករប្រមូលផលដំឡូង នឹងត្រូវចំណាយខ្ពស់ជាងប្រាក់ចំណូល។

លោក រស់ ហ៊ុន អ្នកដាំដំឡូងមីមួយរូបនៅខេត្តប៉ៃលិន បានអះអាងថា ដើម្បីប្រមូលផលដំឡូងមីមួយតោនត្រូវការចំណាយ មិនក្រោម ៦ ម៉ឺនរៀលដែរ នោះអត់ទាន់គិតថ្លៃដឹកជញ្ជូន ថ្លៃភ្ជួរ ថ្លៃជី ថ្លៃអីផង។

ដោយឡែកអ្នកធ្វើស្រែវិញនៅដើមឆ្នាំនេះ ក៏អាចមានអ្នកដែលមានវិបត្តិរឿងបំណុលធនាគារឬស្ថាប័នមីក្រូហិរញ្ញវត្ថុមិនតិចនោះទេ ដោយសារតែតម្លៃស្រូវបានធ្លាក់ចុះកាលពីរដូវប្រមូលផល កាលពីឆ្នាំទៅថ្មីៗនេះ។

លោក នុប រឿន កសិករនៅស្រុកបាកានខេត្តពោធិសាត់បានឲ្យដឹងថា ឲ្យយើងរំពឹងអី បើយើងធ្វើ ស្រែរំពឹងថា លក់បានស្រូវមួយគីឡូដល់ទៅ ១.១០០រៀល ដល់តែពេលប្រមូលផល លក់បានត្រឹមពី ៧០០ ទៅ ៨០០រៀលហ្នឹង។ *ដោយ អរិយបុត្រ*



*ថតដោយ រិទ្ធី*

# យុវជនក៏បានត្រៀមខ្លួនរួចហើយសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់



ថតដោយ សហការីស៊ីអេសស៊ី

*រូបថត ឯកសារអំពីការពិនិត្យឈ្មោះបោះឆ្នោត ឆ្នាំ២០១៣*

យុវជនភាគច្រើនដែលបានគ្រប់អាយុបោះឆ្នោតបានអះអាងពីការត្រៀមខ្លួនរួចជាស្រេចសម្រាប់ ចូលរួមដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់នាពេលខាងមុខនេះ។

យុវជនម៉េង ស៊ុនហេង មានអាយុ ១៩ឆ្នាំ បានអះអាងថា ប្អូនបានត្រៀមខ្លួនរួច ហើយ សម្រាប់ការបោះឆ្នោតនៅពេលខាងមុខ។

ស៊ុនហេង បានអះអាងបញ្ជាក់ថា "មិនដឹងយ៉ាងម៉េចទេ! តែខ្ញុំបានត្រៀមខ្លួនរួចហើយ ដើម្បីបោះឆ្នោតនៅក្នុងនាមជាពលរដ្ឋពេញច្បាប់ និងជាម្ចាស់សម្លេងមួយរូបនៅក្នុងសង្គម"។

ស៊ុនហេង បានបន្តរៀបរាប់ថា ដំបូងឡើយក៏មិនបានចាប់អារម្មណ៍រឿងបោះឆ្នោតនេះដែរទោះបី ជាដល់អាយុពីព្រោះវាមិនដែលបានបោះ ប៉ុន្តែកាលពីខែ៨ ឬ ៩ ខាងអាជ្ញាធរសង្កាត់ គេបានយក ក្រដាសឈ្មោះមកឲ្យម្តាយនៅឯស្រុក ហៅប្អូន និងប្អូនស្រីប្អូនមួយរូបទៀតដែលកំពុងតែសិក្សានៅភ្នំពេញជាមួយគ្នា ឲ្យទៅចុះឈ្មោះបោះឆ្នោត ហើយក៏បានទៅចុះនឹងគេទាំងពីរតែម្តង ។

ស៊ុនហេង បានបន្តថា "ឈ្មោះខ្ញុំនិងប្អូនគឺយើងមាននៅក្នុងបញ្ជីបោះឆ្នោតហើយ ពោលគឺចាំតែថ្ងៃ បោះតែប៉ុណ្ណោះ"។

ទាក់ទងនឹងអារម្មណ៍នៅក្នុងនាមជាអ្នកដែលមិនដែលបានចូលរួមបោះឆ្នោតនឹងគេពីមុន ស៊ុនហេង បានបន្តថា វាដូចជាគ្មានអ្វីដែលឲ្យភ័យ ឲ្យព្រួយទេ ទោះជាប្អូនមិនដែលបានចូលរួមក៏ដោយ។

ប្អូនបានបញ្ជាក់ថា "មានអីត្រូវភ័យទៀត គ្រាន់តែរឿងបោះឆ្នោតនេះ គេប្រាប់គេបង្រៀនយើង គេរៀបចំឲ្យយើងអស់ហើយ។ ពេលបោះយើងចាំតែទៅការិយាល័យគេ តាមដែលយើងបានចុះ ហើយចូលបន្ទប់សម្ងាត់ រួចគូសលើសន្លឹកឆ្នោតយកសន្លឹកឆ្នោតទៅដាក់នៅក្នុងធុងហឹបឆ្នោត រួចជ្រលក់ទឹកថ្នាំម្រាមដៃចេញមកវិញមក ស្រេចហើយ"។

ស៊ុនហេងបានបន្តទៀតថា អារឿងអស់ហ្នឹងខ្ញុំបានព្យាយាមស្វែងយល់តាំងពី អាយុ ១៥ ទៅ១៦ឆ្នាំម្ល៉េះពោលគឺ តាំងពីបណ្តាសកម្មជនគណបក្សគេចុះទៅពង្រឹងមូលដ្ឋាននៅភូមិស្រុកខ្ញុំ គេចុះទៅបង្រៀនកាលពីការបោះឆ្នោតមុនៗម្ល៉េះ។

ស៊ុយហេង បានបន្តថា កាលពីដំបូងខ្ញុំធុញដែរ ជាពិសេសពេលចុះឈ្មោះ ដោយសារតែពេលនោះ គឺត្រូវចាំយូរមនុស្សច្រើន។

យុវនារី យ៉ាន នីយ៉ារ័ត្ន ដែលមានអាយុ ២១ឆ្នាំ បានថ្លែងថា បើគិតតាំងការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំសង្កាត់នាពេលខាងមុខនេះ កញ្ញា នឹងបានបោះឆ្នោះចំនួនពីរដង។

នីយ៉ារ័ត្ន បានថ្លែងបញ្ជាក់ថា "កាលពី ២០១៣ រៀងភ័យៗដែរ ពីព្រោះខ្ញុំវាមិនដែលបោះនឹងគេកាលនោះ ប៉ុន្តែឥឡូវដូចអត់អី តាំងពីពេលចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្មានថ្ងៃមុននេះបានទៅពិនិត្យឈ្មោះនឹងគេដែរ"។

កញ្ញាបានបញ្ជាក់ទៀតថា "វាគ្មានរឿងអីត្រូវភ័យផង គ្រាន់តែចូលការិយាល័យបោះឆ្នោត ហើយពិនិត្យឈ្មោះ និងគូសសន្លឹកឆ្នោតយកទៅដាក់ហឹបនោះ"។

កញ្ញាបានបន្តថា នៅពេលនោះ បើយើងមិនចេះមិនដឹងអំពីនីតិវិធីរបស់គេមន្ត្រីនៅការិយាល័យនោះ ជួយហើយ។

ហ៊ីន ចំរើន ជាកម្មករសំណង់មួយរូបបានថ្លែងថា គាត់ក៏បានទៅចុះឈ្មោះបោះឆ្នោតនឹងគេរួចហើយដែរ ប៉ុន្តែមិនបានទៅពិនិត្យឈ្មោះអីនឹងគេទេ ព្រោះតែរវល់ ធ្វើការរកលុយនៅភ្នំពេញនេះ។

ចំរើន បានឲ្យដឹងថា ពេលពិនិត្យឈ្មោះនេះ គាត់មិនបានទៅទេ ហើយមិត្តភក្តិមួយចំនួន ដែលមករកការងារធ្វើជាមួយគ្នា ក៏មិនបានទៅពិនិត្យឈ្មោះនៅក្នុងបញ្ជីថ្មីនេះដែរ ប៉ុន្តែនឹងទៅបោះឆ្នោត នៅពេលខាងមុខបើមិនមានបញ្ហាឈ្មោះគាត់ត្រូវគេលុប ឬយ៉ាងណានោះ។

ចំរើនបានអះអាងថា "ពេលចុះឈ្មោះនេះចុះហើយ តែអត់តែពេលពិនិត្យទេ ដោយសារវាអត់លុយ ទៅស្រុកមើលឈ្មោះហ្នឹងគេ"។

លោក អ៊ឹម សុធី នាយកប្រតិបត្តិនៃក្រុមប្រឹក្សាយុវជនកម្ពុជា បានថ្លែងថា នាឆ្នាំ២០១៧នេះ ព្រឹត្តិការណ៍នយោបាយដែលសំខាន់ យើងយុវជនដែលគ្រប់អាយុបោះឆ្នោតត្រូវយកចិត្តទុកដាក់ គឺការចូលរួម បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់នាពេលខាងមុខនេះ។

លោកបានបញ្ជាក់ថា "យុវជនទាំងអស់ត្រូវតែយកចិត្តទុកដាក់ ពីព្រោះយុវជនម្នាក់ក៏ជាសន្លឹកឆ្នោតមួយសន្លឹកតំណាងឲ្យមួយសម្លេងដែរ"។

លោកបានបន្តទៀតថា ខាងក្រុមប្រឹក្សាយុវជនកន្លងមក យើងបានជំរុញ និងចូលរួមយ៉ាងសកម្មដែរ ដើម្បីឲ្យយុវជនចូលរួមសកម្មភាពនយោបាយ និងសង្គមនេះ។

លោកបានបន្តទៀតថា ខាងក្រុមប្រឹក្សាយុវជនក៏មានគម្រោងខ្លះជំរុញឲ្យយុវជនចូលរួម យកចិត្តទុកដាក់នឹងនយោបាយនេះផងដែរ។

កម្ពុជាគ្រោងនឹងរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់នៅក្នុងថ្ងៃទី០៤ មិថុនា ២០១៧នេះ ហើយបន្ទាប់មក នៅឆ្នាំ២០១៨ នឹងរៀបចំការបោះឆ្នោតជាតិជាថ្មីម្តងទៀត។

ពីថ្ងៃទី០៤ ដល់ថ្ងៃទី១៤ ខែមករា នេះ គឺកំពុងតែស្ថិតនៅក្នុងតំណាក់កាលនៃការពិនិត្យផ្ទៀតផ្ទាត់ បញ្ជីបោះឆ្នោតដែលបានចុះរួច។

កាលពីអំឡុងពេលចុះឈ្មោះបោះឆ្នោតនៅក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាទាំងអស់ដែលគ្រប់ អាយុចុះឈ្មោះ គឺបានចុះសរុប ប្រហាក់ប្រហែល ៨ លាននាក់ នៃប្រជាជនសរុបដែលគ្រប់អាយុ ចំនួន ៩,៦ លាននាក់។

*ដោយ អរិយបុត្រ*

# ការសម្រកក្បាលពោះមានប្រយោជន៍ចំពោះសុខភាព



រូបថតពី អ៊ីធឺណែត

នៅក្នុងការរស់នៅ មនុស្សភាគច្រើន អាយុកាន់តែច្រើន ការរីកមាឌទទឹងកាន់តែធំ ដែលយើងតែងហៅថា ដុះក្បាល-ពោះ។ ការឡើងគីឡូនៅជុំវិញក្បាលពោះ មិនមែនគ្មានបញ្ហា ឬមើលឃើញថា ជារឿងធម្មតាៗ នោះទេ។ ខ្លាញ់ក្បាលពោះ នឹងបង្កើនការប្រថុយប្រថាន នឹងការកើនឡើងនូវជំងឺទឹកនោមផ្អែម ចំពោះជំងឺសរសៃឈាមបេះដូង នៅពេលអនាគត។

ខ្លាញ់នៅក្បាលពោះ គឺខុសពីខ្លាញ់នៅចង្កេះ និងភ្លៅ។ តាមប្រភពពត៌មានពីទស្សនាវដ្ដី សាន់តេ (Santé Magazine) បានធ្វើបទសំភាសន៍ជាមួយលោកសាស្ត្រាម៉ាក ឡាហ្វុង តាន នាយកមជ្ឈមណ្ឌលស្រាវជ្រាវសុខភាពនៅប្រទេសបារាំង បានគូសបញ្ជាក់ថា "នៅគ្រប់ការសិក្សាអំពីជំងឺ និងកត្តាបង្ករបស់វា ដែលគេបានធ្វើរយៈពេល ១៥ឆ្នាំមកហើយ បានបង្ហាញថា ការកើនឡើងនូវមាឌជុំវិញក្បាលពោះ មានទំនាក់ទំនងនឹងការកើនឡើងនូវហានិភ័យនៃជំងឺសំយោគសារជាតុក្នុងរាង-កាយ ដូចជា ជំងឺទឹកនោមផ្អែមប្រភេទទី២ និងជំងឺសរសៃឈាមបេះដូងជាដើម"។

តើខ្លាញ់ក្បាលពោះមានប្រតិកម្មយ៉ាងដូចម្តេច?

ផ្ទុយពីស្រទាប់ខ្លាញ់ដែលស្ថិតនៅក្រោមស្បែក ខ្លាញ់ក្បាលពោះមានកម្រាស់ក្រាសក្នុងរាងកាយ និងនៅមិនស្ងៀមនោះទេ។ វាបញ្ជូនទៅក្នុងចរន្តឈាមនូវម៉ូលេគុលផ្សេងៗ ដូចជា អាស៊ីតខ្លាញ់ អ័រមូន និងកត្តាកើនទម្ងន់។ល។ ដែលបន្ទាប់មក វានឹងរាំងដំណើរការដ៏ល្អរបស់សរីរាង្គផ្សេងៗក្នុងរាងកាយ។

បន្តិចម្តងៗ វាបំផ្លាញ នូវសរីរាង្គសំខាន់ៗ។ ការធ្វើតេស្តឈាមបង្ហាញអំពីអត្រាខ្លាញ់គ្លីសេរីដកើនខ្ពស់ និងការកើនឡើងនូវខ្លាញ់គ្លីសេមី (ខ្លាញ់បេះដូង) ទាំងនៅវ័យក្មេង សំពាធឈាមខ្ពស់ អត្រាកូ-ឡេស្តេរ៉ូលល្អ (HDL) មានកម្រិតទាប។ កត្តាទាំងនេះ នឹងប្រឈមការកើតជំងឺទឹកនោមផ្អែម។

លោកសាស្ត្រាចារ្យ ការីន ក្លេម៉ង់ អ្នកឯកទេសជំងឺធ្ងន់នៃវិទ្យាស្ថានបេះដូងសាស្ត្រ និងចំណីអាហារ នៅទីក្រុងប៉ារីស ប្រទេសបារាំង ក៏បានកត់សម្គាល់ថា "បញ្ហាគឺថាខ្លាញ់ក្បាលពោះនេះបានឆ្លងកាត់ដោយសរសៃឈាមដែលទៅចិញ្ចឹមថ្លើម"។ លោកបន្តថាដោយសារការធ្វើចរាចរណ៍របស់ឈាម អាស៊ីតខ្លាញ់ក៏មកដល់ថ្លើម។ អាស៊ីតខ្លាញ់ក៏ធ្វើឲ្យដំណើរការរបស់ថ្លើមមានការលំបាក បន្ទាប់មកវាក៏បង្កបានជាប្រតិកម្មវិលជុំ ទៅបំផ្លាញសរីរាង្គផ្សេងៗទៀត ដូចជា លំពែង សាច់ដុំ និងបេះដូងជាដើម។

ខ្លាញ់ក្បាលពោះបង្កការរលាកកោសិកាការក្នុងរាងកាយ ហើយការរលាកនេះនឹងបង្កឲ្យមានផលវិបាក ដោយសារតែម៉ូលេគុលពុលសាយភាយទៅក្នុងឈាម និងមកដល់ថ្លើម។លោកសាស្ត្រាចារ្យក្លេម៉ង់បានបន្ថែមថា "កត្តារលាកទាំងនេះ បង្កឲ្យមានការប្រឆាំងសារជាតិអាំងស៊ុយលីនដែលចងភ្ជាប់ទៅនឹងជំងឺទឹកនោមផ្អែម និងជំងឺសរសៃឈាមបេះដូង។ ការរលាកនេះក៏បំផ្លាញជីវសាស្ត្ររបស់កោសិកា ដែលនេះគឺអាចពន្យល់អំពីការកើនឡើងនូវហានិភ័យនៃជំងឺមហារីក មានជាអាទិ៍មហារីកសុដនបន្ទាប់ពីស្ត្រីអស់រដូវ"។

*ប្រែសម្រួលដោយ ផាត សំភី*

# បង្ការជំងឺអុតក្តាមលើសត្វគោ

ជំងឺអុតក្តាមបង្កឡើងដោយវីរុសជាច្រើនប្រភេទ ដូចជាប្រភេទ អូ អា និងអាស៊ី១ (O,A,Asia1)។ វីរុសទាំងនេះត្រូវបានរកឃើញថា បង្កជាជំងឺអុតក្តាមនៅប្រទេសកម្ពុជា។ ការប្រើអង់ទីប៊ីយូទិចគ្មានប្រសិទ្ធភាពលើជំងឺនេះទេ។ វីរុសអាចសាយភាយពីជ្រូកទៅគោ ពីព្រោះជ្រូកបញ្ចេញវីរុសច្រើន ហើយគោងាយទទួលនូវការចម្លងតាមខ្យល់ដែលមានមេរោគ។ ការចម្លងដ៏សំខាន់នៃជំងឺនេះ គឺតាមរយៈខ្យល់ដកដង្ហើម ការប៉ះពាល់ផ្ទាល់ជាមួយសត្វឈឺ ការប៉ះពាល់ដោយប្រយោលដូចជាតាមរយៈស្បែកជើង ដៃ និងសម្ភារដែលមានមេរោគ។

សម្រាប់រោគសញ្ញានៃជំងឺអុតក្តាម គឺគោគ្រុនក្តៅ មិនស៊ីចំណី ហូរទឹកមាត់ពងដោរនៅលើអណ្តាត អញ្ចាញ បបូរមាត់ ក្បាលដោះ កន្សោមដោះ និងមានខ្លាញ់នៅគល់ក្រចក និងចង្វែកជើង។

ជំងឺអុតក្តាមបង្កឡើងដោយវីរុសដូច្នេះគ្មានការព្យាបាលទេ។ ការព្យាបាលខាងក្រោម គឺការពារការជ្រៀតចូលរបស់បាក់តេរីផ្សេងទៀតនៅពេលមានអុតក្តាម។

កសិករត្រូវចាក់ទ្រីមេតូព្រីម ស៊ុលហ្វា ឬអុកស៊ីតេត្រាស៊ីគ្លីនរយៈពេល ៥-៧ថ្ងៃ។ កសិករត្រូវលាងដំបៅជាមួយសាប៊ូ សាច់ជូ ឬទឹកម្ជូរ។ កសិករត្រូវបាញ់ថ្នាំសម្លាប់មេរោគដែលមានជាតិ វីយូឡេហ្សង់ត្យាន និងអុកស៊ីតេត្រាស៊ីគ្លី នៅបរិវេណចងគោ និងរោងចិញ្ចឹមគោ។ នៅពេលមានជំងឺ គោមិនអាចដើរស៊ីចំណី និងផឹកទឹកទេ ដូច្នេះកសិករត្រូវផ្តល់ស្មៅ និងកន្ទក់ដល់វា និងចងគោទុកក្នុងម្លប់ដើម្បីកាត់បន្ថយការខ្សោះទឹក។

កសិករគួរចាក់វ៉ាក់សាំងការពារអុតក្តាមប្រភេទ អូ អា និងអាស៊ី១ (O,A,Asia1)។ ថ្នាំទាំងនេះអាចរកទិញបាននៅតាមហាងលក់ថ្នាំសត្វ ឬសួរបសុពេទ្យ។ កសិករចាក់លើកទីមួយនៅពេលគោមានអាយុ ៤ ខែ មួយខែក្រោយមកទៀត កសិករចាក់ជាលើកទីពីរ។ កសិករត្រូវចាក់ថ្នាំនេះជារៀងរាល់៦ខែ។ ប្រសិនបើភូមិនៅជិតនោះមានផ្ទុះជំងឺនេះ កសិករត្រូវស្វែងរកអ្នកជំនាញកសិកម្ម ឬបសុពេទ្យ ដើម្បីប្រឹក្សាយោបល់ ថាគួរចាក់ថ្នាំបង្ការបន្ថែម ឬយ៉ាងណា? ដូច្នេះដើម្បីចិញ្ចឹមគោឲ្យបានទិន្នផលខ្ពស់កសិករត្រូវការការយកចិត្តទុកដាក់ ការដកពិសោធន៍ និងប្រឹក្សាជាមួយអ្នកបច្ចេកទេសជាប្រចាំបន្ថែមទៀត។



ថតដោយ រិទ្ធី

# បណ្តាញសង្គមក្លាយជាវេទិកានយោបាយដ៏សំខាន់នៅកម្ពុជានាឆ្នាំ២០១៦




*រូបថតពីហ្វេសបុក ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី*

បណ្តាញសង្គមនៅកម្ពុជាមានច្រើនប៉ុន្តែកាលពីឆ្នាំ២០១៦ កន្លងទៅនេះ ហ្វេសបុកបានក្លាយជាបណ្តាញសង្គមដ៏ពេញនិយមបំផុតនៅក្នុងប្រទេសកម្ពុជា ដោយមានអ្នកប្រើប្រាស់ជាច្រើនរាប់ទាំង ព្រះមហាក្សត្រ ប្រមុខរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គិតត្រឹមថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ទំព័រហ្វេសបុកដែលគេអាចនឹងងាយស្រួលនៅក្នុងការស្វែងរក ដោយត្រូវវាយអក្សរខ្មែរនៅកន្លែងស្វែងរកថា ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី បានកំពុងតែលេចធ្លោរ។

រហូតមកដល់ពេលនេះ អ្នកនាំសារហាក់មិនទាន់ទទួលព័ត៌មានអំពីការជូនដំណឹងប្រកាសបណ្តាញសង្គមរបស់ព្រះមហាក្សត្រជុំវិញគណនីហ្វេសបុក ដែលមានព្រះនាមព្រះករុណានេះនៅឡើយទេ ប៉ុន្តែគណនីហ្វេសបុកនេះ បានលេចធ្លោឡើងនៅក្រោយពេលដែលព្រះអង្គបានយាងទៅតាមព្រះរាជទីនាំង រថភ្លើង នៅថ្ងៃទី៣០ ធ្នូ យាងទៅខេត្តព្រះសីហនុ។ គណនីហ្វេសបុកនេះអាចនឹងត្រូវបង្កើតឡើងថ្មីៗនេះទេ ប៉ុន្តែក៏កំពុងតែមានអ្នកចុច ឡៃ(Likes) បានចំនួន ៤៣៣.១៨១ ឡៃផងដែរ។ ទំព័រហ្វេសបុកនេះគឺមានសុទ្ធតែរូបភាពដែលជាព្រះរាជសកម្មភាពរបស់ព្រះករុណាទាំងអស់។

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភាជាតិនៃកម្ពុជា ក៏មានគណនីហ្វេសបុកផ្ទាល់ខ្លួនផងដែរ ដោយមានអ្នកចុចឡៃ ចំនួន ៤៣.៩៣៨ ឡៃដែរ។

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានក្លាយជាមេដឹកនាំមួយរូបដែលកំពុងតែប្រើបណ្តាញសង្គមហ្វេសបុកនេះដ៏មានប្រជាប្រិយភាព ដោយហ្វេសបុកផ្លូវការដែលបង្កើតឡើងដោយក្រុមការងារ និងសម្តេចផ្ទាល់បានទទួលការចូលចិត្តសរុបរហូតដល់ទៅ ៦.៥៤៣.២២០ ឡៃ មានទាំងប្រជាពលរដ្ឋខ្មែរ និងបរទេស គិតត្រឹមម៉ោង ៥ព្រឹក ថ្ងៃទី០៣ មករា ២០១៧។ ហ្វេសបុករបស់សម្តេចប្រមុខរដ្ឋាភិបាលកម្ពុជាបានក្លាយជាប្រភពព័ត៌មានដ៏សំខាន់ដែលមនុស្សជាច្រើនបានតាមដាន ជាពិសេសក្រុមអ្នកសារព័ត៌មាន ហើយផ្អែកតាមខ្លឹមសារនោះ ជួនកាលសម្តេចផ្ទាល់ក៏បានចូលរួមចែករំលែកការយល់ឃើញ និងបញ្ចេញយោបល់លើបញ្ហាផ្សេងៗ ហើយមានពេលខ្លះក៏បានចែករំលែកអំពីជីវភាពឯកជនសង្គមគ្រួសារ និងបញ្ហាសុខទុក្ខផ្ទាល់របស់សម្តេច និងក្រុមគ្រួសារផងដែរ។

ដោយឡែកក្រៅពីមេដឹកនាំប្រទេស មេដឹកនាំគណបក្សនយោបាយសំខាន់ៗ ក៏កំពុងតែប្រើប្រាស់បណ្តាញសង្គមនេះយ៉ាងផុលផុសផងដែរ។

លោកសម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិដែលកំពុងតែរស់នៅនិរទេសខ្លួនដោយខ្លួនឯង ដើម្បីគេចចេញពីរឿងនយោបាយដែលបានចាប់អារម្មណ៍ និងជាអ្នកប្រើប្រាស់បណ្តាញសង្គមដ៏ចំណាស់មួយរូបនៅកម្ពុជា ហើយក៏ជាអ្នកសកម្មនៅក្នុងការលេងតាមបណ្តាញសង្គមនេះដែរ។ ទំព័រហ្វេសបុករបស់លោក សម រង្ស៊ី ត្រូវបានគេដឹងថា មានចំនួនអ្នកឡៃ ៣.៥២៨.៨៦៨ ឡៃ។

គណនីហ្វេសបុករបស់លោក គឺនៅតែសកម្ម ហើយ លោក ឧស្សាហ៍ធ្វើសកម្មភាពនយោបាយ ដ៏ប៉ិនប្រសព្វរបស់លោក បន្តធ្វើការរិះគន់ លើកទឹកចិត្តសកម្មជន និងផ្សព្វផ្សាយគោលនយោបាយគណបក្សតាមបណ្តាញសង្គមនេះ។ តាមការសង្កេតពេញមួយឆ្នាំ២០១៦កន្លងទៅ មានពេលខ្លះ លោក ក៏បានផ្តល់បទសម្ភាសន៍ជាមួយនឹងអ្នកសារព័ត៌មានតាមបណ្តាញសង្គមនេះផងដែរ។

លោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ ក៏ជាអ្នកប្រើប្រាស់បណ្តាញសង្គមមួយរូប ដ៏ប៉ិនប្រសព្វផងដែរ បើទោះបីជាចំនួនអ្នកចូលចិត្តឡៃ គឺមានតិចក៏ដោយ។ គិតនៅត្រឹម ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ ម៉ោង៥ ចំនួនឡៃហ្វេសបុកលោក មានត្រឹមតែ ៨៣៧.២៤១ ឡៃប៉ុណ្ណោះ ប៉ុន្តែវាគឺជាបណ្តាញសង្គមមួយដែលលោក និងក្រុមការងាររបស់លោកកំពុងតែ ប្រើប្រាស់ដើម្បីឃោសនាបម្រើសកម្មភាពនយោបាយផ្ទាល់ខ្លួននិងបក្សយ៉ាងរស់រវើក។

ក្រៅពីប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ប្រមុខស្ថាប័ននីតិបញ្ញត្តិ និងអ្នកនយោបាយចេញ នៅតាមបណ្តា ក្រសួងមន្ទីរស្ថាប័នក៏កំពុងតែប្រើប្រាស់បណ្តាញសង្គមនេះ យ៉ាងទូលំទូលាយផងដែរ។

រហូតមកដល់ពេលនេះ បណ្តាស្ថាប័ន និងក្រសួងមន្ទីរនានា គឺមានក្រុមការងារដែលសម្រាប់ បង្កើត និងទទួលព័ត៌មានតាមបណ្តាញសង្គមនេះ។

នៅពេលនេះ ក្រសួងដែលត្រូវបានគេតាមដានច្រើនជាងគេ និងសកម្មជាងគេដែលគេអាចនឹង ផ្តល់ពិន្ទុតាមបណ្តាញសង្គមបាននោះ មានដូចជា ក្រសួងពាណិជ្ជកម្ម ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងបរិស្ថាន ក្រសួងរ៉ែនិងថាមពល ក្រសួងឧស្សាហកម្មនិងសិប្បកម្មជាដើម។

បណ្តាក្រសួងទាំងនេះ បានបន្តលើកទឹកចិត្តឲ្យមន្ត្រីនៅក្រោមឱវាទបន្តបង្កើតបណ្តាញនេះ ដល់កម្រិតថ្នាក់ក្រោមជាតិផងដែរ។

សម្តេចតេជោ ហ៊ុន សែន ថ្មីៗនេះបានជំរុញ និងលើកទឹកចិត្តឲ្យពលរដ្ឋកម្ពុជាក្លាយជាប្រជាពលរដ្ឋអេឡិចត្រូនិច ឬ E-people។

សម្តេចតេជោបានមានប្រសាសន៍ថា កម្ពុជា មិនត្រឹមតែចង់បានត្រឹមតែរដ្ឋាភិបាលអេឡិចត្រូនិច ប៉ុណ្ណោះទេ គឺថែមទាំងចង់បាន E.People។

នៅចុងឆ្នាំមុននេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជាបានថ្លែងថា សម្តេចឈប់ឲ្យធ្វើកម្មវិធីអនក្ខរកម្មកុំព្យូទ័រហើយ ប៉ុន្តែនឹងគាំទ្រកម្មវិធីអក្ខរកម្មប្រព័ន្ធព័ត៌មានបច្ចេកវិទ្យា។

ថ្លែងនៅក្នុងពិធីសម្ពោធអាគារទីស្តីការក្រសួងប្រៃសណីយ៍ថ្មី សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា មិនចាំបាច់ដល់ចេះជ្រៅជ្រះអ្វីនោះទេ គឺត្រឹមតែចេះប្រើស្មាតហ្វូន លើកម្មវិធីបណ្តាញសង្គមមួយចំនួនដូចជា Whatup, lines,... ត្រឹមចេះទទួល កូពី និងបញ្ជូនក៏បានដែរ ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ទោះបីជាប្រភពព័ត៌មាននេះវាមិនផ្លូវការ មិនអាចសម្រេចអ្វីបាន ប៉ុន្តែវាក៏ជួយសម្រួលនៅក្នុងការទទួលព័ត៌មានដែរ ដូច្នេះនៅពេលអនាគត ការតម្លើងតួនាទីមន្ត្រីក៏នឹងអាចពិនិត្យមើលសមត្ថភាពប្រើប្រាស់ប្រព័ន្ធស្មាតហ្វូននេះផងដែរ។

*ដោយ អរិយបុត្រ*

# ក្រុមកម្មករខ្លះនៅចាំព្រឹត្តិការណ៍ថ្ងៃ៣ មករា ឆ្នាំ២០១៤ ខ្លះស្រពេចស្រពិល ខ្លះថាមិនបានដឹង

បើផ្អែកតាមកំណត់ត្រារបស់ក្រុមសហជីពមួយចំនួន និងសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤ ជាព្រឹត្តិការណ៍នៃការបង្ក្រាបការតវ៉ាដោយហិង្សាមួយ ពីសំណាក់អាជ្ញាធរទៅលើក្រុមកម្មករ ប៉ុន្តែ៣ឆ្នាំ ក្រោយមកកម្មករខ្លះនៅចាំ កម្មករខ្លះស្រពេចស្រពិល ខ្លះថា មិនបានដឹងអំពីព្រឹត្តិការណ៍នេះ ។

កញ្ញា អេង រ៉ា ជាកម្មការនីរោងចក្រនៅម្តុំផ្លូវវេងស្រេង បានអះអាង កាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៧ មួយថ្ងៃក្រោយពី ក្រុមកម្មករនិងកម្មការនី សាច់ញាតិជនរងគ្រោះ និងក្រុមអង្គការសង្គមស៊ីវិលមួយចំនួនបានជួបជុំគ្នា រំលឹកខួប៣ឆ្នាំនៃព្រឹត្តិការណ៍បង្ក្រាបដោយហិង្សាទៅលើកម្មករ និងអ្នកតវ៉ានៅលើកំណាត់ផ្លូវវេងស្រេងថា កញ្ញានៅចាំពីព្រឹត្តិការណ៍នេះ ប៉ុន្តែមិនចាំថ្ងៃខែច្បាស់លាស់ទេ ដែលកម្មករមួយចំនួនបានពលីជីវិតដើម្បីការទាមទារតម្លើងប្រាក់ខែនៅពេលនោះ។

កញ្ញាបានបញ្ជាក់ថា "ចាំតើ តែមិនចាំថ្ងៃនៅទិដ្ឋភាពនាថ្ងៃនោះ"។

កញ្ញាបានបន្តថា "ទិដ្ឋភាពពេលនោះគួរឲ្យខ្លាច ខ្ញុំអីមានហ៊ាននៅទីនេះឯណា ឡើងឡានទៅស្រុកវិញបាត់នឹងគេ ក្រោយឃើញហេតុការណ៍បែបនេះ"។ កញ្ញាបានរៀបរាប់ថា នៅពេលនោះ កញ្ញា និងមិត្តភក្តិក៏បានចូលរួមការដើរក្បួន តវ៉ានឹងគេដែរ តែដល់មានហិង្សា ក៏បានរត់ទៅស្រុកជាមួយគេជាមួយឯងទៅ។

កញ្ញាបានបញ្ជាក់ថា "ខ្ញុំមិនចង់ឃើញទិដ្ឋភាពអីចឹងទៀតនោះទេ ឃើញកាន់កាំភ្លើង កាន់ដំបង កាន់ដុំថ្មបាញ់គប់ដាក់គ្នាបែបនេះមិនល្អទេ។

កញ្ញា សេង ចាន់ ជាកម្មការនីរោងចក្រនៅសួនឧស្សាហកម្មកាណាឌីយ៉ា បានឲ្យដឹងថា កញ្ញាមិនបានឃើញទិដ្ឋភាពនេះផ្ទាល់ភ្នែកទេ ដោយសារនៅពេលនោះ កញ្ញាមិនទាន់បានមកកាត់ដេរនៅឡើយ ប៉ុន្តែធ្លាប់ឮកម្មការិនីមិត្តភក្តិរួមការងារនិយាយ និងរំឭកជាហូរហែដែរ។

កញ្ញាបានបញ្ជាក់ថា "កាលណោះខ្ញុំអាយុស្ទើរអត់បានឃើញទេ តែពេលឮគេនិយាយ ខ្ញុំមិនចង់ឃើញទេ"។

កញ្ញា ចេង ណារី ជាកម្មការិនីរោងចក្រកាត់ដេរ នៅម្តុំផ្លូវវេងស្រេងមួយរូបដែរបានបន្ថែមថា គេ (អ្នករួមការងារ) និយាយតែរហូតដែរអំពីថ្ងៃនោះ ប៉ុន្តែគ្មានថ្ងៃ គ្មានខែអីទេ គឺគ្រាន់តែ និយាយពេលទំនេរ ពេលនៅផ្ទះជួល ពេលជិះឡានទៅស្រុកអីហ្នឹង។

កញ្ញាបានបញ្ជាក់ថា "កាលនោះបើតាមខ្ញុំចាំប្រហែលពេលបងស្រីខ្ញុំគាត់មកធ្វើការ ឃើញគាត់ត្រឡប់ទៅផ្ទះ ហើយខ្ញុំចាំថា គាត់និយាយប្រាប់ម៉ែ ហើយឥឡូវគាត់លែងមកហើយ ព្រោះម៉ែគាត់ ចាប់ការប្តី"។

ដោយសារថ្ងៃទី០៣ មករា ២០១៤ ជាថ្ងៃប្រវត្តិសាស្ត្រខ្មៅមួយនៅក្នុងប្រទេស ជាពិសេសនៅក្នុងប្រវត្តិនៃវិស័យឧស្សាហកម្មកាត់ដេរ នៅកម្ពុជា នាព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ២០១៧ កន្លងទៅដែល ជាថ្ងៃខួប ៣ឆ្នាំនៃព្រឹត្តិការណ៍បង្ក្រាបកម្មករ និងអ្នកតវ៉ាដោយហិង្សា ខណៈដែលកម្មករនិងកម្មការិនីបានធ្វើការទាមទារតម្លើងប្រាក់ឈ្នួល ១៦០ដុល្លារ នៅលើកំណាត់ផ្លូវវេងស្រេង ស្ថិតក្នុងខណ្ឌពោធិ៍សែនជ័យ ដោយបណ្តាលឲ្យមានរបួសនិងពលីមួយចំនួននោះ សាច់ញាតិកម្មករដែលបានបាត់បង់ជីវិត ក្រុមអង្គការសង្គមស៊ីវិល ព្រមទាំងព្រះសង្ឃ បានរៀបចំពិធីបង្សុកូលឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធដល់អស់អ្នកស្លាប់នៅផ្ទះសាមគ្គី ស្ថិតក្នុងភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ក្រៅតែអំពីការធ្វើបុណ្យរំឭកវិញ្ញាណក្ខន្ធអ្នកពលី ក៏ជាឱកាសជួបជុំមួយដែររបស់អ្នករងគ្រោះទាំងអស់នៅក្នុងព្រឹត្តិការណ៍ប៉ះទង្គិចរវាងអ្នកតវ៉ា និងកងកម្លាំងនៃកងពលតូចពិសេសផ្ទៃត្រយោងលេខ ៩១១ នៅទល់មុខតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ។

ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ លោក វន់ ពៅ មានប្រសាសន៍ឲ្យដឹងថា ការប្រារព្ធពិធីរំឭកខួប ៣ឆ្នាំ គឺយើងចង់រំឭកនូវការឈឺចាប់របស់យើងចំពោះអាជ្ញាធរនៅក្នុងព្រឹត្តិការណ៍នោះ ដែលបណ្តាលឲ្យមានអ្នកស្លាប់ និងរងរបួសជាច្រើន។

លោកបានបន្តថា រហូតមកដល់ពេលនេះរូបលោកក៏ដូចជាបងប្អូនកម្មករដទៃទៀត ក៏មិនទាន់បានរួចខ្លួនពីបណ្តឹងរបស់តុលាការនៅឡើយទេ បើទោះបីពេលវេលានៃការឈឺចាប់នេះបានកន្លងផុតអស់រយៈពេល៣ឆ្នាំទៅហើយក្តី។ លោក វន់ ពៅ ក៏ស្នើសុំឲ្យរដ្ឋាភិបាលស្វែងរកយុត្តិធម៌ជូនបងប្អូនកម្មករ ដែលបានស្លាប់ រងរបួស និងបាត់ខ្លួនឲ្យបានឆាប់។

លោក ថេង សាវឿន អគ្គលេខាធិការនៃសហព័ន្ធសហគមន៍កសិករកម្ពុជា និងជាអ្នកដែលបានទទួលរងគ្រោះក្នុងព្រឹត្តិការណ៍ថ្ងៃទី០២-០៣ មករា ២០១៤ នោះដែរ បានឲ្យដឹងថា បើគិតរហូតមកដល់ពេលនេះ លោកមិនទាន់ទទួលបានយុត្តិធម៌នៅឡើយ ពីប្រព័ន្ធយុត្តិធម៌ របស់តុលាការកម្ពុជា ក្នុងចំណោមអ្នករងគ្រោះ ហើយត្រូវបានចាប់ដាក់ពន្ធនាគារ ទាំង ២៣នាក់នោះ។ លោកក៏បានទាមទារឲ្យរដ្ឋាភិបាលបញ្ឈប់អំពើហិង្សាគ្រប់ទម្រង់ រូបភាពមកលើកម្មករ កម្មការិនី ក៏ដូចជាបងប្អូនប្រជាពលរដ្ឋខ្មែរ ។

ចំណែកអ្នករងគ្រោះម្នាក់ទៀតលោក ជា សារ៉ាត់ សព្វថ្ងៃមានមុខរបរជាអ្នករត់ម៉ូតូឌុប មានស្រុកកំណើតនៅឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល បានរៀបរាប់អំពីទុក្ខសោករបស់ខ្លួនឲ្យដឹងថា នៅពេលព្រឹត្តិការណ៍នោះកើតឡើង លោករស់នៅម្តុំផ្លូវវេងស្រេង ហើយក្នុងអំឡុងពេលនោះលោកក៏ត្រូវបានចាប់ខ្លួនក្នុងចំណោមបងប្អូនកម្មករទាំង២៣ នាក់ យកទៅដាក់នៅពន្ធនាគារត្រពាំងថ្លុង ខេត្តកំពង់ចាម នាពេលនោះប្រពន្ធរបស់លោកកំពុងមានផ្ទៃពោះ និងគ្មានប្រាក់កាសសម្រាប់ការឆ្លងទន្លេនោះឡើយ។

សូមបញ្ជាក់ថា នៅក្នុងព្រឹត្តិការណ៍បង្ក្រាបថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤នោះ មានកម្មករចំនួន៤នាក់បានស្លាប់ របួសជាង៣០នាក់ និងបាត់ខ្លួនម្នាក់រហូតមកដល់ពេលនេះ ហើយនិងមានការចាប់ខ្លួនយកទៅដាក់ពន្ធនាគារចំនួន២៣នាក់ ដោយឃុំខ្លួនអស់រយៈពេលជាង៥ខែ ព្រមទាំងកាត់ទោសដាក់ពន្ធនាគារពីសំណាក់តុលាការសាលាដំបូង រាជធានីភ្នំពេញក្នុងម្នាក់ៗពី៤ឆ្នាំ ទៅ៤ឆ្នាំកន្លះ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន៨លានរៀល ប៉ុន្តែបច្ចុប្បន្នពួកគេកំពុងតែព្យួរទោស។

*ដោយ អរិយបុត្រ*



ថតដោយ ឡុង សម្ផស្ស

## ថៃដើមឆ្នាំរងគ្រោះខ្លាំងព្រោះភ្លៀងដោយសារបម្រែបម្រួលអាកាសធាតុ

ប្រទេសថៃនៅដើមឆ្នាំ ពេល គឺនៅអំឡុងដើមខែមករា បានប្រឈម ការលំបាកខ្លាំងដោយសារតែគ្រោះ ទឹកជំនន់ខុសរដូវដែលបានឆក់យកជីវិតមនុស្សអស់៤០នាក់ ដំណាំចំការកៅស៊ូរាប់សិបហិចតា។

លោក ឆាតឆៃ ប្រូមលឹត ប្រធាននាយកដ្ឋានបង្ការនិងសម្រាលគ្រោះមហន្តរាយថៃ បានអះអាងថា ភ្លៀងជាប់នៅរដូវប្រាំងនេះបង្កការជន់លិចនៅទូទាំងភាគខាងត្បូង ដោយកាត់ផ្តាច់ផ្លូវថ្នល់ ផ្លូវដែក បំផ្លាញដំណាំនិងប៉ះពាល់មនុស្សប្រមាណ ១,៦លាននាក់។

លោក ឆាតឆៃ បានប្រាប់អ្នកសារព័ត៌មានថា នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៧ ស្ថានការណ៍អាក្រក់បំផុតនៅមិនទាន់កន្លងផុតនៅឡើយទេ។

រដូវវស្សានៅថៃតាមធម្មតា គឺនៅចន្លោះខែមិថុនាដល់វិច្ឆិកាហើយទឹកជំនន់ដែលបានចាប់ផ្តើមកាលពីថ្ងៃ០១ មករា បានកើតឡើងបន្ទាប់ពីការធ្លាក់ភ្លៀងខ្លាំងខុសរដូវមិនធម្មតា។ តំបន់ដែលរងគ្រោះនោះ ត្រូវបានគេដឹងថា ជាប្រភពផលិតជ័រកៅស៊ូធម្មជាតិដ៏សំខាន់បំផុតសម្រាប់ពិភពលោក ។

អាជ្ញាធរកៅស៊ូជាតិថៃ បាននិយាយថា ទិន្នផលនៅឆ្នាំ២០១៦-២០១៧ ទាបជាងផែន ការ១០%ដោយសារតែជំនន់ពេលនេះ រីឯថ្លៃជ័រនៅលើផ្សារពិភពលោកក៏កើនឡើងដោយសារតែផលប៉ះពាល់នេះ។

## វិស័យសំណង់នៅកម្ពុជារីកចម្រើនជាមួយនឹងកំណើនដ៏ខ្ពស់

វិស័យសំណង់នៅកម្ពុជាកាលពីឆ្នាំ២០១៦ បានទាក់ទាញទុនវិនិយោគមានតម្លៃសរុបរហូតដល់ទៅ ៨.៥៣៤ លានដុល្លារ។

ប្រភពពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានឲ្យដឹងថា ទំហំវិនិយោគដែលមានទឹកប្រាក់ ៨.៥៣៤ លានដុល្លារនេះ គឺមានកំណើនកើនឡើងប្រមាណជា ១៥៥,៦៨ ភាគរយធៀបនឹង ឆ្នាំ២០១៥ កន្លងទៅ ។

ប្រភពបានបន្តថា នៅទូទាំងប្រទេសមានគម្រោងសាងសង់ចំនួន ២.៦៣៦ គំរោង នៅលើផ្ទៃក្រឡាជាង១៤លានម៉ែត្រការ៉េ ត្រូវបានអនុម័ត ដោយកាលពីឆ្នាំ២០១៥ ការគំរោងសាងសង់ដែលបានអនុម័តមានចំនួនតែ២.៣០៥គំរោងលើផ្ទៃក្រឡាត្រឹមតែជាង៧លានម៉ែត្រការ៉េ និងទុនវិនិយោគចំនួន ៣.៣៣៨លានដុល្លារ តែប៉ុណ្ណោះ ។

វិស័យសំណង់ត្រូវបានគេដឹងថា គឺជាសសរស្តម្ភមួយនៃកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមួយនឹង វិស័យ កសិកម្ម ទេសចរណ៍ និងការនាំចេញ ។

## វៀតណាម ប្រកាសផ្តល់រង្វាន់ដល់អ្នករកដំណោះស្រាយរឿងកកស្ទះចរាចរណ៍ឃើញ

អាជ្ញាធរវៀតណាមនៅក្នុងក្រុងហាណូយបានប្រកាសផ្តល់ប្រាក់រង្វាន់រហូតដល់ទៅ ២០០.០០០ ដុល្លារ ដល់អ្នកដែលអាចរកវិធីដោះស្រាយបញ្ហាការកកស្ទះចរាចរណ៍នៅក្នុងទីក្រុងដ៏មមាញឹកនេះបាន ។

អាជ្ញាធរក្នុងទីក្រុង បានប្រកាសស្វែងរកមតិយោបល់ពីសាធារណជនយ៉ាងបើកចំហរដើម្បីដោះស្រាយការកកស្ទះចរាចរណ៍កាន់តែខ្លាំងឡើង នៅពេល ដែលទីក្រុងនេះ មិនអាចទប់ស្កាត់ការកើនឡើងយ៉ាងលឿននូវចំនួនយានជំនិះនៅក្នុងទីក្រុងបាន។

នាយកដ្ឋានដឹកជញ្ជូនសាធារណៈនៃទីក្រុងហាណូយបានរៀបចំការប្រកួតប្រជែងមួយ កាលពីថ្ងៃ ទី១២ខែមករាដើម្បីស្វែងរកដំណោះស្រាយពីសាធារណជនសម្រាប់ដោះស្រាយបញ្ហាការកកស្ទះចរាចរណ៍កាន់តែខ្លាំងឡើងរបស់ខ្លួននេះ។ ស្ថាប័នជំនាញនេះ បានស្នើឱ្យក្រុមអ្នកចូលរួមប្រកួតប្រជែងផ្តោតគំនិតលើបញ្ហាចំណតរថយន្តនៅក្រោមដី ប្រព័ន្ធដឹកជញ្ជូនងាយ និងមានប្រសិទ្ធភាពព្រមទាំងរបៀបនៃការគ្រប់គ្រងយានជំនិះផ្ទាល់ខ្លួននៅទីក្រុងមួយនេះ ដែលមានម៉ូតូដ៏ច្រើន។

ទីក្រុងហាណូយ ត្រូវបានគេដឹងថា គឺជាទីក្រុងដ៏មមាញឹកបំផុតមួយនៅតំបន់អាស៊ីអគ្នេយ៍នេះ។

ការប្រកួតប្រជែងនេះ នឹងចាប់ផ្តើមពីថ្ងៃទី១៩-២៣ មករា ជាមួយនឹងប្រាក់រង្វាន់ ២០០.០០០ដុល្លារ និងប្រាក់លើកទឹកចិត្តបន្ថែមចំនួន ១០០.០០០ដុល្លារ៕

## រដ្ឋាភិបាល និងក្រុមហ៊ុន ប្រកាសចេញគម្រោង លំនៅដ្ឋានតម្លៃថោកជូន មន្ត្រីរាជការ

នៅដើមខែមករា ឆ្នាំ២០១៧ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់សហការជាមួយនឹងក្រុមហ៊ុនឯកជន បានប្រកាសផ្តល់ជូននូវគម្រោង សាងសង់លំនៅដ្ឋានសាធារណៈ ជាលើកដំបូង។

គម្រោង លំនៅដ្ឋានសាធារណៈនេះមាន ចំនួន២.២៩៦ផ្ទះ នៅលើផ្ទៃដី២០ហិកតា ក្នុងចំណោមផ្ទៃដីដែលបានបំរុងទុកចំនួន៤៥ហិកតានៅចម្ងាយប្រមាណ ៥គីឡូម៉ែត្រពីក្រុងតាខ្មៅ តាមបណ្តោយផ្លូវជាតិលេខ២២១។

លោក សៀ រិទ្ធី អគ្គនាយកក្រុមហ៊ុនដែលចាប់ដៃគូអនុវត្តគម្រោងនេះបានថ្លែងថា ប្រជាពលរដ្ឋក្រីក្រពិតប្រាកដអាចទិញបានតាមរយៈការដាក់ចេញលក្ខខ័ណ្ឌជាច្រើនដូចជា ការបង់រំលោះត្រឹម ១ខែ ៨០ដុល្លារសម្រាប់រយៈពេល២០ឆ្នាំ ការទិញលំនៅដ្ឋាននេះតម្រូវឲ្យម្ចាស់ស្នាក់នៅរយៈពេល៥ឆ្នាំនិងសម្រាប់ប្រជាពលរដ្ឋមានប្រាក់ចំណូលចាប់ពី៥០០ដុល្លារចុះក្រោម។

គម្រោងនេះត្រូវបានបើកការដ្ឋានដោយ លោក ជា សុផារ៉ា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។

## ប្រមុខរដ្ឋាភិបាលកម្ពុជាជំរុញឲ្យអ្នកសារព័ត៌មានគោរពវិជ្ជាជីវៈ

នៅក្នុងពិធីជួបជុំជាមួយនឹងអ្នកសារព័ត៌មានកាលពីថ្ងៃទី១៤ មករា ២០១៧ កន្លងទៅនេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានជំរុញឲ្យអ្នកសារព័ត៌មានលើកកំពស់វិជ្ជាជីវៈ តាមគន្លងនៃផ្លូវប្រជាធិបតេយ្យ។

នៅក្នុងពិធីនោះ ប្រមុខរដ្ឋាភិបាលកម្ពុជា បានធ្វើការរិះគន់ដល់អ្នកធ្វើអត្ថាធិប្បាយតាមប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានមួយចំនួន ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងនៅមុខអ្នកសារព័ត៌មានប្រមាណជាជាង ១០០០នាក់ថា អ្នកសារព័ត៌មានមួយចំនួនបានធ្វើការងារលើសពីវិជ្ជាជីវៈសារព័ត៌មាន ។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា "អ្នកសារព័ត៌មានដែលឆ្លាតត្រូវសរសេរ និងវិភាគតែពីការពិត ហើយរហ័ស និងត្រឹមត្រូវ មិនមែនផ្អូម... ហើយសូមកុំខ្លាចការផ្សាយ។ ប្រសិនបើមានកំហុសសូមកុំស្ទាក់ស្ទើរនៅក្នុងការកែតម្រូវ ហើយសូមកុំប្តូរព័ត៌មានជាមួយនឹង ផលប្រយោជន៍"។

នៅក្នុងនាមជាមេដឹកនាំដែលស្ថិតនៅក្នុងអំណាចយូរជាងគេនៅអាស៊ីអគ្នេយ៍ សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា គ្មានមេដឹកនាំណានៅលើពិភពលោក ដែលជួបអ្នកកាសែតច្រើនជាងសម្តេចនោះទេ ដោយសារតែអ្នកឯងទៀត កាន់អំណាចខ្លីៗ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា នៅលើពិភពលោកនេះ មិនមានមេដឹកនាំពិភពលោកណា ជួបជាមួយនឹងអ្នកកាសែតច្រើនជាងខ្ញុំនោះទេ។ នៅក្នុងរយៈពេល ៣៨ឆ្នាំ តាំងពីត្រូវតែងតាំងជារដ្ឋមន្ត្រីការបរទេស ឧបនាយករដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីជូនកាលខ្ញុំត្រូវចំណាយពេល រាប់សិបម៉ោងជាមួយនឹងអ្នកសារព័ត៌មាន ។

នាឱកាសនោះ សម្តេចតេជោ ហ៊ុន សែន ក៏បានជំរុញឲ្យក្រសួងព័ត៌មានសហការជាមួយនឹង អាជ្ញាធរ អភិបាលខេត្ត រាជធានី ពង្រឹងនិងជំរុញឲ្យមានអ្នកនាំពាក្យដើម្បីទំនាក់ទំនងជាមួយនឹងអ្នកសារព័ត៌មាន។

នាឱកាសនោះ សម្តេចតេជោ ហ៊ុន សែន ក៏បានសន្យាថា នឹងជួបជាមួយនឹងអ្នកសារព័ត៌មាន ពី ៣០០០ ទៅ៤០០០ នាក់ នៅថ្ងៃដែលឆ្នាំក្រោយ ។

នាឱកាសនោះ លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានឲ្យដឹងថា នៅកម្ពុជាមានកាសែត ទស្សនាវដ្តី ព្រឹត្តិប័ត្រសរុប ប្រមាណជា ៨០០ ស្ថាប័ន ៧០ ស្ថាប័នផ្សព្វផ្សាយអនឡាញ ទូរទស្សន៍២២ ស្ថានីយវិទ្យុមានចំនួន ៣៣០ស្ថានីយ និងសមាគមអ្នកកាសែត ៣៨។

# សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ លើកទឹកចិត្តព្រះសហគ



ថ្វីត្បិតតែជាព្រះសហគមន៍តូចពីរនៅលើពិភពលោក ប៉ុន្តែសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានវាយតម្លៃខ្ពស់អំពីការរីកចម្រើន និង សម្តែងការគាំទ្រដល់គ្រប់សកម្មភាពរបស់ព្រះសហគមន៍កាតូលិកនៅក្នុងប្រទេសទាំងពីរ។ នេះបើតាមសេចក្តីរាយការណ៍តាមបណ្តាញសង្គមពីសំណាក់លោក អូលីវីយេ ជ្មឹតអីស្ល៊ែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញនៅក្នុងអំឡុងពេលស្នាក់នៅ និងបំពេញទស្សនកិច្ចនៅក្នុងបុរីវ៉ាទីកង់ កាលពីចុងខែមករា ឆ្នាំ២០១៧ កន្លងទៅថ្មីៗនេះ។

លោកអភិបាលបានចែករំលែកថា ការចូលគាល់ជាមួយសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូដោយផ្ទាល់ និងក្រុមលោកអភិបាលនៃព្រះសហគមន៍កាតូលិកនៃប្រទេសកម្ពុជា និងឡាវ កាលពីថ្ងៃទី២៦ មករា សម្តេចប៉ាបបានសំដែងការគាំទ្រចំពោះព្រះសហគមន៍ទាំងពីរ ។

លោកអភិបាលបានបញ្ជាក់ថា "ថ្ងៃទីបួនត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី២៦ ខែមករា ឆ្នាំ២០១៧ ជាពេលវេលាដ៏ល្អប្រសើរបំផុត ព្រោះក្រុមលោកអភិបាលនៃព្រះសហគមន៍កាតូលិកកម្ពុជា និងឡាវ បានអញ្ជើញចូលគាល់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូដោយផ្ទាល់ ដែលព្រះអង្គទ្រង់ស្វាគមន៍ក្រុមលោកអភិបាលទាំងពីរប្រទេសនៅម៉ោង១១ព្រឹករហូតដល់ម៉ោង១២ និង ៣០នាទីរសៀល"។

លោកអភិបាលបានបន្តទៀតថា ក្រុមលោកអភិបាលឡាវ-កម្ពុជាក៏បាន ចែកបទពិសោធន៍នៃព្រះសហគមន៍ក្នុងប្រទេសឡាវ-កម្ពុជា ថ្វាយសម្តេចប៉ាបទ្រង់ព្រះសណ្តាប់ផងដែរ។

នៅក្នុងជំនួបនោះ លោក អូលីវីយេ បានបន្តថា សម្តេចប៉ាបមានព្រះហឫទ័យរីករាយដោយសារតែសក្ខីភាពអំពីព្រះវិហារដ៏តូច ដែលជាព្រះវិហារធ្លាប់ជួបទុក្ខលំបាក និងព្រះវិហារមិនមានជីវិត។

លោកអភិបាលបានបញ្ជាក់ថា "សម្តេចប៉ាបបានមានបន្ទូលធានាយើងអំពីភាពជិតស្និទ្ធនៃព្រះសហគមន៍ និងស្នើសុំយើងឲ្យមានចិត្តក្លាហាន ដើម្បីបន្តការប្រកាសដំណឹងល្អជាភាសាសមស្រប សម្រាប់មនុស្សទាំងអស់នៅប្រទេសកម្ពុជា និង ឡាវ ពោលគឺភាសាពោរពេញដោយសេចក្តីស្រឡាញ់ និងមេត្តាករុណា។ ព្រះអង្គបានប្រទានព្រះពរដល់យើងទាំងអស់ ហើយមានបន្ទូលថា "ដើរឆ្ពោះទៅមុខ !" ។

លោកអភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបាន ចេញដំណើរឆ្ពោះទៅបុរីវ៉ាទីកង់ ដើម្បីសួរសុខទុក្ខសម្តេចប៉ាប និងសម្តែងការគួរសម រួមជាមួយលោកអភិបាលទាំងអស់នៅប្រទេសឡាវ និងកម្ពុជា កាលពីថ្ងៃទី២១ មករា ២០១៧។ នេះគឺជាដំណើរដែល ក្រុមលោកអភិបាលនៃព្រះសហគមន៍ឡាវ និងកម្ពុជា ចូលគាល់សម្តេចប៉ាបជារៀងរាល់១០ឆ្នាំម្តង ដើម្បីជំរាបជូនសម្តេចប៉ាប អំពីស្ថានភាព សេចក្តីត្រូវការនានា របស់ព្រះសហគមន៍កាតូលិកនៃប្រទេសទាំងពីរ។

នៅថ្ងៃទី២៣ ខែមករា ដែលជាថ្ងៃទី១ នៃដំណើរទស្សនកិច្ចជាផ្លូវការរបស់ក្រុម លោកអភិបាលព្រះសហគមន៍កាតូលិក ឡាវ-កម្ពុជា នៅបុរីវ៉ាទីកង់បានចាប់ផ្តើមដោយ ពិធីអរព្រះគុណព្រះជាម្ចាស់នៅផ្នូររបស់សន្ត សិលា។ នាថ្ងៃនោះ លោកអភិបាលទាំងអស់បានអធិដ្ឋានសម្រាប់សម្តេចប៉ាប និងសម្រាប់គ្រីស្តបរិស័ទទាំងនៅកម្ពុជា និងឡាវ។ បន្ទាប់មកក៏បានចូលសារនៅការនៅក្រសួងអប់រំកាតូលិក។

បន្ទាប់មកនៅថ្ងៃទី២នៃដំណើរទស្សនកិច្ចផ្លូវការនៅបុរីវ៉ាទីកង់ ក្រុមលោកអភិបាលឡាវ និងកម្ពុជា បានជួបពិភាក្សាជាមួយលោក កាឌីណាល់ ហ្វីឡូនី ទទួលបន្ទុកលើក្រសួងប្រកាសដំណឹងល្អ។ នៅក្នុងជំនួបនោះលោកកាឌីណាល់ បានជំរុញឲ្យក្រុមលោកអភិបាល ទាំងអស់ធ្វើជាព្យាការី ដែលជាសញ្ញារួមគ្នាជាធ្លុងតែមួយ និង ប្រកាសដំណឹងល្អ ដោយចែករំលែកនូវសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណា។

នៅថ្ងៃដដែល វេលាថ្ងៃត្រង់ លោកអភិបាល អូលីវីយេ ក៏បានអញ្ជើញទៅសួរសុខទុក្ខ ប្រធានធំនៃក្រុមគ្រួសារបងស្រីដូមីនីក នៅរ៉ូម ដែលក្រុមនេះមានបងស្រីមួយចំនួនបម្រើនៅព្រះសហគមន៍កំពង់សោម។ ហើយក្រុមលោកអភិបាលបានបញ្ចប់កម្មវិធីនៅថ្ងៃនោះ ដោយពិធីអរព្រះគុណព្រះជាម្ចាស់ និងទទួលទានអាហារពេលល្ងាចនៅនិវេសនដ្ឋាន ពីមេ (PIME)

## លោកអភិបាលអូលីវីយេ ចែករំលែកសក្ខីភាព

លោកអូលីវីយេ ជ្មឹតអីស្ល៊ែរ អភិបាល នៃព្រះសហគមន៍កាតូលិកភូមិភាគ ភ្នំពេញ បានចែករំលែកអំពី សក្ខីភាពនៃដំណើរទស្សនកិច្ចដ៏មានអត្ថន័យនៅបុរីវ៉ាទីកង់។

លោកអភិបាលបានជម្រាបថា ដំណើរនេះ គឺមានរយៈពេល ពេញមួយ សប្តាហ៍ ដោយយើងចាប់ផ្តើម ពីពិធីថ្វាយអភិបូជានៅផ្នូររបស់ សន្តសិលាតែម្តង និងក្រោយមក យើងបានទស្សនកិច្ចនៅតាមក្រសួងមួយចំនួន ដែលសម្តេចប៉ាបមាន ប៉ុន្តែដោយសារតែក្រសួងច្រើន ក្រសួងដែលយើងបានទៅទស្សនកិច្ចនោះ គឺមានក្រសួងប្រកាសដំណឹងល្អ ក្រសួងអន្តរសាសនា ជាមួយនឹងក្រសួងគ្រួសារ ក្រសួងអភិវឌ្ឍន៍មនុស្ស ក្រសួងផ្សព្វផ្សាយព័ត៌មាន និងក្រសួងអប់រំកាតូលិកជាដើម។

លោកអភិបាលបានបន្តថា យើងបានចែកបទពិសោធន៍អំពីជីវិតរបស់ព្រះសហគមន៍។ ទោះបីជាយើងជាព្រះសហគមន៍តូច តែយើងបានចែករំលែកអំពីជីវិតយុវជន ជីវិតកូនក្មេង ជាពិសេសគឺរបៀបដែលយើងបានយកចិត្តទុកដាក់ ប្រកាស ដំណឹងល្អដូចជា ការប្រកាសដំណឹងល្អតាមការសាកសួរសុខទុក្ខ។

លោកអភិបាលបន្តមានប្រសាសន៍ថា "នៅទីនោះគេមានការភ្ញាក់ផ្អើលនឹងព្រះសហគមន៍យើងដែរ ដោយសារតែយើងប្រកាសដំណឹងល្អតាមវិធីតូចតាច តែយើងមានជីវិត "។

លោកអភិបាលបានថ្លែងទៀតថា នៅពេលនោះយើងមានឱកាសបានជួបសម្តេចប៉ាបផ្ទាល់រយៈពេលមួយម៉ោងកន្លះ។ យើង

# គមន៍កាតូលិកនៅកម្ពុជានិងនៅប្រទេសឡាវ



ក្នុងក្រុងរ៉ូម។

នៅថ្ងៃទី២៥ ខែមករា ក្រុមលោកអភិបាលទាំងអស់នៃព្រះសហគមន៍កម្ពុជា និងឡាវ ក៏បានចូលរួមសវការសាធារណៈជាមួយសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ និងបងប្អូនអ្នកមានជំនឿមកពីជុំវិញពិភពលោក ដោយនៅក្នុងឱកាសនោះ សម្តេចប៉ាបបានជំរុញ សូមឲ្យយើងទាំងអស់គ្នាត្រូវមានសេចក្តីសង្ឃឹមគ្រប់ពេលវេលា។

បន្ទាប់មកនៅរសៀលថ្ងៃនេះ ក្រុមលោកអភិបាលក៏បានទៅជួបសារនាការការងារនៅលេខាធិការដ្ឋាន នៃក្រសួងសារគមនាគមន៍ ហើយលោក អូលីវីយេ ក៏បានបង្ហាញជូននូវកិច្ចការរបស់ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកកម្ពុជា។

លោកអូលីវីយេ បានបញ្ជាក់ថា "ក្រោយពីបានស្តាប់របាយការណ៍ពួកគេរីករាយ និងចាប់អារម្មណ៍យ៉ាងខ្លាំង ហើយសន្យានឹងជួយយើង លើការបណ្តុះបណ្តាលបន្ថែម។ អរគុណការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកកម្ពុជា ចំពោះការសម្រេចបាននូវលទ្ធផលល្អៗជាច្រើន"។

លោកបានបញ្ជាក់ទៀតថា "នាថ្ងៃនោះខ្ញុំបានទៅអធិដ្ឋានក្នុងវិហារសន្តសិលា នៅត្រង់ផ្នូរសន្តយ៉ូហានប៉ូលទី២ និងសន្តយ៉ូហានទី២៣ ដោយអធិដ្ឋានសម្រាប់បងប្អូនទាំងអស់គ្នា"។

នាថ្ងៃអាទិត្យ ទី២៩ ខែមករាដែលជាថ្ងៃនេះ ថ្ងៃសេរីភាព ក្រុមលោកអភិបាលនៃព្រះសហគមន៍ នៅប្រទេសទាំងពីរ បានទៅចូលរួមការប្រារព្ធពិធីថ្វាយអភិបូជាថ្ងៃអាទិត្យនៅ សាន ឡូរ៉េនហ្សូ។ ហើយក៏បានទៅទស្សនាវិមានបាស៊ីលីកា និងកន្លែង ដែលបានទទួលការតែងតាំងជាមរណសាក្សី ឌីខុន ឡូរ៉េនហ្សូ បន្ទាប់ពីលោកត្រូវបានដុតនៅលើចង្អើរនៅសតវត្សទីពីរ។ នៅក្នុងឱកាសនេះ ក្រុមលោកអភិបាលក៏បានប្រារព្ធខួបកំណើតលោកបូជាចារ្យអូលីវីយេ ដែលក្លាយជាឧបដ្ឋាកប្រចាំការ ៣០ឆ្នាំកន្លងទៅ ហើយលោកអភិបាលអូលីវីយេក៏ បានធ្វើធម្មទេសនានិងបម្រើពិធីថ្វាយអភិបូជានោះ។

នៅក្នុងអំឡុងពេលស្នាក់នៅក្នុងទីក្រុងរ៉ូម ដើម្បីទស្សនកិច្ចនៅបុរីវ៉ាទីកង់នេះ ក្រុមលោកអភិបាលឡាវ កម្ពុជា ក៏បានធ្វើទស្សនកិច្ចនៅស្ថាប័នថ្មីផ្នែកអភិវឌ្ឍធនធានមនុស្ស ដោយនៅពេលនោះ ក្រុមលោកអភិបាលក៏មាន ឱកាសដ៏វិសេសក្នុងការចែករំលែកបទពិសោធន៍ជាច្រើនអំពីការអភិវឌ្ឍន៍នេះ នៅប្រទេសកម្ពុជា។ ហើយក៏បានទៅទស្សនកិច្ចកន្លែងបញ្ចុះសពស្អាតបំផុតរបស់ សន្តព្រីស៊ីឡា ជាមួយនឹងការបង្ហាញខ្លួនលើកដំបូងនៃព្រះនាងម៉ារីកាលពីឆ្នាំ(២២០)។

លោកអភិបាលភូមិភាគភ្នំពេញក៏បានថ្លែងថា បន្ទាប់មកនៅថ្ងៃទី៣០ ខែមករា ជាថ្ងៃប្រវត្តិសាស្ត្រ ជាថ្មីនៃព្រះសហគមន៍កាតូលិករបស់ប្រទេសទាំងពីរ ដោយមានឱកាសចូលរួមពិធីថ្វាយអភិបូជា ដោយផ្ទាល់ជាមួយនឹង សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ នៅមហាវិសាលវិហារ សានតា ម៉ាថា ។

ក្រៅពីនោះ ក្រុមលោកអភិបាលកម្ពុជា និងឡាវ ក៏បានចូលរួមពិធីថ្វាយអភិបូជាបិទទស្សនកិច្ចនេះនៅព្រះវិហារសន្តប៉ូល។

លោកអូលីវីយេ បានបញ្ជាក់នៅក្នុងសារតាមបណ្តាញសង្គមថា "យើងបានអរព្រះគុណព្រះជាម្ចាស់សម្រាប់ការអស្ចារ្យយ៉ាងនេះក្នុងការរួបរួមជាធ្លុងតែមួយ ជាមួយព្រះបិតា ជាមួយព្រះវិហារសកលលោក និងក្នុងចំណោមយើងក្នុងឋានៈជាលោកអភិបាលនៅកម្ពុជា និងឡាវ។ យើងបានអធិដ្ឋានឲ្យបងប្អូន ហើយទូលសុំព្រះជាម្ចាស់ ឲ្យប្រទានព្រះពរដល់បងប្អូនទាំងអស់ និងប្រទានឲ្យយើងមានថាមពលដូចគ្នានឹងសន្តប៉ូល ដើម្បីប្រកាសដំណឹងល្អ! សូមព្រះជាម្ចាស់ប្រទានព្រះពរដល់បងប្អូនទាំងអស់នៅក្នុងអំណរសប្បាយ និងសន្តិភាព។

នៅក្នុងថ្ងៃចុងក្រោយនោះដែរ នៅម៉ោង ១២ ក្រុមលោកអភិបាលឡាវ កម្ពុជា បានធ្វើទស្សនកិច្ចចុងក្រោយទៅកាន់សភាសម្តេចប៉ាបផ្នែក សន្ទនាអន្តរសាសនា។ នេះជាឱកាសដ៏ល្អដើម្បីបង្ហាញខ្លួន ហើយក្រុមលោកអភិបាលព្យាយាមពិភាក្សាអំពីរឿងរ៉ាវជីវិត កិច្ចសន្ទនាជាមួយពុទ្ធសាសនានៅកម្ពុជាផងដែរ ហើយកបានធ្វើទស្សនកិច្ចជាឯកជនទៅកាន់សារមន្ទីរនៃបុរីវ៉ាទីកង់ និងវិហារអធិដ្ឋានតូចស៊ិចស្ទីន។

នាឱកាសនោះសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ក៏បានទទួលស្វាគមន៍ លោកអភិបាល អូលីវីយេ និងឪពុកម្តាយរបស់លោកអភិបាលផងដែរ។ *ដោយ អរិយបុត្រ*

## ជាក់ស្តែងក្នុងដំណើរទស្សនកិច្ចនៅបុរីវ៉ាទីកង់

បានរួមគ្នា ចែករំលែកអំពីជីវិតព្រះសហគមន៍របស់យើងជូនដល់សម្តេចប៉ាប បានជ្រាប ជាពិសេសគឺព្រះសហគមន៍របស់យើងដែលបានបាត់បង់ទាំងអស់ នៅសម័យ ប៉ុលពត និង១០ឆ្នាំក្រោយមក ក៏អត់ទាន់មានអីសោះ ហើយនៅពេលនោះយើងបានខិតខំជម្រាបសម្តេចប៉ាបអំពីរបៀបដែលយើងបានខិតខំកសាងព្រះសហគមន៍ ដោយយើងមានគ្រីស្តទូតជាច្រើននាក់ ហើយឡាវ គឺមានសុទ្ធតែជាជនជាតិឡាវ។ យើងក៏បានជម្រាបសម្តេចប៉ាបថា យើងកំពុងតែមានជីវិតនៅក្នុងសង្គមមួយ ដែលមាន ពុទ្ធបរិស័ទច្រើនដែលសព្វថ្ងៃគឺកំពុងតែគិតអំពីអភិវឌ្ឍន៍ និងរឿងលោកិយ ច្រើនជាងជីវិតព្រះជាម្ចាស់ ។

លោកអភិបាលបានបញ្ជាក់ថា "នៅពេលនោះ ខ្ញុំបានជម្រាបជូនសម្តេចប៉ាបថា ព្រះសហគមន៍នៅកម្ពុជារីក ចម្រើន តែយើងអត់មានវិសាលវិហារ តែយើងទៅ(ពី)វិហារមួយទៅវិហារមួយ ដែលជាវិសាលវិហាររបស់យើង។ ពេលឮបែបនោះ សម្តេចប៉ាបលោក សប្បាយចិត្ត និងបាន តបមកពួកយើងថា សូមមានចិត្តអត់ធ្មត់។ ហើយជាពិសេសនៅពេលដែលយើង បានចូលរួមពិធីថ្វាយអភិបូជាជាមួយនឹងសម្តេចប៉ាប គឺលោកបានលើកឡើងអំពីព្រះសហគមន៍ដ៏តូចតាច តែជាព្រះសហគមន៍ ដែលរស់រវើក។ សម្តេចប៉ាបបានលើកទឹកចិត្តយើងដើម្បីបន្តប្រកាសដំណឹងល្អ"។

# ៣៨ ឆ្នាំមុន ជាមេរៀនប្រវត្តិសាស្ត្រមួយត

ថ្វីត្បិតតែមានការរិះគន់ខ្លះទៅលើថ្ងៃ៧ មករា ប៉ុន្តែជារួមយុវជនខ្មែរបានចាត់ទុកថា នោះគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ សម្រាប់ទុកជាការដាស់សតិពួកគេ និងអ្នកជំនាន់ក្រោយដើម្បី បញ្ចៀសបញ្ហាទាំងនោះទៀត។

យុវជន ម៉េង ហៀង ដែលបានអះអាងថា ជានិស្សិតឆ្នាំបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាប័ត្រ អក្សរសាស្ត្រអង់គ្លេសមួយរូប បានថ្លែងថា តាមពិតទៅគាត់កើតមិនទាន់ថ្ងៃជ័យជំនះ ៧ មករា ១៩៧៩ ទេតែប្អូនឮប្រជាពលរដ្ឋខ្មែរជាពិសេសឮតា និងយាយ របស់គាត់និយាយប្រាប់ថាជាថ្ងៃនេះជាកំណើតទីពីរ របស់ពួកគាត់ ម្យ៉ាងវិញទៀតក៏មានអ្នកខ្លះបាននិយាយថា ជាថ្ងៃនោះជាថ្ងៃដែល វៀតណាម ចូលស្រុកខ្មែរផងដែរ។

ហៀង បានបញ្ជាក់ថា "លោកតា លោកយាយ ខ្ញុំគាត់និយាយថា ប្រសិនបើគ្មានថ្ងៃនោះ (៧ មករា ១៩៧៩) ខ្ញុំ ប្រហែលមិនមែនជាចៅរបស់គាត់ទេ តែអាចជាចៅរបស់អង្គការ (របបខ្មែរក្រហម)"។

ហៀងបានបន្តថា ឪពុកម្តាយគាត់ គឺជាក្មេងដែលកើតកាលពីសម័យនោះ គាត់មិនចាំរឿងទាំងនោះទេ ប៉ុន្តែលោកតា លោកយាយគាត់ថា វេទនាណាស់ ហើយគាត់ក៏មិនបានមើលថែទាំកូនៗ ដូចឪពុកម្តាយរបស់គាត់ដែលកើតនៅសម័យនេះដែរ។

ហៀងបានបញ្ជាក់ថា "តាមដែលខ្ញុំចាំលោកតា ធ្លាប់និយាយថា ឪពុកខ្ញុំ ដែលកាលនោះ មានអាយុ ប្រហែលជា៣ ឆ្នាំស្បែកដណ្តប់ឆ្អឹងពេលឈឺរងារ គាត់មិនបានមើលថែទេ ដោយសារតែ អង្គការ មិនឲ្យ តែសំណាងហើយ បាន ៧ មករាទាន់ ទើបអាចគាត់ធំធាត់ហើយមានខ្ញុំ មានប្អូនខ្ញុំបន្តទៀតនោះ"។

ទន្ទឹមនឹងអ្វីដែល ជីដូន ជីតា របស់ហៀង បាននិយាយ នោះ ហៀង ក៏បានទទួលព័ត៌មាន តាមបណ្តាញសង្គម តាមវិទ្យុខ្លះៗថា ថ្ងៃនេះជាថ្ងៃដែលជនជាតិវៀតណាម បានចូលមកលុកលុយប្រទេសកម្ពុជា។

ហៀង បានបញ្ជាក់ថា "កាលពីថ្ងៃ៧ មករា នោះ ខ្ញុំបានអានសារ បានឮ បានស្តាប់វិទ្យុ មួយចំនួន ពីវីដេអូអនឡាញពីសារនៅលើបណ្តាញសង្គម ដោយអ្នកខ្លះរិះគន់ថា ថ្ងៃនោះ គឺជាថ្ងៃដែលវៀត-ណាម បានចូលមកគ្រប់គ្រងនិងឈ្លានពានខ្មែរ ប៉ុន្តែតាមការអាន និងបៀបធៀបគ្នា ខ្ញុំអាចស្វែងយល់ថា វត្តមានរបស់ពួក




គេ គឺជាការមកជួយខ្មែរជារឿងដែលមិនអាចប្រកែកបាន ទោះបីជាការជួយនេះវាមានហេតុផលអ្វីផ្សេង ក៏ដោយ។

យុវតីមួយរូបដែលកំពុងស្ថិតនៅមុខបណ្ណាល័យជាតិ កញ្ញា ដេត បញ្ញានី បានថ្លែងថា ចង់អ្នកណាយល់ យ៉ាងម៉េច គឺជារឿងរបស់គេម្នាក់ៗប៉ុន្តែសំខាន់ប្រវត្តិសាស្ត្រ គឺប្រវត្តិសាស្ត្រ។

កញ្ញាបានបន្តថា "អ្នកដែលថា ៧ មករាជាថ្ងៃរំដោះក៏ត្រឹមត្រូវ ហើយអ្នកដែលរិះគន់ថា វៀតណាមមកឈ្លានពាន ក៏ពួកគេគិតថាមិនខុសដែរ ដោយសារតែគេមានការអះអាងរបស់គេរៀងៗខ្លួន ប៉ុន្តែសំខាន់យើងត្រូវតែដឹងប្រវត្តិសាស្ត្រ "។

កញ្ញាបានបញ្ជាក់ថា "សម្រាប់ខ្ញុំ ចង់នរណាខុសនរណាត្រូវមិនសំខាន់ទេ សំខាន់ គឺការបញ្ចប់របបដឹកនាំមួយដែលសម្លាប់មនុស្ស សម្លាប់សេដ្ឋកិច្ច បំផ្លាញប្រទេស ហើយបំបិទសិទ្ធិសេរីភាពរបស់មនុស្សជាតិ"។

កញ្ញា បានបន្តថា ៧ មករា ជាថ្ងៃដែលធ្វើអោយកម្ពុជា ប្រែក្លាយមុខមាត់ថ្មី ដែលត្រូវបានទទួលស្គាល់ពីសំណាក់អន្តរជាតិ និងជាថ្ងៃដែលផ្តល់សេរីភាព ដល់ពលរដ្ឋកម្ពុជា។ កញ្ញា បន្ថែមថា ៧ មករា អាចនៅតែជាចម្ងល់មួយ សម្រាប់ពិភពលោក និងប្រជាជនយ៉ាងណាក៏ដោយ កញ្ញនៅតែប្រកាន់ភាពវិជ្ជមានចំពោះទស្សនៈ នៃថ្ងៃ៧ មករា នេះដដែល។

ស្ថិតនៅជុំវិញ អត្ថន័យនៃថ្ងៃ ៧ មករា ១៩៧៩ នេះ លោក ជា សូខុម ជាបុគ្គលិកក្រុមហ៊ុនឯកជនមួយ បានលើកឡើងថា ថ្វីបើលោក កើតមិនទាន់ ថ្ងៃ៧ មករា ១៩៧៩ នេះមែន ប៉ុន្តែ លោកបានដឹងតាមរយៈសៀវភៅ និងការដំណាលប្រាប់របស់ចាស់ៗ។

លោក សូខុម បានរៀបរាប់ជាថ្មីថា ថ្ងៃ៧ មករា ជាថ្ងៃដែល កងទ័ពរណសិរ្សសាមគ្គីរំដោះជាតិ បានមកធ្វើការវាយផ្តួលរំលំ របបប្រល័យពូជសាសន៍ ដោយមានការជួយឧបត្ថម្ភទាំងស្មារតី និងសម្ភារ ពីសំណាក់កងទ័ពនិងប្រជាជនវៀតណាម និងជាថ្ងៃដែលផ្តល់នូវសេរីភាព រួចផុតពីការកាប់សំលាប់របស់នេះ។

លោកបញ្ជាក់ថា "ខ្ញុំគិតថា បើសិនជារបបខ្មែរក្រហមបន្តដឹកនាំដល់ឥឡូវ ប្រទេសកម្ពុជាមិនដឹងយ៉ាងណាទេ បើក្រោយ៧ មករា គេរកឃើញតែឆ្អឹង ឃើញតែភាព-តក់ស្លុត រន្ធត់តែរហូតមកនោះ"។

អ្នកនាង គង់ ច័ន្ទសេដ្ឋា ជានិស្សិតបញ្ចប់ផ្នែកវេជ្ជសាស្ត្រមួយរូប បានឲ្យដឹងថា អ្នកនាង មានទស្សនៈចំពោះថ្ងៃ៧ មករា ១៩៧៩នេះ ជាថ្ងៃដែល ក្រុមគ្រួសារអ្នកនាង ជាពិសេសឪពុកម្តាយ និងជីដូនជីតារបស់អ្នកនាង បានរួចរស់រានមានជីវិត និងជាថ្ងៃដែលអនុញ្ញាត្តអោយ អ្នកនាង បានសិក្សារៀនសូត្រ ព្រមទាំងអាចប្រកបរបរអាជីវកម្មបាន។

ថ្វីត្បិតតែថ្ងៃ៧ មករា ១៩៧៩ បានកន្លងផុតទៅ ៣៨ឆ្នាំមកតែវាហាក់នៅថ្មីៗ សំរាប់ពលរដ្ឋកម្ពុជាគ្រប់រូបជាពិសេស គឺចាស់ៗ និងអ្នកដែលបានហែលឆ្លងរបបនោះ។ ពួកគេអាចនៅតែជិតជាមក្នុងចិត្តស្ទើរតែមិនអាចបំភ្លេចបាន។

លោក បណ្ឌិត សភាចារ្យ ស៊ន សំណាង ទីប្រឹក្សា រាជរដ្ឋាភិបាលកម្ពុជា និងជាប្រធានសមាគម អ្នកប្រវត្តិសាស្ត្រកម្ពុជាបានប្រាប់អ្នកសារព័ត៌មានអោយដឹងថា ថ្ងៃ៧ មករា ១៩៧៩ ជាថ្ងៃប្រវត្តិសាស្ត្រ របស់កម្ពុជា

# សម្រាប់ដាស់សតិអ្នកជំនាន់ក្រោយ




*រូបថតពី AKP*

ដែលបានរួចផុតពីសំណាក់របបខ្មៅងងឹត របស់ខ្មែរក្រហម និងជាថ្ងៃដែលបង្ហាញអំពីការ សាមគ្គីភាពរបស់ប្រជាពលរដ្ឋកម្ពុជា ដែលបានរួបរួមគ្នា ធ្វើការផ្តួលរំលំរបបប្រល័យពូជសាសន៍ នៅកម្ពុជា។

លោក បណ្ឌិតសភាចារ្យ បានបន្តទៀតថា ថ្ងៃ៧ ខែមករា នេះ បានសបញ្ជាក់ពីវីរៈភាពនៃប្រជាជនកម្ពុជានាសម័យនោះ ដែលបូជាជីវិត សំរាប់ជាតិ និងប្រជាជន។ ពិតណាស់ ៧ មករា ១៩៧៩ ជាថ្ងៃបើកទំព័រប្រវត្តិសាស្ត្រថ្មី ដែលកម្ពុជា ធ្លាក់ក្នុងជ្រោះមរណៈមកជាការអភិវឌ្ឍស្ទើរគ្រប់វិស័យនៅពេលបច្ចុប្បន្ន។

ថ្ងៃ៧ មករា នេះ មានអ្នកនយោបាយ និងប្រជាពលរដ្ឋកម្ពុជាមួយចំនួនមានគំនិត និងការយល់ឃើញផ្សេងទៅតាមការរិះគិតរបស់ពួកគេ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នៅរៀងរាល់ថ្ងៃនេះ គណបក្សប្រជាជនកម្ពុជា ដែលកំពុងតែដឹកនាំប្រទេស បានបន្តប្រារព្ធពិធីរំលឹក និងអបអរព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះជាបន្តបន្ទាប់ ហើយក៏បានទទួលស្គាល់ថ្ងៃនោះជាថ្ងៃឈប់សម្រាកជាសាធារណៈមួយថ្ងៃ ថែមទៀត ។

នេត ចរិយា ជាយុវនារីមួយរូបដែលបានចូលរួមកំសាន្តសប្បាយនៅក្នុងកម្មវិធីកំសាន្តកាលពី រាត្រីថ្ងៃទី៧ មករា នៅកោះពេជ្រ បានថ្លែងថា គ្មាននរណាមិនចាំថាថ្ងៃនេះ (៧ មករា )ជាថ្ងៃស្អីនោះទេ ដោយសារតែគេរៀបចំពិធីនេះតែហូតតាំងពីទីក្រុងដល់ខេត្តដល់ស្រុកថែមទៀត។

កញ្ញាបានបញ្ជាក់ថា "កាលនៅស្រុកក៏ធ្លាប់ត្រូវបានគេហៅទៅចូលរួម ស្តាប់គេនិយាយអំពីថ្ងៃទី៧ មករា នេះដែរ"។

ហេង ស៊ីនឿន ជាយុវជនមួយរូបផ្សេងទៀតដែលកំពុងតែមើលកម្មវិធីនៅក្បែរនោះដែរ បាននិយាយ ប្រាប់អ្នកនាំសារថា "នរណាក៏ដឹងដែរបងថ្ងៃនេះ បើគេរៀបចំតែរាល់ឆ្នាំ តែពេលនេះសប្បាយ កុំនិយាយកុំសួររឿងពីមុនអីបង។ ស៊ីនឿន បានបន្តថា ៣៨ឆ្នាំហើយរឿងនេះវាក្លាយទៅ ជារឿងប្រវត្តិសាស្ត្រហើយ ចង់ដឹងចង់ស្វែងយល់អាចទៅអានសៀវភៅបាន ឯកសារមិនខ្វះទេ មានតែគ្រប់កន្លែងហ្នឹង ។

*ដោយ អរិយបុត្រ*

## ប្រមុខរដ្ឋាភិបាលកម្ពុជា៖ ស្មារតីជ័យជម្នះ៧មករាស្ថិតស្ថេរ និងរស់រវើកជានិច្ច

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណបក្សប្រជាជនកម្ពុជាបានថ្លែងថា ស្មារតីជ័យជម្នះ ៧ មករា ស្ថិតស្ថេរ និងរស់រវើកជានិច្ចក្នុងដួងចិត្តរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់ៗរូប។

ក្នុងពិធីប្រជុំព្រឹកខួបលើកទី៣៨ នៃទិវាជ័យជម្នះ ៧ មករា នៅទីស្នាក់ការកណ្តាលគណបក្សប្រជាជនកម្ពុជា ស្ថិតក្នុងខណ្ឌចំការមន រាជធានីភ្នំពេញ ដែលមានអ្នកចូលរួមប្រមាណ១ម៉ឺននាក់ សម្តេចតេជោថ្លែងថា ឆ្លងកាត់រយៈពេល ៣៨ឆ្នាំមកនេះ ផ្តើមពីជ័យជម្នះ៧មករា ប្រទេសកម្ពុជាបាននិងកំពុងឈានទៅមុខតាមទិសដៅដ៏ត្រឹមត្រូវស្របតាមបំណងប្រាថ្នាដ៏ពិសិដ្ឋ របស់ប្រជាជន និងដើរស្របជាមួយនិន្នាការរួមក្នុងតំបន់ក៏ដូចពិភពលោក ទោះបីជាត្រូវជួបនិងភាពបត់បែនយ៉ាងច្រើនក្តី ដូចជាកម្ពុជាពីមុនដែលជាវាលពិឃាត ជាតំបន់អសន្តិសុខ ជាចម្ការមីន ឥឡូវបានក្លាយទៅជា ទឹកដីសន្តិភាព និងជាតំបន់ទេសចរណ៍មួយប្រកបដោយប្រជាប្រិយភាពក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលទទួល បានភ្ញៀវទេសចររាប់លាននាក់ក្នុងមួយឆ្នាំៗ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា "កម្ពុជាពីមុន ដែលតែងតែប្រើអាវុធដើម្បីដណ្តើមអំណាចគ្នា ឥឡូវបានក្លាយទៅជាប្រទេសមួយដែលគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នៃលទ្ធិប្រជាធិតេយ្យ សេរីពហុបក្ស តាមរយៈការរៀបចំយ៉ាងទៀងទាត់ នូវការបោះឆ្នោតដោយសេរីត្រឹមត្រូវ និងយុត្តិធម៌"។

## គណបក្សកាន់អំណាចប្រកាសគោលជំហរនយោបាយជាថ្មីម្តងទៀតប្រឆាំងនឹង សកម្មភាពប្រទូសរ៉ាយ ជាថ្មី

គណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សកាន់អំណាចនៅក្នុងប្រទេស បានប្រកាសបញ្ជូនសារជាថ្មីអំពី ការប្រឆាំងដាច់ខាតនូវរាល់សកម្មភាព ប្រទូស៉ាយ ដែលអាចធ្វើឱ្យប្រទេសបែកបាក់គ្នាជាថ្មី។

នេះជាសារនយោបាយ ដែលប្រកាសដោយសម្តេចតេជោ ហ៊ុន សែន ប្រធានគណបក្សប្រជាជនកម្ពុជាកាលពីថ្ងៃទី០៧ ខែមករា។

គណបក្សនេះក៏បានប្រកាសប្រកាន់ខ្ជាប់នូវស្មារតី បង្រួបបង្រួមជាតិ និង គោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ហើយក៏ខិតខំសម្របសម្រួលដោះស្រាយនូវទស្សនៈខុសៗគ្នាក្នុងសង្គមដោយភាពអត់ធ្មត់ យោគយល់អធ្យាស្រ័យគ្នា និងអហិង្សា និងឈរ លើមូលដ្ឋានគោរពអនុវត្តន៍ច្បាប់យ៉ាងម៉ឺងម៉ាត់។

សម្តេចតេជោ ហ៊ុន សែន គណបក្សប្រជាជនកម្ពុជាសូមការពារជាដាច់ខាតនូវឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី ការពាររដ្ឋធម្មនុញ្ញ របបរាជានិយម និងរាល់សមិទ្ធផលរបស់សង្គមជាតិ ជាពិសេស ថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឱ្យបានរឹងមាំឥតរង្គោះរង្គើរ ដែលជាកត្តាសារវន្ត ដើម្បីធានាដល់ដំណើរការរីកចម្រើននៃលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ធានាការអភិវឌ្ឍ ប្រកបដោយចីរភាព និងសមធម៌ និងធានានូវជីវភាពរស់នៅដ៏សុខសាន្តរបស់ប្រជាជន តែប្រឆាំងនឹងសកម្មភាពណាមួយពីខាងក្រៅ ដែលព្យាយាមដាក់ការគៀបសង្កត់មកលើរាជរដ្ឋាភិបាលកម្ពុជាឱ្យធ្វើតាមឆន្ទៈរបស់ខ្លួននៅក្រោមហេតុផលប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដែលជាការជ្រៀតជ្រែកមកលើដែនសមត្ថកិច្ចរបស់រដ្ឋអធិបតេយ្យមួយ បំពានលើគោលការណ៍ជាសកល។

# លោកអូលីវីយេជំរុញគ្រីស្តបរិស័ទ ឲ្យធ្វើបដិវត្ត ដោយកសាងវប្បធម៌នៃសេចក្តីស្រឡាញ់



ថតដោយ សុធារិទ្ធ

លោកអភិបាលអូលីវីយេមានប្រសាសន៍ថា ព្រះជាម្ចាស់បានត្រាស់ហៅយើង ឲ្យធ្វើបដិវត្ត ដោយប្រមូលផ្តុំកម្លាំងទាំងអស់គ្នា កសាងវប្បធម៌នៃសេចក្តីស្រឡាញ់។ លោកអភិបាល បានមានប្រសាសន៍ដូច្នេះ ក្នុងធម្មទេសនា នៅថ្ងៃបុណ្យអបអរសាទរព្រះយេស៊ូប្រសូត ថ្ងៃទី២៤ ធ្នូ ២០១៦ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល នៃព្រះសហគមន៍កាតូលិកភ្នំពេញថ្មី ដែលមានគ្រីស្តបរិស័ទចូលរួមយ៉ាងច្រើនកុះករ។ លោកបន្តថា បដិវត្តនេះត្រូវចាប់ផ្តើមពីម្នាក់ៗផ្ទាល់ខ្លួន និងបងប្អូនឯទៀតៗ។ លោកថា ព្រះជាម្ចាស់ត្រាស់ហៅបងប្អូនឲ្យបន្ត សកម្មភាពព្រះហឫទ័យប្រណីសន្តោស និងមេត្តាករុណា នៃឆ្នាំមហាករុណាទិគុណឲ្យដុះឡើង ដែលជាប្រភពនៃការកសាងសន្តិភាពក្នុងដួងចិត្តយើងរបស់ម្នាក់ៗ ក៏ដូចជាក្នុងពិភពលោកទាំងមូល។ នៅក្នុងធម្មទេសនា លោកអភិបាលអូលីវីយេ ក៏បាននាំឲ្យបងប្អូនរិះគិតថា តើនរណាធំជាងគេ? ក្នុងពិភពលោក ក្នុងប្រទេស ក្នុងព្រះសហគមន៍ និងក្នុងផ្លូវជំនឿ។ តាមជំនឿគឺ ព្រះជាម្ចាស់ ជាព្រះបង្កើតអ្វីៗទាំងអស់ និងមានឫទ្ធានុភាពសព្វប្រការ។ ព្រះអម្ចាស់មានអំណាច លើសអ្វីៗទាំងអស់។ ព្រះអង្គមានព្រះជន្មគង់នៅជានិច្ច។ ព្រះអង្គស្រឡាញ់ មនុស្សរហូតចាត់ព្រះបុត្រា ឲ្យកើតជាមនុស្ស។ ព្រះអង្គប្រសូតមក គ្មានអំណាច គ្មានទ្រព្យសម្បត្តិអ្វីទាំងអស់។ លោកអភិបាលថា "យប់នេះព្រះអង្គគង់នៅជាមួយយើង និងគង់ក្នុងចំណោមយើង"។ ក្នុងនោះលោកអភិបាលអូលីវីយេក៏បាន បង្ហាញសក្ខីភាពខ្លះៗអំពីវត្តមានរបស់ព្រះម្ចាស់ក្នុងស្នាមញញឹមរបស់បងប្អូន ដែលមានលោកបានជួប ដែលបញ្ជាក់អំពីវត្តមានរបស់ព្រះអង្គ តាមរយៈកិច្ចការមេត្តាករុណារបស់ព្រះសហគមន៍។ លោកអភិបាលថា ក្នុងពិភពលោកនេះ មានសង្គ្រាមសម្លាប់គ្នា មានការស្អប់គ្នា សងសឹកគ្នា និងភាពលោភលន់។ ក្នុងព្រះសហគមន៍ក៏ដូចគ្នាដែរ ជួនកាលយើងមានចិត្តចង្អៀតចង្អល់ ប្រណែនគ្នា ស្អប់គ្នា ជិះជាន់គ្នា មើលងាយអ្នកដទៃ មានអំនួតខ្លាំងជាដើម។ យប់នេះព្រះជាម្ចាស់ បានកើតជាមនុស្ស កែប្រែពិភពលោក ព្រមទាំងកែប្រែយើងទាំងអស់គ្នាដែរ។ សូមឲ្យបងប្អូន បើកភ្នែក បើកត្រចៀក បើកចិត្តទទួលស្វាគមន៍ អ្នកតូចតាច អ្នកគ្មានទីពឹង អ្នកអស់សង្ឃឹម អ្នកខ្វះសេចក្តីស្រឡាញ់... ដោយសេចក្តីកក់ក្តៅបំផុត។ លោកអភិបាលបន្តថា យើងត្រូវកសាងសេចក្តីសុខសាន្តក្នុងគ្រួសារ និងក្នុងសង្គម ព្រោះព្រះជាម្ចាស់ត្រាស់ហៅយើងម្នាក់ៗយ៉ាងពិតប្រាកដ ឲ្យកសាងវប្បធម៌នៃសេចក្តីប្រណីសន្តោស និងធម៌មេត្តាករុណា។ យប់នេះពិតជាពេលវេលាមួយដែលពោរពេញដោយអំណរសប្បាយយ៉ាងពិតប្រាកដ ព្រោះព្រះជាម្ចាស់បានកើតជាមនុស្សជាង២០០០ឆ្នាំហើយ។ យប់នេះយើងរួមជាមួយទេវទូតទាំងឡាយច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ។ នៅថ្ងៃទី២៤ ខែធ្នូ រាល់ឆ្នាំ ព្រះសហគមន៍កាតូលិកនៅកម្ពុជាគ្រប់ទីកន្លែងបានប្រារព្ធបុណ្យព្រះយេស៊ូប្រសូតយ៉ាងសប្បាយរីករាយ។ ព្រះសហគមន៍កាតូលិកនៅកម្ពុជាមានព្រះវិហារ ចំនួនប្រមាណជិតមួយរយកន្លែងមានគ្រីស្តបរិស័ទប្រមាណជាងពីរម៉ឺននាក់។ ព្រះសហគមន៍កាតូលិកបានចែកចេញជាបីភូមិភាគធំៗ គឺបាត់ដំបងគ្រប់ដណ្តប់ខេត្ត ភាគខាងជើង និងពាយព្យ ភូមិភាគកំពង់ចាម គ្រប់ដណ្តប់ខេត្ត ភាគឦសាន និងខាងកើត និងព្រះសហគមន៍ភូមិភាគភ្នំពេញគ្រប់ដណ្តប់ខេត្តភាគខាងត្បូង និងនិរតី។ ព្រះសហគមន៍កាតូលិកនៅកម្ពុជាបានចូលរួមយ៉ាងសកម្មភាពក្នុងការរួមចំណែក បម្រើប្រជាជនក្រីក្រ ជនពិការ កុមារកំព្រា អ្នកជំងឺ ចាស់ជរា និងអភិវឌ្ឍសង្គមកម្ពុជា តាមរយៈការអភិវឌ្ឍធនធានមនុស្ស ក្នុងវិស័យអប់រំ ចំណេះដឹងទូទៅ និងជំនាញ ព្រមទាំងបានបង្កើតការងារសម្រាប់ប្រជាជនផងដែរ។

# ព្រះជាម្ចាស់គង់ជាមួយយើង

កុមារាកុមារី ប្រមាណជាង៣០០០នាក់ មកពីភូមិនានា បានមកជួបជុំ គ្នានៅព្រះវិហារសន្តីម៉ារីញញឹម នៃភូមិចំការទៀង ស្រុកត្រាំកក់ ខេត្តតាកែវ ដើម្បីចូលរួមអបអរសាទរបុណ្យព្រះយេស៊ូប្រសូត។ ការជួបជុំដ៏ឱឡារិកនេះ បានប្រព្រឹត្តទៅកាលពីថ្ងៃទី២៥ ខែធ្នូកន្លងទៅ ក្រោមអធិបតីភាពលោកអូលីវីយេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។

កុមារទាំងនោះ មកពីភូមិនានា ជុំវិញភូមិចំការទៀង និងពីភូមិចំការទៀង គេបានស្គាល់ព្រះសហគមន៍កាតូលិក ដោយសារសកម្មភាពនានា របស់ព្រះសហគមន៍កាតូលិកក្នុងភូមិ ឬស្គាល់តាមរយៈមិត្តភក្តិដែលរៀននៅសាលាសន្តហ្វ្រង់ស្វ័រ និងមិត្តភក្តិដែលជាក្រុមកាយឫទ្ធិជាដើម។ ក្នុងការជួបជុំនេះពួកគេរីករាយទស្សនា ការសម្តែងរឿងកំណើតព្រះយេស៊ូ ដែលសម្តែងដោយក្រុមកុមារកាយឫទ្ធិនៃព្រះសហគមន៍កាតូលិកភូមិចំការទៀង និងទទួលអំណោយខ្លះៗផងដែរ។ កម្មវិធីបានប្រព្រឹត្ត



ថតដោយ សុធារិទ្ធ

ទៅប្រកបដោយអំណរសប្បាយបំផុត។ នេះបានបញ្ជាក់យ៉ាងច្បាស់ពីវត្តមានរបស់ព្រះជាម្ចាស់ ដែលបានយាងមកសម្រាប់មនុស្សទាំងអស់ ហើយគង់ជាមួយយើងផង។ ក្នុងឱកាសនោះលោកអភិបាលអូលីវីយេ បានមានប្រសាសន៍ទៅកាន់កុមារទាំងនោះថា យើងជួបជុំគ្នាថ្ងៃនេះ ដើម្បីអបអរបុណ្យព្រះយេស៊ូប្រសូត។ សូមឲ្យកូនៗទាំងអស់ទទួលពន្លឺពីព្រះជាម្ចាស់ ដែលនាំឲ្យកូនៗ ទៅជាកូនល្អ ចេះគោរពចាស់ទុំ ខិតខំរៀនសូត្រ យកចិត្តទុកដាក់កសាងអនាគតឲ្យល្អ ដើម្បីកសាងគ្រួសារដ៏ល្អ និងទៅជាពលរដ្ឋដ៏ល្អក្នុងសង្គម។ មានប្រសាសន៍ពាក្យទាំងនេះចប់ លោកអភិបាលបានសូត្រមួយម្តងទៀតដើម្បីឲ្យកុមារទាំងអស់សូត្រតាម។ ព្រះសហគមន៍កាតូលិកភូមិចំការទៀង ស្ថិតនៅចំកណ្តាលវាលស្រែ នៃទីជនបទដាច់ស្រយាល តែមានសកម្មភាពសស់រវើក ក្នុងសកម្មភាពមេត្តាករុណា ការសិក្សា និងការអប់រំជំនាញសិប្បកម្ម។ យុវជន កុមារបានស្គាល់ព្រះជាម្ចាស់តាមរយៈសក្ខីភាពក្នុងសកម្មភាពខាងលើ។ បន្ទាប់ពីបានទស្សនា ការសម្តែងរឿងកំណើត ព្រះយេស៊ូ និងរបាំបុរាណខ្មែរ នៅលើឆាកសម្តែងដ៏ធំ ដែលមិនធ្លាប់មាននៅក្នុងតំបន់នេះមក កុមារទាំងអស់ទទួលកញ្ចប់អំណោយពីលោកអភិបាល ហើយបានវិលត្រលប់ទៅផ្ទះវិញដោយរីករាយបំផុត។

# លោកអភិបាលអូលីវីយេ ត្រូវស្រឡាញ់បរិស្ថានដូចស្រឡាញ់ម្តាយបង្កើតផ្ទាល់ខ្លួន

ព្រះសហគមន៍កាតូលិកសន្តីម៉ារីញញឹម ភូមិចំការទៀង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ បានរៀបចំសិក្ខាសាលាមួយស្តីអំពីបរិស្ថាន ក្រោមប្រធានបទ គ្រួសារស្រឡាញ់បរិស្ថានដោយនាំគ្នាលុបបំបាត់ថង់ប្លាស្ទិច និងចូលរួមដាំដើមឈើ នាថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៧។ កម្មវិធីនេះ មានការចូលរួមពីសហគមកាតូលិកទាំងប្រាំបីក្នុងខេត្តតាកែវរួមជាមួយអាជ្ញាធរទាំង៣០ភូមិក្នុងឃុំគុសសរុបប្រមាណជា ២៥០នាក់ក្រោមអធិបតីភាពរបស់ លោកអភិបាលអូលីវីយេនិងលោក ហុង ភារៈ ជាអនុប្រធានមន្ទីរបរិស្ថានខេត្តតាកែវ។

លោកអភិបាលអូលីវីយេ បានថ្លែងក្នុងអង្គសិក្ខាសាលានេះ លោកអភិបាលបានលើកឡើងចំនួនបីចំនុចសំខាន់ៗគឺ ទីមួយ ឲ្យយើងម្នាក់ៗទុកផែនដីដូចជាម្តាយ ជាបងស្រីរបស់យើងបង្កើត ដែលយើងត្រូវរួមគ្នាទទួលខុសត្រូវក្នុងការថែរក្សាបរិស្ថាន។ ទីពីរឲ្យយើងបង្កើតវប្បធម៌ថ្មី ដោយចេះការពារថែរក្សាធម្មជាតិ និងបរិស្ថានដូចការពារម្តាយរបស់យើងព្រោះថា ផែនដីបានធ្វើឲ្យយើងមានដង្ហើម មានកម្លាំង មានជីវិត បើមនុស្សយើងបំផ្លាញផែនដីដូចជាបំផ្លាញខ្លួនឯងផ្ទាល់ ហេតុនេះហើយយើងត្រូវគោរព ស្រឡាញ់ ថែរក្សាការពារបរិស្ថានដូចយើងគោរពស្រឡាញ់ថែរក្សាការពារម្តាយរបស់យើង បើយើងកាប់ដើមឈើមួយដើម ឲ្យយើងដាំពីរដើមវិញ។ និងទីបី យើងត្រូវតែបន្ថែមការអប់រំស្តីពីបរិស្ថាននេះដល់ប្រជាពលរដ្ឋ ឲ្យបានទូលំទូលាយជាងមុន ដើម្បីឲ្យភូមិរបស់យើងទៅជាភូមិបៃតង។ លោកអភិបាលបានលើកទឹកចិត្តដល់អាជ្ញាភូមិឃុំ ក្នុងការរៀនចំកម្មវិធីភូមិស្អាតដល់ប្រជាជនដោយមានគណកម្មការចុះពិនិត្យដល់ផ្ទះប្រជាពលរដ្ឋនិងដាក់ពិន្ទុគ្រួសារណាដែលបានយកចិត្តទុកដាក់ថែរក្សាបរិស្ថានបានល្អជាងគេ ក្នុងន័យថា ទាំងថែរក្សាបរិស្ថានទាំងអនាម័យ ទាំងការពារធម្មជាតិ ដោយមានព្រះសហគមន៍ជាអ្នកឧបត្ថម្ភ និងសហការជាមួយភូមិឃុំ។

លោក ហុង ភារៈ អនុប្រធានមន្ទីរបរិស្ថានខេត្តតាកែវទទួលបន្ទុកបរិស្ថានបានពន្យល់អំពីការគ្រប់គ្រងកាកសំណល់និងផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលសម្រាប់ក្រុមគ្រួសារ និងសហគមន៍ដល់អង្គសិក្ខាសាលាទាំងមូល។ លោកបានសង្កាត់ធ្ងន់ថា សព្វថ្ងៃការបំពុលបរិស្ថានមានបួនចំនុចសំខាន់គឺ ការបំពុលទឹក ការបំពុលដី ការបំពុលខ្យល់ និងការបំពុលទន្លេ ដែលអាជ្ញាធរគួរយកចំនុចទាំងនេះទៅពិភាក្សាក្នុងភូមិឃុំរបស់ខ្លួនដើម្បីដោះស្រាយបញ្ហាបរិស្ថាន។ លោកក៏បានស្នើឲ្យសិក្ខាកាមទាំងអស់យកចិត្តទុកដាក់លើការទុកដាក់កាកសំណល់ ដោយធ្វើការបែងចែកជាកាកសំណល់ដែលអាចកែច្នៃបាន កាកសំណល់មិនអាចកែច្នៃបាន កាកសំណល់ប្លាស្ទិច កាកសំណល់វិទ្យុសកម្ម ដែលគួរជៀសវាងការដុតកាកសំណល់ទាំងនោះព្រោះអាចប៉ះពាល់ដល់សុខភាព ដោយធ្វើការកក់សំរាមទាំងនោះវិញ។ លោកអនុប្រធានមន្ទីរក៏បានបញ្ជាក់ផងដែរថា ចំពោះកាកសំណល់ដែលអាចបំភាយវិទ្យុសកម្ម ដូចជា ទូរស័ព្ទ ថ្មពិល អាគុយ ទូរទស្សន៍ ជាដើមសហគមន៍គួរមានកន្លែងស្តុកទុកមួយច្បាប់លាស់រួចទំនាក់ទំនងទៅមន្ទីរបរិស្ថានខេត្ត ដើម្បីមកយកកាក់សំណល់នោះទៅចោលកន្លែងមានសុវត្ថិភាព។ ដើម្បីឆ្លើយតបនឹងផលពិបាករបស់ប្រជាពលរដ្ឋអំពីបញ្ហាបរិស្ថាន លោកអនុប្រធានមន្ទីរបរិស្ថានរូបនេះ ក៏បានសន្យាថាលោកនឹងដឹកនាំក្រុមការងារមកដោះស្រាយជូនប្រជាពលរដ្ឋក្នុងឃុំគុសក្នុងពេលឆាប់ៗនេះ។

លោក មាឃ ស៊ិន ជាប្រធានក្រុមអ្នកផ្តួចផ្តើមរៀបចំសិក្ខាសាលានេះ បានឲ្យដឹងថា បានជាមានការរៀបចំសិក្ខាសាលាស្តីអំពីបរិស្ថាននេះឡើង ព្រោះដោយសារលោកនិងក្រុមលោកបានទទួលបេសកកម្មពីសាលាអប់រំជំនឿគ្រីស្តបរិស័ទសន្តយ៉ូស្វីន ដើម្បីប្រកាសដំណឹងល្អ និងចូលរួមអភិវឌ្ឍប្រទេសជាតិ។ មួយវិញទៀតលោកមើលឃើញថាបរិស្ថាន គឺជាមូលដ្ឋានគ្រឹះសម្រាប់ប្រជាពលរដ្ឋដែលត្រូវតែយកចិត្តទុកដាក់ ដើម្បីថែរក្សាអនាម័យ និងសុខភាពរបស់ខ្លួនជាប្រចាំ។ លោកបានបន្តថា ក្រុមលោក នឹងធ្វើការសហការជាមួយអាជ្ញាធរភូមិឃុំ ដើម្បីរៀបចំសិក្ខាស្តីពីបរិស្ថាននេះនៅតាមភូមិរបស់ប្រជាពលរដ្ឋ ដើម្បីឲ្យប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីបរិស្ថាន និងរបៀបការពារថែរក្សាបរិស្ថាននេះផងដែរ។

គួរបញ្ជាក់ផងដែរថា សិក្ខាសាលានេះជាសិក្ខាសាលាលើកទីមួយដែលលោក មាឃ ស៊ិន និងក្រុមលោក ដែលរួមមានលោក យុន សម្អាត លោក កែវ ភោគ លោក សែម ធីម លោក សែ ថុន លោក ភឿន សុភាន់ ជាអតីតនិស្សិតនៃសាលាអប់រំជំនឿគ្រីស្តបរិស័ទសន្តយ៉ូស្វីនជំនាន់ទីមួយជំនាន់ទីពីរ និងជំនាន់ទីបី។

*ដោយ សុធារិទ្ធ*



ថតដោយ សុធារិទ្ធ

# លោកអភិបាលអូលីវីយេ "យើងទាំងអស់គ្នា គឺជាគ្រីស្តទូត"



លោកអភិបាលអូលីវីយេមានប្រសាសន៍ថា "យើងមានលក្ខណៈប្លែកពីការងារក្នុងក្រុមហ៊ុន អង្គការ និងសមាគម ព្រោះយើងទាំងអស់គ្នា គឺជាគ្រីស្តទូត"។ លោកបានរំឭកឲ្យបុគ្គលិកគ្រប់ការិយាល័យព្រះ-សហគមន៍ភូមិភាគភ្នំពេញទាំងអស់ឲ្យយកចិត្តទុកដាក់នៅក្នុងការងាររបស់ខ្លួន ដោយផ្សព្វភ្ជាប់នូវបេសកកម្មដើម្បីផ្តល់សក្ខីភាពអំពីព្រះជាម្ចាស់។ ត្រូវខិតខំបង្កើតបរិយា-កាសល្អនៅកន្លែងការងារ ដោយគោរពគ្នា និងសហការគ្នាទៅវិញទៅមកឲ្យបានល្អ ព្រមទាំងស្រឡាញ់ការងាររបស់ខ្លួន ដែលនាំឲ្យយើងមានអំណរសប្បាយ។

លោកអភិបាលបានមានប្រសាសន៍ដូចនេះ នៅក្នុងឱកាសអបអរសាទរបុណ្យព្រះយេស៊ូប្រសូត រួមជាមួយបុគ្គលិកតាមការិយាល័យទាំងអស់ ក្នុងភូមិភាគភ្នំពេញ កាលពីថ្ងៃទី២២ ធ្នូ ២០១៦ នៅព្រះវិហារសន្តប៉ូល និងសន្តសិលាភ្នំពេញថ្មី។

លោកអូលីវីយេបានមានប្រសាសន៍កត់សំគាល់ថា "ប៉ុន្មានឆ្នាំនេះ ខ្ញុំឃើញជីវិតព្រះសហគមន៍មានភាពរីកចម្រើនទៅមុខ និងបងប្អូនជាកម្លាំងរបស់ព្រះសហគមន៍"។

ក្នុងឱកាសនេះដែរលោកអភិបាលបានណែនាំ និងផ្តល់អនុសាសន៍ ៣ចំណុចសំខាន់ៗដែលទាំងអស់គ្នាត្រូវយកចិត្តទុកដាក់គឺ៖ ១) កែប្រែចិត្តគំនិត មានប្រែចិត្តគំនិតដោយបង្កើតបរិយាកាសដែលមានប្រសិទ្ធភាព ដើម្បីធ្វើការជាមួយគ្នាយ៉ាងជិតស្និទ្ធ និងមានអំណរសប្បាយ។ ២) លើកលែងទោស គឺត្រូវចេះសម្រុះសម្រួល និងណែនាំឲ្យបងប្អូននិយាយសេចក្តីពិត ដែលនាំឲ្យយើងអាចដកបន្លាដែលរារាំងចិត្តគំនិតយើង។ និង៣) ធ្វើជាសាក្សី គឺសូមកុំខ្លាចក្នុងការផ្តល់សក្ខីភាពដែលជាសញ្ញា និងឥទ្ធិពលដែលយើងបានទទួលពីព្រះយេស៊ូ។

ក្នុងនោះដែរលោកអភិបាលក៏បានលើកយកលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ស្តីអំពី "ការប្រណីសន្តោស និងសេចក្តីអាណិតអាសូរ"។ តាមរយៈសារលិខិតនេះលោកអភិបាលបានជំរុញឲ្យគ្រប់គ្នាបង្កើតនូវវប្បធម៌មេត្តាករុណា ដើម្បីឲ្យទៅជាវប្បធម៌មួយដែលនាំឲ្យយើងចេះមើលគ្នាទៅវិញទៅមក ដោយយកចិត្តទុកដាក់ចំពោះបងប្អូនដែលមានទុក្ខលំបាក កំពុងឈឺចាប់ និងអស់អ្នកដែលគ្មានអ្នកអើពើឲ្យមានសង្ឃឹមឡើងវិញ។ លោកបន្តថា ការបំពេញកិច្ចការនៃមេត្តាករុណា គឺជាការប្រព្រឹត្តដោយផ្ទាល់ដៃ និងដោយក្តីស្រឡាញ់របស់យើងតាមវិធីរាប់ពាន់របៀប។

នៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញមានស្ថាប័ន១១ ដែលកំពុងបំពេញសកម្មភាពយ៉ាងសកម្មមានដូចជា យុវជន និងកុមារ ព័ត៌មាន សុខភាព អប់រំជំនឿ អប់រំទូទៅ គណៈកម្មការពលករ ខុទ្ទកាល័យលោកអភិបាល ក្រុមបដិសណ្ឋារកិច្ចភ្ញៀវ នៅភ្នំពេញថ្មី សហគ្រិនសង្គម ផ្នែកសិល្បៈ និងគណៈកម្មការព្រះគម្ពីរ។

ក្រោយពីទទួលការអប់រំពីលោកអភិ-បាល ក៏មានពិធីអរព្រះគុណព្រះជាម្ចាស់ អបអរបុណ្យព្រះយេស៊ូប្រសូត ព្រមទាំងការចែករំលែកអំណរសប្បាយពីលោកអភិបាល ដល់កុមារទាំងឡាយដែលចូលរួម និងបុគ្គលិកទាំងអស់ម្នាក់ទទួលអំណោយគ្រប់ដៃ។ អ្វីដែលអស្ចារ្យ គឺមាននំខួបកំណើតដ៏ធំ សម្រាប់កុមារទាំងអស់ផ្លុំទៀនអបអរកំណើតព្រះយេស៊ូ ដែលពួកគេមិនធ្លាប់ជួប។

កម្មវិធីនេះបានបញ្ចប់ដោយទទួលទានអាហារសាមគ្គីរួមគ្នាយ៉ាងធ្លាញ់ពិសា និងពោរពេញដោយអំណរសប្បាយរីករាយក្រៃលែង ក្នុងភាពស្និទ្ធស្នាលជាទីបំផុត។

*ដោយដាលីស*

# លោកអូលីវីយេ ជំរុញឲ្យសាសនិកទាំងអស់រួមគ្នាកសាងសន្តិភាព

លោកអូលីវីយេ ជាអភិបាលព្រះសហ-គមន៍កាតូលិក ភូមិភាគភ្នំពេញ នៅក្នុងជំនួបតំណាងសាសនានានា ក្នុងខេត្តតាកែវ បានជំរុញឲ្យទាំងអស់គ្នារួមគ្នាដើម្បីកសាងសន្តិភាព លោកថា "សុខសន្តិភាពសម្រាប់ទាំងអស់គ្នា ទាំងអស់គ្នាដើម្បីសន្តិភាព"។ យើងម្នាក់ៗសង្ឃឹមថាយើងមានសេចក្តីសុខ សន្តិភាពក្នុងចិត្ត សម្រាប់ម្នាក់ៗ។ ជាងនេះទៅទៀតគឺ "ទាំងអស់គ្នាដើម្បីសន្តិភាព" មានន័យថា សន្តិភាពកើតឡើង លុះត្រាតែទាំងអស់គ្នា ចូលរួមយ៉ាងសកម្ម។ សាសនាមានតួនាទីចូលរួមក្នុងការកសាងសន្តិភាព ទាំងអស់គ្នា។ មិនខ្វះទេហិង្សាក្នុងពិភពលោកនេះ ហេតុនេះសាសនាមានតួនាទី អប់រំផ្លូវចិត្តកសាងសីលធម៌ និងកសាងអនាគតដ៏ភ្លឺស្វាង ដែលចេះសហការគ្នា និងជួយគ្នាទៅវិញទៅមក។ ក្នុងពិភពលោកការបែកបាក់ និងឈ្លោះគ្នា គឺបណ្តាលមកពីសាសនា។ ហេតុនេះមេដឹកនាសាសនាទាំងអស់ត្រូវរួមគ្នាកសាងសុខដុមរមនាឲ្យបាន។

លោកអភិបាលក៏មានប្រសាសន៍ថា ក្នុងឆ្នាំថ្មីសូមឲ្យមេដឹកនាំសាសនាទាំងអស់យកចិត្តទុកដាក់នឹងក្រុមគ្រួសារ "បើគ្រួសារសុខសាន្តនាំឲ្យសង្គមសុខសាន្ត"។

ពិធីជួបជុំអន្តរសាសនានេះបានធ្វើឡើងនៅទីស្នាក់ការព្រះសហគមន៍កាតូលិកខេត្តតាកែវ កាលពីថ្ងៃទី២៦ ខែធ្នូកន្លងទៅ ដែលមានការចូលរួមពីសំណាក់ តាជី យាយជី ពុទ្ធបរិស័ទ ឥស្លាម និងគ្រីស្ត-បរិស័ទយ៉ាងច្រើនកុះករ។

លោក គាំ ដាំផេង អនុប្រធានមន្ទីរធម្មការ និងសាសនាខេត្តតាកែវ បានចាប់អារម្មណ៍ និងលើកទឹកចិត្តឲ្យសាសនាទាំងអស់រួមគ្នា ប្រកបដោយសុខដុមបំផុត ដើម្បីភាពរីកចម្រើន និងសន្តិភាព។ លោកក៏បានអំពាវនាវឲ្យសាសនាទាំងអស់ ខិតខំបន្តអប់រំអំពីសុជីវធម៌ សីលធម៌រស់នៅល្អ និងលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ។ លោកក៏សូមឲ្យសាសនាទាំងអស់ចូលរួមជួយពេលមានគ្រោះមហន្តរាយធម្មជាតិ ជួយកុមារកំព្រា កុមារងាយរងគ្រោះ។ អប់រំអំពីផលប៉ះពាល់នៃប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ល្បែងស៊ីសងគ្រប់ប្រភេទ លុបបំបាត់អំពើអនាចារផ្សេងៗ។ ជំរុញឲ្យការសាងសង់ ព្រះវិហារនានា ត្រូវមានប្លង់ មានបរិស្ថានល្អ គិតអំពី វប្បធម៌ប្រពៃ-ណីខ្មែរជាដើម។ល។

ការជួបជុំជាលក្ខណៈអន្តរសាសនានៅក្នុងខេត្តតាកែវ ដែលរៀបចំដោយព្រះសហ-គមន៍កាតូលិក បានប្រព្រឹត្តរយៈពេល៤ដងរួចមកហើយ នៅក្នុងឱកាសអបអរ-សាទរបុណ្យព្រះយេស៊ូប្រសូត។ ព្រះសហ-គមន៍កាតូលិកភូមិភាគភ្នំពេញបានខិតខំយ៉ាងខ្លាំង ក្នុងការបង្កើតកិច្ចសន្ទនា អន្តរ-សាសនា ដើម្បីបញ្ចៀសឲ្យបាននូវការយល់ច្រលំគ្នា។ កម្មវិធីនេះមិនត្រឹមតែធ្វើឡើងក្នុងខេត្តតាកែវប៉ុណ្ណោះគឺនឹងមាន នៅរៀបចំនៅខេត្តព្រះសីហនុ កំពត និងថ្នាក់ជាតិផងដែរ។ ក្នុងជំនួបនេះ តំណាងមេដឹកនាំសាសនា ព្រះពុទ្ធសាសនា ក្រុមជំនុំ និងឥស្លាមសាសនា បានសាទរយ៉ាងខ្លាំង និងគាំទ្រយ៉ាងពេញទំហឹងចំពោះសកម្មភាពដែលបានធ្វើ។ ពិធីបានបញ្ចប់ដោយមានអាហារសាមគ្គី និងមានចង្ហាន់សម្រាប់ព្រះសង្ឃផងដែរ ក្នុងបរិយាកាសរីករាយបំផុត។



ថតដោយ លី សុវណ្ណា



# លោកយ៉ូសែប ថុន (១៩៤៥-១៩៧៨)

## Mr. Joseph THONG

## ជាគ្រូបាស្ទ័ ជាគ្រូអប់រំជំនឿ

លោកកើតប្រហែលឆ្នាំ ១៩៤៥ ហើយមានដើមកំណើតនៅវៀតណាម នៅក្រុងហាណូយ ដែលជាក្មួយ របស់លោកគ្រូងាមីយ៉ាំង។ លោកមករស់នៅភូមិកំពង់គ ហើយរៀនអាននិងសរសេរភាសាខ្មែរនៅទីនោះ។ ក្រោយមក លោកទទួលការអប់រំជំនឿពីលោកគ្រូងាមីយ៉ាំង។ លោកក្លាយទៅជាគ្រូអប់រំជំនឿក្រោយបានទទួលការអប់រំនៅខេត្តបាត់ដំបង ហើយអប់រំជំនឿរវាងឆ្នាំ ១៩៦៥-១៩៦៨ ផ្នែកក្រុមរៀបចំជ្រមុជទឹក និង លាបថ្វាស។

ពេលការអធិដ្ឋាននិងអភិបូជានៅព្រះវិហារ លោកស្វះស្វែងទៅជាមួយកូនចៅក្មួយបង្ហាញថា ជាក្រុមគ្រួសារដែលស្និតស្នាញ និងមានជំនឿរឹងមាំ។ ក្រោយអភិបូជា ថ្ងៃសៅរ៍និងអាទិត្យ លោកតែងតែបង្រៀន អប់រំជំនឿ និងបន្ថែមពីប្រវត្តិព្រះយេស៊ូ។ លោកធ្លាប់ប្រាប់កូនសិស្សថា "ប្រសិនបើមានបញ្ហា ស្មុគស្មាញកើតឡើងក្នុងជីវិត សូមអធិដ្ឋានទៅព្រះជាម្ចាស់"។ ធ្វើឲ្យសិស្សខ្លះចងចាំនិងអនុវត្តរហូតដល់ សព្វថ្ងៃនេះ។

លោករៀបការជាមួយសាវឿន នារីខ្មែរនៅភូមិកំពង់គ ហើយមានទាំងកូនទាំងចៅ ៧ នាក់។ ជាមួយកូននិងចៅ លោកព្យាយាមអប់រំឲ្យទៅព្រះវិហារ ដើម្បីអធិដ្ឋាន និងចូលរួមអភិបូជា។ លោកចង់ឲ្យគ្រួសាររបស់លោកមានជំនឿរឹងមាំ។ គ្រួសាររបស់លោកជាគំរូសម្រាប់គ្រិស្តបរិស័ទឯទៀតៗដែរ។ លោកមិនដែលប្រើអំពើហិង្សាលើកូន ឬប្រពន្ធទេ លោកមិនមែនជាមនុស្សផឹកនិងជក់បារីដែរ។

នៅក្នុងព្រះសហគមន៍ លោកជាជំនួយសំខាន់ម្នាក់របស់លោកពុកវីរ៉ៃណេ (MEP)។ ទាំងការងារ ធ្វើស្រែ ទាំងខាងការបង្រៀន និងអប់រំជំនឿ។ លោកជួយរបង្កើតកម្មវិធីផ្សេងៗក្នុងព្រះវិហារ និងជួយអាសាការងារអ្នកដទៃ។

គុណធម៌សំខាន់មួយរបស់លោកគឺ លោកបង្រៀនកូនក្មេងក្នុងភូមិរាល់ព្រឹកនិងល្ងាច។ លោកតែង តែរំលឹកដាស់តឿនកូនចៅរបស់លោកឲ្យយកចិត្តទុកដាក់រៀនសូត្រ។ ក្រៅម៉ោងរៀនក្នុងសាលា លោកនាំកូនក្មេងលេងល្បែងកម្សាន្ត។ ចំពោះការទំនាក់ទំនងជាមួយលោកគ្រូឯទៀតៗ របស់លោកគឺ មានលក្ខណៈល្អជាមួយគ្នា។ លោកជាមនុស្សចូលចិត្តសុត្រធម៌ ហើយឧទ្ទិសខ្លួនដើម្បីព្រះជាម្ចាស់និងបងប្អូន។ ជួនកាលកូនសិស្សរបស់លោកខ្លះ នៅតែផ្តល់សក្ខីភាពអំពីជំនឿនិងទទួលការផ្តើមគំនិតពីលោក។

នៅឆ្នាំ ១៩៧០ ពេលទាហានវៀតកុងចូលភូមិ ហើយចាប់លោកពុកវីរ៉ៃណេ និងគ្រិស្តបរិស័ទមួយ ចំនួន លោកហ៊ានប្រកែកជាមួយទាហានថា "សូមកុំប៉ះពាល់លោកឪពុកខ្ញុំ"។ លោកព្យាយាមធ្វើអន្តរាគមន៍ ដោយសារគាត់ចេះនិយាយវៀតណាម ពួកវៀតកុងអត់ចាប់គាត់ទេ លោកប្រថុយជីវិតទៅជាមួយកាណូតនោះដែរ។ ក្រោយមកពួកទាហាននោះក៏នាំលោកបូជាចារ្យយកមកកំពង់គវិញ។ នៅឆ្នាំ ១៩៧៤ លោកជួយចែកចាយម្ហូប អាហារឲ្យជនភៀសខ្លួន ៤០,០០០ នាក់។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមយកកំពង់ធំនិងជម្លៀសប្រជាជនទៅធ្វើការ។ គ្រូថុងត្រូវឃើញទៅធ្វើការ នៅភូមិសំរោង (តាំងគោក) ជាកន្លែងដែលលោកបានឃើញគ្រិស្តបរិស័ទនៅភ្នំពេញ និងកំពង់ធំ។

នៅឆ្នាំ ១៩៧៨ ក្នុងអំឡុងពេលដ៏សែនវេទនាសម័យខ្មែរក្រហម លោកត្រូវបញ្ជូនទៅ "រៀន" ដូច ជនជាតិវៀតណាមនៅប្រទេសកម្ពុជា។ លោកគ្រូថុងរៀបចំជាស្រេច លោកលុតជង្គង់ហើយនិយាយថា "ខ្ញុំចង់ឲ្យកូនមួយក្នុងចំណោមកូន ៦ នាក់ ថ្វាយទៅកាន់ព្រះជាម្ចាស់"។



សន្តី អឺឡាលីយ៉ា នៅមេរីដា

នាងអឺឡាលីយ៉ាជាព្រហ្មចារីដ៏ល្បីល្បាញជាងគេនៅប្រទេសអេស្ប៉ាញ។ នាងកើតនៅ ទីនោះនៅសតវត្សទីបី។ នៅសម័យនោះ ព្រះចៅអធិរាជរ៉ូម៉ាំងបៀតបៀនគ្រិស្តបរិស័ទ យ៉ាងខ្លាំងជាទីបំផុត។ ពេលគេចាប់គ្រិស្តបរិស័ទម្នាក់ គេបញ្ជាឲ្យអ្នកនោះថ្វាយយញ្ញបូជាចំពោះព្រះក្លែងក្លាយនៃជនជាតិរ៉ូម៉ាំង។ ប៉ុន្តែគ្រិស្តបរិស័ទភាគច្រើនមិនព្រមក្បត់ ជំនឿរបស់ខ្លួន ទើបត្រូវគេសម្លាប់។ ថ្ងៃមួយ គេចាប់នាងអឺឡាលីយ៉ាដែលមានបំណងចង់បង្ខំនាងឲ្យថ្វាយយញ្ញបូជាចំពោះព្រះក្លែងក្លាយ។ ទោះបីម្តាយនាងអង្វរនាងគោរព បញ្ជារបស់ព្រះចៅអធិរាជក៏នាងមិនព្រមស្តាប់ម្តាយ ដោយពោលថា៖ គួរតែស្តាប់បង្គាប់ព្រះជាម្ចាស់ជាងស្តាប់បង្គាប់មនុស្សលោក។ ខ្ញុំបាត់បង់ជីវិតនៅក្នុងលោកីយ៍នេះមែន តែខ្ញុំនឹងទទួលជីវិតអស់កល្បជានិច្ចពោរពេញដោយសុភមង្គលនៅស្ថានបរមសុខ រួមជាមួយព្រះបិតាវិញ។ ដោយសារគេខឹងពេកគេយកនាងចងដៃចងជើងជាប់ នឹងដើមឈើ ធ្វើទុក្ខទារុណកម្មគ្រប់យ៉ាងដល់នាង និងដុតនាងទាំងរស់ តែនៅពេលនោះនាងមានមុខពោរពេញដោយអំណរសប្បាយ ដោយបានបូជាជីវិតសម្រាប់ស្តេច នៃស្ថានបរមសុខ។ នៅពេលនោះនាងអាយុ១២ឆ្នាំប៉ុណ្ណោះ។

# កំណាព្យ ល្បែងតែងវិនាស

(បទព្រហ្មគិតិ)



និពន្ធដោយអ្នកស្រី ខុង ណារី, មន្ត្រីគ្រប់គ្រងកម្មវិធីអប់រំ និង សុខភាព នៃគម្រោងអភិវឌ្ឍន៍ជនបទ អង្គស្ទួល / JSC

១),ពាក្យថាល្បែងតែងវិនាស
កុំប៉ងក្បៀកកិតកាយ
ចូរបង្វៀសជៀសឲ្យឆ្ងាយ
នាំអន្តរាយដល់អាត្មា ។

២),ព្រោះល្បែងតែងនាំផល
ច្បាប់បានចែងចរចា
អសោចដល់កេរ្តិ៍ផងណា
ទុកតម្រាដូនប្រុសស្រី ។

៣),លួចលាក់ជំពាក់ប្រាក់
កើតការច្រើនរាល់ថ្ងៃ
ចងបណ្តាក់ដោយបុលខ្ចី
ស្រូវវ័យល្អីសងពុំគ្រប់ ។

៤),មួយឆ្នាំដល់ពីរឆ្នាំ
សងដើមមិនទាន់គ្រប់
ចងប្រចាំមិនព្រមឈប់
ការកើនលប់ទៀងរាល់ខែ ។

៥),លក់អស់ទ្រព្យទាំងឡាយ
សម្បត្តិច្រើនហូរហែ
ដែលសោកស្តាយទោះកេរម៉ែ
កោតចិត្តមិនស្រណោះ ។

៦),លុះដល់ផ្លាក់ខ្លួនក្រ
នឹកស្តាយទ្រព្យរបស់
ទើបត្រដររថាហួសអស់
មិនគួរសោះអស់ពីប្រាណ ។

៧),ខ្មាសអស់ញាតិប្អូនបង
ឈប់សាសងលែងរាប់អាន
គេស្អប់ខ្ពើមសន្តាន
មនុស្សលង់ប្រាណដោយសារល្បែង ។

៨),ម៉ែឪស្តីប្រដៅ
ព្រោះច្បាប់ចាប់មិនលែង
ប្រាប់កូនចៅឲ្យគិតក្រែង
ទោសខ្លួនឯងថ្លែងមិនស្តាប់ ។

៩),ជនខ្លះគាត់ចាញ់ល្បែង
ខ្លះទៀតដើរខុសច្បាប់
សោកសង្រេងចង់តែស្លាប់
កើតចិត្តចាប់ជាចោរប្លន់ ។

១០),ជួនហ៊ានធ្វើឃាតករ
ទុកឲ្យកូនប្រពន្ធ
ដែលរបរជាប់ទោសធ្ងន់
វែកទម្ងន់ក្នុងគ្រួសារ ។

១១),នេះគឺដោយសារល្បែង
ទុក្ខទោសខ្លួនឯងកា
កុំប្រថែងនាំបញ្ហា
គ្មានអ្នកណាគេរាប់រក ។

# យើងមានអំណរសប្បាយបំផុត ដោយសារព្រះបុត្រាព្រះជាម្ចាស់បានប្រសូតហើយ!



ថតដោយ សុធារិទ្ធ

មនុស្សម្នារាប់ពាន់នាក់យ៉ាងកកកុញ ខ្លះកាន់កន្ទេល ខ្លះកម្រាលផ្សេងៗ ដឹកដៃកូនចៅ ចូលក្នុងទីធ្លានៃព្រះសហគមន៍កាតូលិក ភូមិចំការទៀង ស្ថិតនៅកណ្តាលវាលស្រែ នៃស្រុកត្រាំកក់ ខេត្តតាកែវ ដើម្បីចូលរួមអបអរសាទរបុណ្យព្រះយេស៊ូប្រសូត។

ទោះបីអ្នកទាំងនោះភាគច្រើន គ្មានជំនឿលើព្រះយេស៊ូក៏ដោយតែពួកគេពេញចិត្ត និងចូលរួមក្នុងអំណរសប្បាយជាមួយព្រះសហគមន៍កាតូលិកផងដែរ។

នៅក្នុងទីធ្លាដែលមានការតុបតែងភ្លើងចំរុះពណ៌យ៉ាងល្អប្រណិតជាទីគយគន់បំផុត។ គ្រីស្តបរិស័ទបានចូលក្នុងព្រះវិហារដើម្បីកោតសរសើរ លើកតម្កើងព្រះជាម្ចាស់ រំឭកអំពីថ្ងៃដែលព្រះបុត្ររបស់ព្រះជាម្ចាស់បានកើតជាមនុស្ស។ ពិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់លោកអភិបាល អូលីវិយេ នៅថ្ងៃទី២៥ ធ្នូ ២០១៦។

ព្រះវិហារតូចពិតតែអាចស្វាគមន៍មនុស្សឲ្យរួបគ្នាកើតសរសើរព្រះជាម្ចាស់ដោយអំណរបំផុត។ មានប្រសាសន៍ក្នុងធម្មទេសនាថា នៅយប់នេះយើងមានអំណរសប្បាយ ជាពេលដែលយើងរង់ចាំស្តាប់ព្រះបន្ទូល ឬពាក្យថា "ព្រះអម្ចាស់យេស៊ូប្រសូតហើយ"។ លោកអភិបាលក៏បាននាំឲ្យបងប្អូនរិះគិតដែរថា តើក្នុងចំណោមយើងនរណាធំជាងគេ? លោកបានបង្ហាញអ្នកធំក្នុងពិភពលោក ប្រទេសកម្ពុជា និងក្នុងជំនឿ។ ក្នុងនេះលោកក៏បានលើកឡើងថា អ្នកធំក្នុងជំនឿ គឺ "ព្រះជាម្ចាស់"ជាព្រះបង្កើតអ្វីៗទាំងអស់មានឫទ្ធានុភាព។ ព្រះអង្គបានចាប់កំណើតជាមនុស្ស ដែលគ្មានអំណាចគ្មានទ្រព្យសម្បត្តិជាកូនង៉ែតតូចមួយ។ ព្រះអង្គយាងមកដើម្បីកុំឲ្យយើងខ្លាចភ័យតែឲ្យមានយើងមានជីវិតថ្មី មានសេចក្តីសង្ឃឹម។ ដោយសារព្រះអង្គប្រសូត គឺទាំងអស់មានសេចក្តីសុខ។

លោកអភិបាលក៏បានបង្ហាញសក្ខីភាពអំពីវត្តមានរបស់ព្រះជាម្ចាស់តាមសកម្មភាពព្រះសហគមន៍ជាមួយអ្នកតូចតាចបរិស័ទសាសនាផ្សេងៗ ជាមួយអ្នកដែលចង់ស្វែងរកព្រះអង្គ គឺមនុស្សដែលនៅជុំវិញយើង ដែលមានទទួលសេចក្តីសុខមានស្នាមញញឹមរីករាយ។

លោកក៏រំឭកឲ្យគ្រីស្តបរិស័ទបើកភ្នែកបើកត្រចៀករកឃើញព្រះអង្គក្នុងជីវិត មានសេចក្តីសង្ឃឹម ទទួលពន្លឺ និងជីវិតថ្មីពីព្រះអង្គ។ លោកអភិបាលថា ក្នុងសង្គមយើងមានបញ្ហាច្រើនណាស់តែដោយសារព្រះយេស៊ូយាងមកនាំឲ្យយើងមានសង្ឃឹម។ លោកអញ្ជើញឲ្យគ្រីស្តបរិស័ទទាំងអស់ធ្វើបដិវត្ត ដោយកសាងវប្បធម៌ នៃធម៌មេត្តាករុណា និងសេចក្តីប្រណីសន្តោស ព្រមទាំងបង្កើតពិភពលោកថ្មី។ បន្ទាប់ពីធម្មទេសនា មានកុមារតូច ៣នាក់ទទួលអគ្គសញ្ញាជ្រមុជទឹក គឺទទួលជីវិតថ្មីក្នុងថ្ងៃដែលព្រះអង្គបានប្រសូត។

ស្ថិតក្នុងឱកាសនោះ ដើម្បីអបអរសាទរ និងបង្កើនបរិយាកាសឲ្យកាន់តែសប្បាយរីករាយថែមទៀត ព្រះសហគមន៍បានរៀបចំការសម្តែងល្ខោនបាលាក់ និងរបាំប្រពៃណីនានា ព្រមទាំងមានការចាប់ឆ្នោតរង្វាន់ផងដែរ។

លោកអភិបាលបានមានប្រសាសន៍ថា យុវជន សម្តែងល្ខោនអំពីកំណើតព្រះយេស៊ូ ព្រមទាំងរបាំផង ហើយក៏មានចាប់រង្វាន់ពិសេសដែរ។ អ្វីដែលកាន់តែពិសេសនោះគឺ ព្រះសហគមន៍បានសាងសង់ រោងមហោស្រពថ្មីដ៏ធំទី២នៅកម្ពុជា លើឆាកមានតុបតែងភ្លើងយ៉ាងស្អាត ហើយក៏មានការសម្តែងរបាំជូនពរវង់ធំ ដែលមានអ្នករាំចំនួន២១នាក់ "ពិតជាអស្ចារ្យ"។ លោកបន្តថា ការសាងសង់រោងមហោស្រពនេះមិនមែនសម្រាប់តែសម្តែងក្នុងថ្ងៃបុណ្យព្រះយេស៊ូប្រសូតមួយឆ្នាំម្តងនោះទេ គឺព្រះសហគមន៍នឹងរៀងចំឲ្យការសម្តែងសិល្បៈក្នុងទំរង់ផ្សេងៗយ៉ាងតិច១ខែម្តង ដើម្បីចូលរួមថែរក្សាវប្បធម៌ និងសិល្បៈខ្មែរ និងឲ្យព្រះសហគមន៍នេះជាភូមិវប្បធម៌ថ្មីមួយសម្រាប់ឲ្យមនុស្សចេញចូលទស្សនាផងដែរ។

មានមនុស្សរាប់ពាន់មកអបអរសាទរបុណ្យព្រះយេស៊ូប្រសូត ទស្សនាការសម្តែងល្ខោនរឿងកំណើតព្រះយេស៊ូ និងសិល្បៈ ព្រមទាំងរង់ចាំផ្សៀងរង្វាន់ យ៉ាងសប្បាយបំផុត រហូតដល់វេលារំលងអធ្រាត្របិទកម្មវិធី។



ថតដោយ សុធារិទ្ធ

# ភូមិភាគភ្នំពេញ ប្រកាសបើកឆ្នាំក្រុមគ្រួសារ



ថតដោយ សុធារិទ្ធ

លោកអភិបាលអូលីវីយេ ឆ្មីតអឺស្លែរ បានប្រកាសយកឆ្នាំ២០១៧ ឆ្នាំ២០១៨ និងឆ្នាំ២០១៩ ជាឆ្នាំដែលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ត្រូវយកចិត្តទុកដាក់ជាពិសេស លើប្រធានបទក្រុមគ្រួសារ។ ការប្រកាសនេះបានធ្វើឡើងក្នុង ឱកាសបុណ្យព្រះយេស៊ូសម្ដែងព្រះអង្គកាលពីថ្ងៃទី៨ មករា ២០១៦នេះ នៅព្រះវិហារសន្តប៉ូល និងសន្តសិលា ភ្នំពេញថ្មី ដោយមានការចូលរួមពីបណ្ដាតំណាងព្រះសហគមន៍ បុព្វជិត បុព្វជិតា និងស្ថាប័នទាំងអស់នៃភូមិភាគភ្នំពេញ។

ក្នុងពេលនោះលោកអភិបាលអូលីវីយេ បានមានប្រសាសន៍រំឭកអំពីសារលិខិតរបស់សម្ដេចប៉ាប ដែលបានសរសេរអំពី "អំណរសប្បាយនៃសេចក្ដីស្រឡាញ់"។ លោកអភិបាលបានពន្យល់ថា សារលិខិតនេះនាំឲ្យយល់ថាពិតមែនក្រុមគ្រួសារគឺជាសង្គមតូចមួយ ដើម្បីចាប់ផ្ដើមជីវិតថ្មី។

លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញបានប្រកាសទៀតថា ឆ្នាំដំបូងនៃឆ្នាំគ្រួសារ(២០១៧) ព្រះសហគមន៍នឹងចាប់ផ្ដើមរិះគិតអំពីយុវជន យុវនារីដែលមានបំណងកសាងក្រុមគ្រួសារ។ ឆ្នាំបន្ទាប់ (២០១៨) ព្រះសហគមន៍រិះគិតអំពីអគ្គសញ្ញាអាពាហ៍ពិពាហ៍។ និងឆ្នាំចុងក្រោយ (២០១៩)គិតអំពីអ្នកដែលមានគ្រួសាររួចហើយ។

លោកអភិបាលក៏បានបង្ហាញអំពីស្ថានភាព នៃក្រុមគ្រួសារក្នុងសង្គម និងក្នុងព្រះសហគមន៍បច្ចុប្បន្ន គឺ៖ ១) អ្នកស្វែងរកគំរូក្នុងការកសាងគ្រួសារ ដោយសារនៅកម្ពុជាមានយុវជន ជាង៦០ភាគរយមានអាយុក្រោម ២២ឆ្នាំ។ ២) ភាពក្រីក្រដែលធ្វើឲ្យគ្រួសារជាច្រើនប្រឈមនឹងបញ្ហាមានហិង្សាក្នុងគ្រួសារ គ្រឿងញៀន គ្រឿងស្រវឹង និងល្បែងស៊ីសង។ ៣) គ្រួសារដែលធ្វើចំណាកស្រុក ដែលនាំឲ្យគ្រួសារបាត់ភាពកក់ក្ដៅត្រូវរស់នៅបែកគ្នា។ ៤) អំពីអាពាហ៍ពិពាហ៍អន្តរសាសនា គឺគ្រួសារដែលមានសាសនាផ្សេងគ្នា។

តាមស្ថានភាពនីមួយៗដែលបានលើកឡើងដោយលោកអភិបាលអូលីវីយេ ក៏មានក្រុមគ្រួសារ ដែលរស់នៅជាក់ស្ដែងក្នុងស្ថានភាពទាំងនោះមកផ្ដល់សក្ខីភាពផងដែរ។

ចុងក្រោយនៃសុន្ទរកថា លោកអូលីវីយេ បានបង្ហាញនូវភាពសុទិដ្ឋនិយមថា ក្នុង ២០១៧ ២០១៨ និង២០១៩ បងប្អូននឹងទៅជាព្រះសហគមន៍ ដែលអប់រំណែនាំយុវតី យុវជន ជំទង់ ព្រមទាំងយុវជនយុវនារី នៅពេលគេចាប់ផ្ដើមមានសេចក្ដីស្នេហា។ ហើយនឹងក្លាយទៅជាព្រះសហគមន៍ ដែលផ្ដល់សក្ខីភាព អំពីមេត្តាករុណា ព្រះហឫទ័យថ្នាក់ថ្នមរបស់ព្រះជាម្ចាស់។ ជាព្រះសហគមន៍ដែលជាឪពុកជាម្ដាយ។ ជាព្រះសហគមន៍ដែលស្ដាប់ និងមើលឃើញសេចក្ដីត្រូវការរបស់ក្រុមគ្រួសារ ដើម្បីបំភ្លឺរបៀបរស់នៅ និងមនសិការរបស់គេ។ ជាព្រះសហគមន៍ដែលត្រាស់ហៅគ្រួសារកាតូលិកឲ្យផ្ដល់សក្ខីភាព អំពីមេត្តាករុណា ការសន្ទនាសាមគ្គីគ្នា និងសន្តិភាពសម្រាប់គ្រប់ក្រុមគ្រួសារនៅកម្ពុជា និងក្នុងតំបន់ទាំងមូល។

*ដោយដាលីស*

# បុណ្យព្រះយេស៊ូសម្ដែងព្រះអង្គនៅភ្នំពេញ



ថតដោយ សុធារិទ្ធ

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានប្រារព្ធបុណ្យព្រះយេស៊ូសម្ដែងព្រះអង្គកាលពីថ្ងៃទី៨ មករា ២០១៦នេះ នៅព្រះវិហារសន្តប៉ូល និងសន្តសិលា ភ្នំពេញថ្មី ក្រោមអធិបតីភាពលោកអភិបាលអូលីវីយេ ឆ្មីតអឺស្លែរ ដោយមានការចូល រួមពីបណ្ដាតំណាងព្រះសហគមន៍ បុព្វជិត បុព្វជិតា និងស្ថាប័នទាំងអស់របស់ភូមិភាគភ្នំពេញ។

នៅក្នុងកម្មវិធីនេះលោកអភិបាលបានប្រកាសអរព្រះគុណព្រះជាម្ចាស់ និងអរគុណដល់សហការី បងប្រុស បងស្រីទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការប្រកាសដំណឹងល្អក្នុងឆ្នាំមហាករុណាទិគុណកន្លងមកនេះ។

លោកអូលីវីយេ ក៏បានលើកឡើងផងដែរអំពីសារលិខិតរបស់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ និងពន្យល់ឲ្យគ្រីស្តបរិស័ទទាំងអស់ឲ្យចូលទៅក្នុងពេលវេលាដើម្បីបដិវត្តនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ គឺជាពេលវេលាដើម្បីក្រោកឡើង ចូលទៅក្នុងបដិវត្តនៃសេចក្ដីស្រឡាញ់ និងសេចក្ដីសង្ឃឹម។

បើតាមប្រសាសន៍របស់លោកអភិបាលព្រះសហគមន៍បន្ទាប់ពីមើលវីដេអូ ដែលបង្ហាញអំពីសកម្មភាពដែលព្រះសហគមន៍បានធ្វើរយៈពេលមួយឆ្នាំកន្លងទៅលោកបានជំរុញ និងលើកទឹកចិត្តដើម្បីបន្តសកម្មភាពនេះបន្ថែមទៅមុខទៀត ដោយមានប្រសាសន៍ថា "លទ្ធផលនៃសកម្មភាពដែលបងប្អូនបានឃើញក្នុងវីដេអូនេះនាំឲ្យយើងមានកម្លាំង និងដឹងថាព្រះសហគមន៍នីមួយៗបានយកចិត្តទុកដាក់លើសកម្មភាពមេត្តាករុណា និងសូមឲ្យយើងបន្ត និងចាប់ផ្ដើមធ្វើថែមទៀត ហើយនេះជាពេលវេលានៃមេត្តាករុណា"។

លោកក៏បានបង្ហាញផងដែរនូវ អំណរសប្បាយក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត និងអំពីវត្តមានរបស់ព្រះជាម្ចាស់ដែលបានប្រសូតជាមនុស្ស តាមរយៈមុខរបស់បងប្អូនដែលលោកបានជួប ដែលបញ្ជាក់ច្បាស់ថាអ្វីៗទាំងអស់បងប្អូនទទួលនិងចូលរួមពោរពេញដោយអំណរសប្បាយ កម្លាំងសេចក្ដីសុខ និងសន្តិភាព គឺជាឫទ្ធានុភាពរបស់ព្រះម្ចាស់។

ឆ្នាំមេត្តាករុណាបានបិទ តែសកម្មភាពគឺត្រូវតែបន្ត ព្រះសហគមន៍ភូមិភាគភ្នំពេញមានផែនការធំសំខាន់ៗបន្ថែមទៀតដែលបង្ហាញដោយលោកអូលីវីយេ គឺ៖ សហគ្រិនភាពសង្គម និងសិប្បកម្ម។ សហគ្រិនភាពសង្គម និងកសិកម្ម។ កសាងវិទ្យាល័យបច្ចេកទេស កសិកម្ម និងទេសចរណ៍។ សាលាពេទ្យមធ្យម ២០១៨ និងបើកមន្ទីរពេទ្យកាតូលិកក្នុងឆ្នាំ២០២២។

ដើម្បីលើកទឹកចិត្តសហការីព្រះសហគមន៍ទាំងអស់ និងចែករំលែកអំណរសប្បាយដែលព្រះយេស៊ូបានយាងមកចាប់កំណើតជាមនុស្សលោកអភិបាលបានចែកសៀវភៅធម្មទេសនាក្នុងឆ្នាំមហាករុណាទិគុណកន្លងទៅដល់អ្នកចូលរួមទាំងអស់គ្នា និងមានពិធីជប់លៀងយ៉ាងសប្បាយរីករាយ។

*ដោយដាលីស*

## សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានអំពាវនាវឲ្យប្រជាពលរដ្ឋនានាយកចិត្តទុកដាក់លើចំណង អាពាហ៍ពិពាហ៍

កាលពីថ្ងៃទី២១ ខែមករា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លៃថា ការអប់រំនិងការរៀបចំអគ្គសញ្ញាអាពាហ៍ពិពាហ៍គួរតែយកចិត្តទុកដាក់ពង្រឹងបន្ថែមទៀត។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងថា អគ្គសញ្ញាអាពាហ៍ពិពាហ៍ គឺមិនមែនសម្រាប់តែការពារឲ្យអាពាហ៍ពិពាហ៍ស្របច្បាប់តាមសាសនាប៉ុណ្ណោះទេ ប៉ុន្តែគឺសម្រាប់ជាការពង្រឹងជំនឿ ចំពោះស្វាមីនិងភរិយា ដើម្បីឲ្យពួកគេទទួលបាននូវការជូនពរដ៏ពិសិដ្ឋសម្រាប់ប្រឈម និងដោះស្រាយបញ្ហាផ្សេងៗនៅក្នុងចំណងអាពាហ៍ពិពាហ៍។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ បានថ្លែងថា គោលដៅនៃការរៀបចំអគ្គសញ្ញាអាពាហ៍ពិពាហ៍នេះ គឺជាការជួយពួកគេឲ្យដឹងនិងចេះរស់នៅនៅក្នុងចំណងអាពាហ៍ពិពាហ៍មួយដ៏ពិតប្រាកដ ប៉ុន្តែមិនមែនត្រឹមតែជាការគោរពនិងឲ្យតម្លៃព្រមទាំងការទទួលស្គាល់នៅក្នុងសង្គមទេ ប៉ុន្តែវាគួរតែមានផ្លែផ្កា ដើម្បីឲ្យយើងទាំងអស់គ្នាមានលទ្ធភាពរីករាយនៃដំណើរក្នុងចំណងនេះប្រកបដោយជំនឿ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងអំពីចំណុចនេះ នៅក្នុងសារដែលលោកបានផ្ញើរជូនទៅកាន់គ្រីស្តបរិស័ទនៅពេលថ្មីៗនេះ។

## មេដឹកនាំពិភពលោកស្វាគមន៍លោក ដូណាល់ ត្រាំ ដ៏ប្រយ័ត្នប្រយែង

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូបានធ្វើការអំពាវនាវជាថ្មីឲ្យគ្រិស្តបរិស័ទយកចិត្តទុកដាក់ទៅលើឯកភាពគ្រីស្តសាសនា។

វិទ្យុវាទីកង់បានរាយការណ៍ថា ការអំពាវនាវនេះ ធ្វើឡើងកាលពីថ្ងៃអាទិត្យ ដោយ សម្តេចប៉ាបបានធ្វើការកត់សំគាល់នៅពាក់កណ្តាលសប្តាហ៍នៃពិធីអធិដ្ឋានដើម្បីឯកភាព គ្រីស្តសាសនា ដែលបានរៀបចំឡើងនៅក្រោមប្រធានបទ "ការផ្សះផ្សារជាសេចក្តីស្រលាញ់ នៃព្រះគ្រីស្ត សម្រាប់យើងទាំងអស់គ្នា"។

ប្រភពដដែលបានបន្តថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូនឹងបូកសរុបពិធីនេះជាថ្មីនៅថ្ងៃពុធ នាទីក្រុងរ៉ូម ជាមួយនឹងពិធីមួយចំនួន នៅក្រៅទីលានសន្តយូហាន។

ដើម្បីឲ្យសារនេះជ្រាបបានទៅគ្រីស្តបរិស័ទទាំងអស់ សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ធ្វើការអញ្ជើញឲ្យគ្រីស្តបរិស័ទទាំងអស់អធិដ្ឋាន ហើយចង់ឲ្យពួកគេក្លាយតែមួយនៅក្នុងអង្គព្រះគ្រិស្តតែមួយ។

## សម្តេចប៉ាបអធិដ្ឋានសម្រាប់លោក ដូណាល់ ត្រាំនៅថ្ងៃចូលកាន់ដំណែងប្រធានាធិបតី

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃទី២០មករា២០១៧នៅថ្ងៃដែលលោកដូណាល់ ត្រាំ បានស្បថចូលកាន់ដំណែងប្រធានាធិបតីអាមេរិកទី ៤៥ បានធ្វើអធិដ្ឋានសម្រាប់លោកនាថ្ងៃនោះ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានសំដែងនូវការអបអរសារទរលោក ដូណាល់ ត្រាំ ហើយបានថ្លែងថាព្រះជាម្ចាស់នឹងប្រទានឲ្យលោកនូវគតិបណ្ឌិត និងជំហរសម្រាប់ដឹកនាំអាមេរិក។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានត្រូវទីភ្នាក់ងារព័ត៌មានដកស្រង់សំដីថា លោកបានអធិដ្ឋានឲ្យលោក ដូណាល់ត្រាំ ជួយអ្នកក្រីក្រ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា ខ្ញុំសូមអធិដ្ឋានសូមឲ្យព្រះជាម្ចាស់តម្រង់ការសម្រេច ចិត្តរបស់លោក នៅក្នុងការនាំផ្លូវអ្នកប្រកបដោយស្មារតីដ៏សំបូរបែប និង តម្លៃនៃវប្បធម៌ ដែលនឹង រួមគ្នាជាប្រវត្តិសាស្ត្រ លើកកំពស់សេចក្តីថ្លៃថ្នូរ និង សិទ្ធិសេរីភាពនៅលើពិភពលោក។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ក៏បានបន្តប្រកបដោយសេចក្តីសង្ឃឹមថា នៅក្រោមការដឹកនាំរបស់លោកត្រាំ តួនាទីរបស់អាមេរិកកាំង នឹងបន្តមានវិធានការនៅពីលើបញ្ហាដ៏គួរឲ្យបារម្ភ ទាំងឡាយរបស់អ្នកក្រ និងអស់អ្នកដែលត្រូវការទីពឹងពំនាក់។

## សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ អំពាវនាវជាថ្មីអំពីឯកភាពគ្រិស្តសាសនា

ក្រោយពេលដែល លោក ដូណាល់ ត្រាំ ដឹកដៃក្រុមគ្រួសាររបស់លោក ចូលទៅកាន់កាប់ សេតវិមាន កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ ក្រោយរដ្ឋៈកាល៨ឆ្នាំ របស់ប្រធានាធិបតី បារ៉ាក អូបាម៉ា មេដឹកនាំពិភពលោក បានបញ្ចេញប្រតិកម្មជាបន្តបន្ទាប់។

លោកអេនរិក ប៉េណា នីយ៉េតូ ប្រធានាធិបតីនៃប្រទេសម៉ិកស៊ិក ដែលជាអ្នកធ្លាប់រិះគន់និងប្រឆាំងគោលនយោបាយសាងសង់ជញ្ជាំងនៅតាមព្រំដែន ប្រទេសម៉ិកស៊ិក និងអាមេរិករបស់លោក ត្រាំ កាលនៅជាបេក្ខជនប្រធានាធិបតីនៅឡើយនោះ បានធ្វីតនៅលើបណ្តាញសង្គមថា " យើងនឹងបង្កើតនូវការសន្ទនាដ៏សន្តិភាពជាមួយនឹងរដ្ឋាភិបាលលោកដូណាល់ត្រាំ ដ៏ពិតប្រាកដ ដើម្បីផលប្រយោជន៍ ប្រជាពលរដ្ឋម៉ិកស៊ិកកូ"។

ដោយឡែក ឌីមេទ្រី មេតវេដេវ នាយករដ្ឋមន្ត្រីនៃប្រទេសរុស្ស៊ី ក៏បានចូលរួមអបអរជាមួយ នឹងលោកដូណាល់ ត្រាំ ផងដែរ ខណៈដែលទំនាក់ទំនងការទូតរបស់ប្រទេសអាមេរិក និងរុស្ស៊ី បានរង្គោះរង្គើ នៅចុងរដ្ឋបាលលោក បារ៉ាក់ អូបាម៉ា ជុំវិញបញ្ហាលូកលាន់នៅក្នុងការបោះឆ្នោតអាមេរិក និងបញ្ហាបញ្ជូនកងទ័ពទៅសម្ព័ន្ធមិត្តនៅអតីតប្រទេសនៅតំបន់អឺរ៉ុបខាងកើត និង ការលុកលុយរបស់រុស្ស៊ីនៅតំបន់គ្រីមៀររបស់អ៊ុយក្រែន។

លោក ឌីមេទ្រី មេតវេដេវ បានចែករំលែកប្រតិកម្មរបស់លោក ផ្ទាល់តាមបណ្តាញសង្គមថា "យើងបានត្រៀមខ្លួនរួចរាល់ហើយ សម្រាប់ចែករំលែកការងារនៅក្នុងគោលបំណងកែលំអរទំនាក់ទំនងរបស់យើងឡើងវិញ"។

លោកនាយករដ្ឋមន្ត្រីជប៉ុន ហ្ស៊ីនសូ អាបេ បានចេញនូវសេចក្តីថ្លែងការស្វាគមន៍លោក ដូណាល់ ត្រាំ ប៉ុន្មាននាទីក្រោយពេលលោក បានស្បថចូលកាន់តំណែងនៅសេតវិមាន ខណៈដែលប្រព័ន្ធផ្សព្វផ្សាយជប៉ុន បានរាយការណ៍ថា លោក អាបេ អាចនឹងទៅបំពេញ ទស្សនៈកិច្ចជាថ្មីទៅកាន់អាមេរិកនៅចុងខែមករានេះ។

លោក នាយករដ្ឋមន្ត្រីកាណាដា ចាស្ទីន ទ្រូដូ បានប្រកាសថា កាណាដានឹងធ្វើការជាមួយលោកដូណាល់ ត្រាំ និងរដ្ឋបាលរបស់លោក។ លោកក៏បានបង្ហាញពីសេចក្តីសង្ឃឹម នៅក្នុងការអភិវឌ្ឍន៍និងកែលំអរប្រជាពលរដ្ឋវណ្ណៈកណ្តាល ជាពិសេស គឺប្រជាពលរដ្ឋនៅតាមតំបនព្រំដែន។

## លោកដូណាល់ត្រាំចូលកាន់ តំណែងប្រកបដោយសារជាតិនិយមដ៏មុឹងម៉ាត់

លោក ដូណាល់ ត្រាំ បានស្បថចូលកានតំណែងជាប្រធានាធិបតីអាមេរិកទី ៤៥ កាលពីថ្ងៃសុក្រ ទី២០ ខែមករា ដោយចេញប្រកាសអំពីការប្តេជ្ញាបែបជាតិនិយមយ៉ាងមុតមាំដើម្បីដាក់ "អាមេរិកនៅមុខគេ" ជានិច្ចក្នុងសន្ទរកថាបើកពិធីរបស់គាត់ទៅកាន់ប្រជាពលរដ្ឋអាមេរិក និងពិភពលោកទាំងមូល។

មនុស្សរាប់មឺននាក់បានឈរនៅទីលាន ណេសូណល ម៉ល ( National Mall ) ដែលជោគជាំទៅដោយទឹកភ្លៀងដើម្បីមើលមហាសេដ្ឋីអាយុ ៧០ ឆ្នាំរូបនេះស្បថឡើងកាន់តំណែង និងថ្លែងសារអំពាវនាវដ៏មុតមាំរបស់លោក។

លោកត្រាំ បានថ្លែងថា "ចាប់ពីថ្ងៃនេះតទៅមុខ ចក្ខុវិស័យថ្មីនឹងគ្រប់គ្រងដីរបស់យើង។ ចាប់ពីពេលនេះតទៅផលប្រយោជន៍នឹងជារបស់អាមេរិកមុនគេជានិច្ចតែមួយគត់។ថ្ងៃនេះយើងមិនគ្រាន់តែផ្ទេរអំណាចពីរដ្ឋការមួយទៅរដ្ឋការមួយទៀត ឬ ពី គណបក្សមួយទៅគណបក្សមួយទៀតនោះទេ យើងថែមទាំងផ្ទេរអំណាចពីរដ្ឋាភិបាលក្រុងវ៉ាស៊ីនតោនឌីស៊ី ហើយប្រគល់វាជូនមកអ្នកទាំងអស់គ្នាដែលជាប្រជាជនវិញទៀតផង"។

មុននេះបន្តិច មហាសេដ្ឋីមកពីគណបក្សសាធារណរដ្ឋអាយុ ៧០ ឆ្នាំរូបនេះបានដាក់ដៃឆ្វេងលើព្រះគម្ពីរ ដែលប្រើដោយលោក អាប្រាហាម លីនខូន និងសូត្រតាមនូវពាក្យសម្បថ ៣៥ ពាក្យ ដែលធ្លាប់សូត្រ តាំងពីជំនាន់លោកប្រធានាធិបតីចច វ៉ាស៊ីនតោន។

លោកដូណាល់ត្រាំបានថ្លែងសារដែលមានអត្ថន័យជាតិនិយមបំផុតនៅក្នុងសុន្ទរកថា បើកទំព័រថ្មីនៃរដ្ឋបាលថ្មីនៅសេតវិមាន។

លោកបានថ្លែងថា "ខ្ញុំសន្យាថានឹងយកអ្វីៗទាំងអស់មកជូនប្រជាជនអាមេរិកវិញទាំងអស់។ យើងនឹងកសាងប្រទេសរបស់យើង ដោយដៃរបស់យើង។ អ្វីដែលយើងបានបាត់បង់ និងចំណាយទៅបរទេស យើងត្រូវតែយកមកវិញ ហើយគិតអំពីប្រជាជនអាមេរិកដំបូងគេបង្អស់។ យើងនឹងកសាងអ្វីៗទាំងអស់ ដើម្បីប្រទេសអាមេរិករុងរឿងឡើងវិញ។ យើងនឹងត្រូវបានការពារដោយកងទ័ព ជាពិសេសគឺយើងត្រូវបានការពារដោយអទិទេព។ ពេលវេលាសម្រាប់ការនិយាយតែមាត់ទទេគឺត្រូវបញ្ចប់ យើងត្រូវតែធ្វើសកម្មភាព។ យើងនឹងនាំការ-ងារទាំងអស់មកជូនប្រជាជនអាមេរិករាប់លាននាក់ដលែគ្មានការងារធ្វើ។ យើងនឹងបង្កើតអ្វីៗទាំងអស់សម្រាប់ប្រជា-ជន។ ទាំងអស់គ្នាយើងនឹងធ្វើអោយអាមេរិកថ្កុំថ្កើងតទៅទៀត យើងនឹងធ្វើអាមេរិកអស្ចារ្យម្តងទៀត...!"។

# យើងចេញទៅប្រកាសដំណឹងល្អតាមរបៀបដែលព្រះយេស៊ូបង្កើតព្រះសហគមន៍ដើមដំបូង



*លោកអភិបាល អូលីវីយេ ឝ្មីកអឺស្លែរ*

អត្ថបទទី១៖ ពង្សា ២, ១-៤. ១០-១២
អត្ថបទទី២៖ ទរបា ២៩
ដំណឹងល្អ៖ មក ៦, ៧-១៣

ថ្ងៃនេះព្រះសហគមន៍បានសូមឲ្យយើងស្តាប់ព្រះបន្ទូល អំពីព្រះយេស៊ូចាត់ក្រុមគ្រីស្តទូតឲ្យចេញទៅប្រកាសដំណឹងល្អជាលើកដំបូង ដែលណែនាំឲ្យយើងនឹកឃើញពីគម្រោងការ ដ៏អស្ចារ្យរបស់ព្រះអង្គសម្រាប់ព្រះសហគមន៍។ ដំណឹងល្អតាមសន្តម៉ាកូសបានបង្ហាញថា មុននឹងព្រះយេស៊ូចាត់ក្រុមគ្រីស្តទូតឲ្យចេញទៅ៖ ទី១ ព្រះយេស៊ូបានជ្រើសរើសក្រុមគ្រីស្តទូត១២នាក់ ពីក្នុងចំណោមសាវ័កដែលដើរតាមព្រះអង្គ។ ទី២ ព្រះយេស៊ូគង់នៅជាមួយគេ ព្រះអង្គបង្រៀនគេតាមរយៈធម្មទេសនារបស់ព្រះអង្គ ទៅកាន់បណ្តាជនតាមរយៈធម្មទេសនា និងការអធិដ្ឋានរបស់ព្រះអង្គនៅក្នុងធម្មសាលា និងតាមរយៈការបណ្តេញមារ និងការប្រោស អ្នកជំងឺឲ្យបានជាសះស្បើយ។ ទី៣ ព្រះយេស៊ូចាត់គេឲ្យទៅប្រកាសដំណឹងល្អ នៅពេលពួកគេមានគំនិតចាស់ទុំល្មមខាងជំនឿ គឺក្នុងចំណោម១២នាក់ ព្រះអង្គចាត់គេពីរនាក់ឲ្យចេញទៅ។ របៀបទាំងនេះសំខាន់ណាស់សម្រាប់ព្រះសហគមន៍យើងសព្វថ្ងៃ។ តើសព្វថ្ងៃយើងអាចប្រកាសដំណឹងល្អតែម្នាក់ឯងដូចម្តេចបាន? ប៉ុន្តែបើយើងទៅពីរនាក់ ពីរនាក់នោះយើង នឹងមានឱកាសផ្តល់សក្ខីភាពអំពីការរស់របស់យើងជាបងប្អូនគ្នាក្នុងអង្គព្រះគ្រីស្ត។

អត្ថបទថ្ងៃនេះសំខាន់ណាស់ គឺហាក់បីដូចជានាំយើងឲ្យចូលនៅក្នុងសុបិន្ត នៃទស្សនវិស័យរបស់ព្រះយេស៊ូអំពីព្រះរាជ្យព្រះជាម្ចាស់ និងអំពីរបៀបដែលព្រះអង្គបង្កើតព្រះរាជ្យនៅលើផែនដីដែលមានចំណុចខ្លះៗដូចតទៅ៖

១) ក្នុងចំណោមសាវ័កជាច្រើនដែលដើរតាមព្រះយេស៊ូ ព្រះអង្គបានជ្រើស-រើសគេ ១២នាក់ធ្វើជាគ្រីស្តទូត គឺជាទូតដែលព្រះអង្គនឹងចាត់ឲ្យចេញ ទៅប្រកាសដំណឹងល្អ។ ក្រុមគ្រីស្តទូតរស់នៅជាមួយគ្នាយ៉ាងស្និទ្ធស្នាល និងទទួលភាពកក់ក្តៅយ៉ាងក្រៃលែងពីព្រះយេស៊ូ។ ក្រុមនេះបានធ្វើដំណើរជាមួយគ្នា អធិដ្ឋានជាមួយគ្នា ញ៉ាំបាយជាមួយគ្នា សម្រាកជាមួយគ្នា នឿយហត់ជាមួយគ្នា ហើយគេមានរបៀបរស់នៅជាក្រុមយ៉ាងស្រួល។ ពេលកំណត់មកដល់ព្រះយេស៊ូបានចាត់គេឲ្យចេញទៅប្រកាសដំណឹងល្អ។ ព្រះសហគមន៍កាតូលិកយើងបានធ្វើ ត្រាប់តាមគំរូរបស់ព្រះយេស៊ូ ក្នុងការប្រកាសដំណឹងល្អសព្វថ្ងៃ។ ក្នុងព្រះសហគមន៍របស់យើង ទោះបីយើងមានក្រុមបព្វជិតបព្វជិតាផ្សេងៗគ្នាជាច្រើនក៏ដោយ ក៏យើងស្គាល់គ្នាទៅវិញទៅមកយ៉ាងច្បាស់ និងយើងមានទំនាក់ទំនងជាមួយគ្នាយ៉ាងស្រួល ហើយបេសកកម្ម របស់យើងមិនចប់ត្រឹមនេះទេ ដ្បិតនេះមិនមែនជារបៀបដែលព្រះយេស៊ូបង្កើតព្រះសហគមន៍នោះឡើយ។ តាមរបៀបរបស់ព្រះយេស៊ូ ព្រះសហគមន៍ត្រូវតែចេញទៅណែនាំឲ្យអ្នកដទៃបានស្តាប់ឮព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺត្រូវធ្វើដំណើរពីស្រុកមួយទៅស្រុកមួយ ប្រសិនបើមានគេស្វាគមន៍យើង នោះយើងសុខចិត្តស្នាក់នៅជាមួយគេ ប្រសិនបើគេមិនស្វាគមន៍ទេនោះយើងត្រូវបន្តដំណើរទៅមុខទៀត។ ក្រុមគ្រីស្តទូតដែលធ្វើដំណើរទៅប្រកាសដំណឹងល្អ គេអត់មានលុយ អត់មានយកម្ហូបអាហារទៅជាមួយគេ អត់មានកន្លែងស្នាក់នៅស្រាប់ទេ គេអត់មានស្បែកជើង ហើយក៏អត់មានយកទឹកជាប់នឹងខ្លួនដែរ នេះជារបៀបចេញទៅប្រកាសដំណឹងល្អ។

២) ព្រះយេស៊ូណែនាំឲ្យយើងប្រកាសដំណឹងល្អ គឺឲ្យយើងបង្ហាញអំណរសប្បាយដែល យើងបានទទួលពីព្រះអង្គ។ មួយរយៈពេលដែលក្រុមគ្រីស្តទូតស្នាក់នៅជាមួយព្រះយេស៊ូ គេមានអំណរសប្បាយណាស់ ដោយសារគេបានឃើញផ្ទាល់ភ្នែកថា មានមនុស្សជាច្រើនបានជា សះស្បើយពីជំងឺបានរួចផុតពីអំណាចនៃខ្មោច និងមានខ្លះបានរស់ឡើងវិញ...។ ហេតុដូច្នោះហើយក្រុមគ្រីស្តទូតដែលចេញដំណើរទៅ គឺដើម្បីផ្តល់សក្ខីភាពអំពីអំណរសប្បាយទាំងអស់នោះ ដើម្បីឲ្យអ្នកឯទៀតៗចូលមកទទួលអំណរសប្បាយទាំងនោះដែរ។

ព្រះយេស៊ូមានព្រះបន្ទូលថា "បើអ្នករាល់គ្នាចូលផ្ទះណាមួយ ហើយមានគេទទួលស្វាគមន៍ អ្នករាល់គ្នានោះសូមស្នាក់នៅជាមួយគេហើយផ្តល់សក្ខីភាព ឲ្យគេអំពីអំណរសប្បាយ អំពីសេចក្តីសង្ឃឹម និងអំពីអ្វីៗដែលអ្នករាល់គ្នាបានទទួលពីខ្ញុំ" នេះមានន័យថា គ្រីស្តទូតពីរនាក់ ពីរនាក់ដែលព្រះយេស៊ូចាត់ឲ្យទៅ នោះគេមានតួនាទីមួយយ៉ាងពិសេស គឺគេសាបព្រោះដំណឹងល្អដោយមិនជ្រើសរើសភូមិនេះ ឬភូមិនោះទេ គឺព្រះយេស៊ូសូមឲ្យគេចេញពីភូមិមួយទៅភូមិមួយទៀត ពីស្រុកមួយទៅស្រុកមួយទៀត គឺឲ្យទៅគ្រប់ទីកន្លែងដើម្បីសាបព្រោះ ដ្បិតមនុស្ស ទាំងអស់មានសិទ្ធិស្តាប់ ឮព្រះ-បន្ទូលដំណឹងល្អ មានសិទ្ធិដឹងអំពីគម្រោងការនៃការសង្គ្រោះ។ ប្រសិនបើយើងមិនសាបព្រោះទេ គឺយើងប្រព្រឹត្តខុសនឹងសិទ្ធិដែលមនុស្សទាំងអស់មាន ដើម្បីទទួលការសង្គ្រោះ និងដើម្បីស្តាប់ព្រះបន្ទូលដំណឹងល្អ។ តើធ្វើដូចម្តេចដើម្បីឲ្យមនុស្សដែលមិនទាន់ទទួលការសង្គ្រោះបានទទួលការសង្គ្រោះ? ហើយអ្វីដែលសំខាន់ គឺសូមឲ្យអស់អ្នកដែលបានទទួលការសង្គ្រោះហើយនោះ នៅតែមានភាពជិតស្និទ្ធដដែលជាមួយព្រះអង្គ និងជាមួយគ្នាក្នុងក្រុមពីរនាក់ ពីរនាក់របស់គេដើម្បីជាធ្លុងមួយនៅក្នុងអង្គព្រះគ្រីស្ត។

ខ្ញុំជឿជាក់ថាគ្រីស្តទូតទាំងអស់ ទាំងសន្តម៉ាថាយ ថូម៉ាស់ យូដា ហ្វីលីព បាថូឡូមេសិលា" ទាំងអស់គ្នាមានលក្ខណៈខុសៗគ្នាចរិតខុសៗគ្នា ដោយសារមានអ្នកខ្លះនៅក្មេង អ្នកខ្លះចាស់ មានអ្នកខ្លះមានចរិតរឹងរូស...តែគេពីរនាក់ ពីរនាក់ធ្វើដំណើរជាមួយគ្នាដោយមាន ធ្លុងតែមួយនៅក្នុងអង្គព្រះគ្រីស្ត ដោយសារព្រះយេស៊ូ ជាមូលហេតុព្រះយេស៊ូជា គោលព្រះយេស៊ូ ណែនាំឲ្យគេទៅមុខ។ អ្វីៗទាំងនេះគឺជាមេរៀនសម្រាប់ព្រះសហគមន៍របស់យើង ដែលយើង ទាំងអស់គ្នាក៏មានលក្ខណៈខុសៗគ្នាដែរ ប៉ុន្តែនៅក្នុងព្រះគ្រីស្ត យើងមានទស្សនៈតែមួយយើង មានព្រះគ្រីស្តតែមួយ យើងមានជំនឿតែមួយ ដែលណែនាំឲ្យយើងទៅមុខធ្វើឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់យាងមក។ ដូច្នេះសម្រាប់យើងពីនាក់ ពីរនាក់ក្នុងការប្រកាសដំណឹងល្អ គឺយើងជាក្រុមតូចនីមួយៗ ដែលសហការគ្នានៅក្នុងអង្គព្រះគ្រីស្ត ទោះបីយើងជាមនុស្សប្លែកពីគ្នា។ នេះជារបៀបដែលព្រះយេស៊ូបានបង្កើតព្រះសហគមន៍ដើមដំបូង ដែលជាព្រះសហគមន៍ប្រកាសដំណឹងល្អ។

ថ្ងៃនេះ ជាពេលវេលាមួយដើម្បីឲ្យយើងនឹកឃើញម្តងទៀតថា ព្រះសហ-គមន៍នឹងប្រកាសដំណឹងល្អបានលុះត្រាមានកម្មករ ប្រសិនបើអត់មានកម្មករទេមិនអាចទៅមុខបានទេ។ ឆ្លៀតឱកាសនេះដែរ យើងសូមថ្លែងអំណរគុណជូនលោកអភិបាលអេមីល ដែលជាកម្មករគំរូសម្រាប់យើង។ ក្នុងអត្ថបទទីមួយមានចែងថា "ចូរបុត្រមានចិត្តក្លា-ហានឲ្យសមជាមនុស្សពេញលក្ខណៈ ចូរមានចិត្តស្មោះត្រង់ចំពោះព្រះជាម្ចាស់ជាព្រះរបស់បុត្រ ចូរបុត្រប្រព្រឹត្ត តាមព្រះហឫទ័យរបស់ព្រះអង្គជានិច្ច ហើយកាន់តាមក្រឹត្យវិន័យ តាមបញ្ញត្តតាមច្បាប់ និងតាមដំបូន្មានដូចមានចែងទុកក្នុងធម្ម-វិន័យរបស់លោកម៉ូសេ"។ ពេលស្តាប់អត្ថបទនេះហើយ យើងមានអារម្មណ៍ហាក់បីដូចជាលាកអភិហាលអមើលមានប្រសាសន៍មកកាន់យើងទាំងអស់គ្នា ដែលជាអ្នកបន្តការប្រកាសដំណឹងល្អពីលោក គឺយើងនេះហើយដែលជាអ្នកមានចិត្តក្លាហាន ជាអ្នកដែលមានចិត្តស្មោះត្រង់ និងជាអ្នកដែលកាន់តាមក្រិត្យវិន័យរបស់ព្រះអង្គ។ ដូច្នេះដើម្បីក្លាយទៅជាសាវ័កពីរនាក់ ពីរនាក់ដែលអាចចេញទៅពីរនាក់ ពីរនាក់បាននោះចូរមានចិត្តក្លាហានចូរមានចិត្តស្មោះត្រង់ ចូរធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គជានិច្ច នោះយើងនឹងទៅជាគ្រីស្តទូតពិតៗ ទៅប្រកាសដំណឹងល្អនៅគ្រប់ទីកន្លែង មិនមែនតែកន្លែងដែលយើងរស់នៅនោះទេ។

ថ្ងៃនេះយើងសូមអរព្រះគុណព្រះ-ជាម្ចាស់សម្រាប់ការត្រាស់ហៅ សម្រាប់ការជ្រើសរើស ដើម្បីឲ្យយើងទៅជាសាវ័ក និងទៅជាគ្រីស្តទូតរបស់ព្រះគ្រីស្ត ដោយនឹកឃើញថាព្រះអង្គអធិ-ដ្ឋានដើម្បីឲ្យយើងមានចិត្តក្លាហាន ដើម្បីឲ្យយើងមានចិត្តស្មោះត្រង់ និងដើម្បីឲ្យយើងប្រព្រឹត្តតាមព្រះហឫទ័យ របស់ព្រះអង្គជានិច្ច នៅក្នុងអំណរសប្បាយនៃការប្រកាសដំណឹងល្អ។

# ដំណើរទស្សនកិច្ចរបស់ក្រុមលោកអភិបាល

23 01 2017




សភាលោកឡាវ កម្ពុជាទស្សនកិច្ច នៅក្រសួងអប់រំកាតូលិក ដើម្បីរាយការណ៍អំពីសកម្មភាពអប់រំ នៅកម្ពុជា និងឡាវ។




ក្រុមលោកអភិបាលឡាវ កម្ពុជា ថ្វាយអភិបូជានៅផ្នូររបស់សន្តសិលា

24 01 2017



លោកអភិបាលអូលីវីយេ បានអញ្ជើញទៅ
ក្រុមគ្រួសារបងស្រី ដូមីនីក នៅក្រុ



សភាលោកអភិបាលឡាវកម្ពុជា បានជួបជាមួយលោកកាឌី

27 01 2017



ប្រារព្ធអភិបូជាដ៏វិសុទ្ធនៅ Saint Clement Basilica




ក្រុមលោកអភិបាលទស្សនកិច្ច ក្រសួងផ្នែកពិធីបុណ្យព្រះជាម្ចាស់

30 01 2017



ក្រុមលោកអភិបាលទស្សនកិច្ចក្រសួងកិច្ចការ គ្រហស្ថ ក្រុមគ្រួសារ និងជីវិតថ្មី។



អភិបូជាដ៏វិសុទ្ធជាមួយសម្តេចប៉ាប នៅវិហារ Santa Martha



បរិភោគអាហារពេលល្ងាចនៅផ្ទះនៃក្រុមគោរពបូជាព្រះនាងម៉ារី (OMI)



ក្រុមលោកអភិបាលទស្សនកិច្ចក្រសួងអភិវឌ្ឍធនធានមនុស្ស

# កម្ពុជា និងឡាវនៅបុរីវ៉ាទីកង់ ( Ad Limina visit )



សួរសុខទុក្ខ
ស៊ូយ





ណាល់ ហ្វីឡូនី ទទួលបន្ទុកលើក្រសួងប្រកាសដំណឹងល្អ។

25 01 2017



ក្រុមលោកអភិបាល កម្ពុជា ឡាវ បានចូលរួមសវនាការសាធារណៈ ជាមួយសម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ និងបងប្អូនអ្នកជឿជុំវិញពិភពលោក!



ក្រុមលោកអភិបាល កម្ពុជា ឡាវ បានចូលរួមសវនាការសាធារណៈ ជាមួយសម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ និងបងប្អូនអ្នកជឿជុំវិញពិភពលោក!



ក្រុមលោកអភិបាលទៅលេខាធិការដ្ឋាន នៃក្រសួងសារគមនាគមន៍ ហើយបានបង្ហាញជូន នូវកិច្ចការដ៏ល្អរបស់ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកកម្ពុជា។



ប្រារព្ធពិធីអរព្រះគុណព្រះជាម្ចាស់ ក្នុងវិហារសន្តីម៉ាថា ។



28 01 2017



ប្រារព្ធធ្វើអភិបូជានៅ Saint Maria Maggiore

29 01 2017



ក្រុមលោកអភិបាលបានទៅចូលរួមការប្រារព្ធអភិបូជានៅ San Lorenzo និង ប្រារព្ធខួប ៣០ឆ្នាំ ជាឧបដ្ឋាករបស់ឪពុក នៃលោកអភិបាលអូលីវីយេ។

31 01 2017



ក្រុមលោកអភិបាលទស្សនកិច្ច ក្រសួងកិច្ចសន្ទនាអន្តរសាសនា



ពិធីអភិបូជាបិទទស្សនកិច្ចនៅព្រះវិហារសន្តប៉ូល !



ទស្សនកិច្ចសារមន្ទីរនៅបុរីវ៉ាទីកង់













# ពិធីថ្វាយអភិបូជា ដើម្បីរំឭកខួបគម្រប់១ឆ្នាំ នៃមរណភាពលោកអភិបាលអេមីល ដេតម្ប

